00802418

E1/67.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Apr-2012, 14:16
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅជំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០០ នាទី**

**សវនាការលើកទី៥៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក អេនឌ្រូ ចេមស៍ ម៉ាគិនថាយអ៊័រ
*(Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក សំ សុគង់

លោក ឡោ ជុនធី

លោក គឹម ម៉េងឃី

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elisabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សាឡុត បាន (TCW-586) | ខ្មែរ |
| លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សារបស់សាក្សី) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សាឡុត បាន** (TCW-586)

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី៖......................................................ទំព័រ០២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយថ្ងៃនេះ កត់សម្គាល់ឃើញមេធាវីប្រឹក្សាសាក្សីមានការផ្លាស់ប្តូរ។

តើលោកមេធាវីឈ្មោះអ្វីដែរ លោកមេធាវី?

**លោក ម៉ម រិទ្ធា៖**

សូមគោរពលោកប្រធាន ខ្ញុំបាទជាមេធាវីប្រឹក្សាឲ្យសាក្សី ខ្ញុំបាទឈ្មោះ ម៉ម រិទ្ធា។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីក្រោកឈរនិយាយ។

លោកមេធាវីមានអត្តលេខប៉ុន្មានដែរ អត្តលេខនៅក្នុងគណៈមេធាវី?

**លោក ម៉ម រិទ្ធា៖**

បាទឈ្មោះ ម៉ម រិទ្ធា អត្តលេខ ៦១៩។

[០៩:០១:៤៤]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អង្គុយចុះ!

ម៉េចទៅសាក្សីព្រឹកនេះ តើមានបញ្ហាអ្វីទេ?

**លោក សាឡុត បាន៖**

បាទសូមគោរពលោកប្រធាន អត់មានបញ្ហាអីទេ មានការរីករាយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន បញ្ហាដែលសួរហ្នឹង សួរដោយសារមានការផ្លាស់ប្តូរមេធាវីប្រឹក្សាអមជាមួយលោកនូវក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះហ្នឹងណ៎ះ! បើមិនមានបញ្ហាអីទេ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលតទៅទៀត។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:០២:៤៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាងឯល៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ជម្រាបសួរលោកមេធាវីទាំងអស់ជាទីគោរព ហើយជម្រាបសួរលោកសាក្សីផងដែរ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាងឯល៖**

**ស៖** កាលពីម្សិលមិញលោកបានជួយយើងជាច្រើនដោយឆ្លើយមកសំណួរយើងពេញមួយថ្ងៃ ហើយថ្ងៃនេះ ខ្ញុំសូមឲ្យលោកធ្វើដូចគ្នាអ៊ីចឹង។ ហើយជា-- យើងនឹងចោទសំណួរទៅលើរយៈពេលខែមេសា ឆ្នាំ១៩៧៥ ទៅដល់ខែមករា ឆ្នាំ១៩៧៩។

ជាបឋមខ្ញុំមានសំណួរពីរបីដើម្បីសូមការបំភ្លឺអំពីលោក ហើយខ្ញុំនឹងត្រឡប់មកនិយាយអំពីអ្វីដែលបានលើកឡើងទាក់ទងនឹងមន្ទីរក-១ ។ លោកបានបញ្ជាក់ថា អ្នកថ្នាក់ដឹកនាំជាន់ខ្ពស់បានប្រជុំគ្នាជាញឹកញាប់នៅ ក-១ ហើយលោកបានពន្យល់ថា លោកបានទៅ ក-១ នោះម្ដងម្កាលដែរ ដើម្បីជួបប្រពន្ធរបស់លោកដែលធ្វើការនៅទីនោះជាចុងភៅ។

តើលោកអាចជម្រាបយើងបានដែរឬទេ ថាលោកទៅមន្ទីរក-១ នោះញឹកញាប់ដែរឬទេ? ប៉ុន្មានដងក្នុងមួយខែ?

[០៩:០៤:២០]

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំមិនអាចរៀបរាប់ជូនបានទេ ពីព្រោះសភាពការណ៍នៅពេលនោះក៏សម្ងាត់ ហើយខ្ញុំយល់ឃើញថា ការសម្ងាត់ដែលខ្ញុំធ្វើទាំងប៉ុន្មានត្រូវតែឲ្យស្ងាត់រហូតទាល់តែឯងផុតជីវិត។

**ស៖** តើខ្ញុំត្រូវយល់ថា លោកជំទាស់មិនឆ្លើយនឹងសំណួរនេះ ឬក៏យ៉ាងម៉េច? ឬក៏លោកចង់ឆ្លើយមកយើងថា តើលោកទៅមន្ទីរក-១ នោះ ប៉ុន្មានដងក្នុងមួយខែនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សី ឥឡូវ យើងបានជម្រាបរួចហើយ អំពីកាតព្វកិច្ចរបស់សាក្សី ហើយឥឡូវនេះ យើងរំឭកម្ដង ថាក្នុងនាមលោកជាសាក្សីត្រូវផ្ដល់សក្ខីកម្ម កិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះត្រូវ

ឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគីសួរចំពោះលោក។ លើកលែងតែសំណួរដែលនាំឲ្យលទ្ធផល នាំឲ្យចម្លើយរបស់លោក ឬសេចក្តីអះអាងរបស់លោកហ្នឹង គឺដាក់បន្ទុកលើខ្លួនឯង។ បានន័យថា សារភាពកំហុស ឬក៏ឆ្លើយកំហុសដាក់លើខ្លួនឯង អំពីអំពើផ្សេងៗ វិនាសកម្មផ្សេងៗបង្កឡើងនៅក្នុង របបហ្នឹង។ ក្រៅពីនេះ គឺឲ្យតែអ្វីដែលលោកបានដឹង បានឮ បានឃើញ ឬក៏មានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការសង្កេតនៅក្នុងសម័យនុ៎ង គឺលោកអាចឆ្លើយបានហើយ។ ឧទាហរណ៍គ្រាន់តែសួរថា ទៅញឹក ញាប់យ៉ាងម៉េចដែរ? មួយខែប៉ុន្មានដង? ឬក៏មួយឆ្នាំប៉ុន្មានដងអ៊ីចឹង? គ្រាន់តែប្រហែល ក៏អាចឆ្លើយ បានដែរ វាមិនមែនជាការសម្ងាត់អ្វីទេ។ បាទ ពីព្រោះនេះ ជាការស្វែងរកការពិត។ ប្រសិនបើជនគ្រប់ រូប ចំពោះមុខអង្គជំនុំជម្រះ សុទ្ធតែរក្សាការសម្ងាត់ តុលាការអត់មានព័ត៌មានអីច្រើនទេ សម្រាប់វិភាគ ពិចារណា ថាតើរឿងហ្នឹង វាដូចម្តេច? ហើយតុលាការវាយតម្លៃចុងក្រោយដូចម្តេច? ពឹងផ្អែកទៅលើ ព័ត៌មានដែលផ្តល់ឡើងដោយភាគី ដោយសាក្សី ដែលបានមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះហ្នឹង ហើយ។ អង្គជំនុំជម្រះនឹងមានមូលដ្ឋានក្នុងការវិភាគពិចារណា ថ្លឹងថ្លែង ដើម្បីសម្រេចចុងក្រោយ ថារឿងក្តីនោះ វានឹងយ៉ាងដូចម្តេច?

អង្គជំនុំជម្រះសង្ឃឹមថា សាក្សីនឹងយល់បញ្ហានេះ ហើយនិងអាចសហការជាមួយនឹងតុលាការ បានល្អ។

សូមអញ្ជើញលោកអយ្យការ អាចបន្តការសួរដេញដោលទៀត។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេះ**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេះ**

**ស៖** ខ្ញុំសួរម្តងទៀត បាទ លោកបាននិយាយថា លោកបានទៅជួបប្រពន្ធគាត់នៅមន្ទីរក-១ តើលោកទៅទីនោះ ញឹកញាប់ដែរឬទេ? ហើយបើញឹកញាប់ ញឹកញាប់កម្រិតណា?

[០៩:០៧:៣៣]

**លោក សាឡុត បាន៖**

**ឆ៖** បាទ ការដែលខ្ញុំឆ្លើយនេះ ខ្ញុំឆ្លើយ ១ថា ខ្ញុំមិនឆ្លើយទេ ដើម្បីរក្សាការសម្ងាត់របស់ខ្ញុំអស់ មួយជីវិត។ ពីព្រោះខ្ញុំយល់ឃើញថា ពីម្សិលមិញនេះ ការសំណួរដែលឆ្លើយមកខ្ញុំ គឺសុទ្ធតែសំណួរឲ្យខ្ញុំ វ័ណ្ឌក។

**ប្រធានអង្គជំនុំ៖**

តាមការស្តាប់របស់អង្គជំនុំជម្រះ តាំងពីដើមរហូតដល់ចប់ មិនមានសំណួរឯណាដែលនាំឲ្យលោកឆ្លើយមានពិរុទ្ធភាពលើខ្លួនលោកទេ។ ពាក្យថា "វ័ណ្ឋក" មានន័យថាលោកត្រូវមានកំហុសនៅក្នុងហ្នឹង តាមអ្វីដែលយើងបានដំណើរការនីតិវិធីមក គឺមិនមានសំណួរ ហើយនិងចម្លើយណាមួយដែលដាក់ពិរុទ្ធភាពលើខ្លួនឯងទេ។ បាទ អ៊ីចឹង សូមលោកសហការជាមួយតុលាការបន្តទៅទៀត ហើយដោយឡែករឿងក្តីនេះ លោកបានជ្រាបហើយ នៅក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងរវាងកម្ពុជាជាមួយរដ្ឋាភិបាលកម្ពុជា ជាមួយនឹងអង្គការសហប្រជាជាតិ ក៏ដូចជាច្បាប់ អ.វ.ត.ក ដែលបង្កើតឡើងដោយផ្អែកលើកិច្ចព្រមព្រៀង គឺកំណត់វិសាលភាពនៃការចោទប្រកាន់ចំពោះតែមនុស្សពីក្រុមប៉ុណ្ណោះ។ ថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត។ អ៊ីចឹងអ្នកផ្សេងទៀតហ្នឹង គឺមិនមែនជាកម្មវត្ថុនៃការចោទប្រកាន់នោះឡើយ។

[០៩:០៩:៣៣]

ម្យ៉ាងទៀត នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ អង្គជំនុំជម្រះបានរំឭកពីសិទ្ធិលោកហើយ ហើយថែមទាំងចាត់តាំងនូវមេធាវីប្រឹក្សាលោកទៀតផង ដើម្បីលោកមានឱកាសនៅក្នុងការប្រឹក្សា។ ប្រសិនបើសំណួរឯណាដែលសួរទៅលោក ពាក់ព័ន្ធនឹងអំពើទាំងឡាយដែលមានវិនាសកម្ម ដែលអាចថាបង្កដោយលោក ឬក៏លោកបានចូលរួម។ នោះគឺលោកអាចពិភាក្សាជាមុន ហើយលោកសម្រេចថា ឆ្លើយតបទៅនឹងសំណួរ ឬក៏មិនឆ្លើយតបទេ។ នេះជាសិទ្ធិមានចែង ហើយយើងបានប្រាប់រួចហើយ។

ដោយឡែកបញ្ហាផ្សេងទៀត ដែលមានកាតព្វកិច្ច បានន័យថាមានភារកិច្ចត្រូវតែឆ្លើយនូវអ្វីដែលខ្លួនលោកបានដឹង បានឮ បានឃើញ។ មិនមានអ្វីដែលថា ពាក្យថា "វ័ណ្ឋក" ទៅលោកនោះទេ គឺអត់ទាន់មានអីទេណា។ អ៊ីចឹងលោកប្រឹងប្រែងឡើងវិញ។ ម្សិលមិញឃើញថាឆ្លើយល្អណាស់ បញ្ហាដែលលោកបានឆ្លើយមក គឺឃើញថាវាឆ្លើយតបទៅនឹងអ្វីដែលជាតម្រូវការព័ត៌មាន និងសព្វគ្រប់ដែលអង្គជំនុំជម្រះមានបំណងចង់ទទួលដើម្បីឲ្យបានយកទៅពិនិត្យពិចារណានៅក្នុងការសម្រេចសេចក្តីក្នុងរឿងក្តីនេះ។

លោកយល់ទេ?

សូមលោកខិតខំ ដើម្បីធ្វើកម្រិតយ៉ាងហោចណាស់ក៏ត្រឹមដូចម្សិលមិញអ៊ីចឹង កុំឲ្យមានបញ្ហាអី។ លោកអត់មានបញ្ហាអីទេណា។

[០៩:១១:១២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទលោកប្រធាន បាទ ខ្ញុំអនុញ្ញាតសួរសំណួរដដែលទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំសួរសំណួរដដែល លោក-- កាលពីម្សិលមិញ លោកបាននិយាយថា លោកបានទៅមន្ទីរក-១ ដើម្បីជួបប្រពន្ធរបស់លោក តើលោកទៅទីនោះប៉ុន្មានដង ហើយញឹកញាប់យ៉ាងម៉េចដែរ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំចូលមកធ្វើសវនាការក្នុងអង្គតុលាការនេះ ខ្ញុំបានស្បថស្បែចំពោះមុខលោកតាដំបងដែក។ យប់មិញនេះ លោកតាដំបងដែក បានប្រមូលបុព្វការីជនទាំងអស់មកប្រាប់ខ្ញុំថា "ឯង! កុំនិយាយអីផ្តេសផ្តាស។ ឯង! ត្រូវគិតភាសាខ្មែរឲ្យច្បាស់ សិរីសួស្តី។ ពាក្យថា "សេរី សួស្តី" បើសំណួរណាមិនមានសិរីសួស្តីទេ ឯង! មិនត្រូវស្តីរកទេ"។ នេះជាបណ្តាំលោកតាដំបងដែកប្រាប់ខ្ញុំ។ សូមតុលាការជ្រាប។

[០៩:១៣:២៣]

**ប្រធានអង្គជំនុំ៖**

បន្តសំណួរផ្សេងទៀតបាន។ ទុកសំណួរអម្បាញ់មិញនេះមួយអន្លើសិនទៅ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី កាលពីម្សិលមិញ លោកបាននិយាយលោកបានទៅមន្ទីរក-១ តើលោកដើម្បីទៅទីនោះ ឬក៏ដើម្បីដើរហើរនៅក្នុងក្រុងនោះ តើលោកត្រូវការការអនុញ្ញាតដែរឬទេនៅសម័យនោះ?

**ឆ៖** លោកតាដំបងដែកបានប្រាប់ខ្ញុំទៀតថា "តុលាការនេះ មិនយុត្តិធម៌១០០ភាគរយទេ។ ល្អហើយតុលាការនេះមានខ្មែរ មានអន្តរជាតិ។ បើតុលាការអន្តរជាតិនៅប្រទេសផ្សេងៗ គេយកឯងទៅព្យួរកហើយ តែភព្វសំណាងឯងមានតុលាការនៅក្នុងពេលនេះ ដែលគេហៅថា តុលាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហៅក្រៅនោះគេហៅថា តុលាការ-- តុលាការកាត់ទោសខ្មែរក្រហមឲ្យ

ផុតពូជហើយ។ ព្រះអង្គដំបងដែកប្រាប់ខ្ញុំមកអ៊ីចឹង។ ខ្ញុំសួរទៅព្រះអង្គថា ចុះឯងម៉េចក៏ថាតុលាការហ្នឹង អត់យុត្តិធម៌? ទេ ពីតុលាការនេះអត់កាត់ ០០០ កាត់--

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះជំហរសាក្សីបង្ហាញជំហរយ៉ាងម៉េចទៅ? លោកប្រកែកមិនព្រមឆ្លើយចាប់ពីពេលនេះតទៅ ឬយ៉ាងម៉េច? និយាយឲ្យបានច្បាស់លាស់។ នៅក្នុងពាក្យសម្បថ គឺលោកបានឆ្លើយច្បាស់លាស់ហើយ នៅក្នុងច្បាប់គឺតម្រូវឲ្យលោកឆ្លើយតែការណាដែលពិត ដែលខ្ញុំបានដឹង បានឃើញ បានឮ និងបានចាំផ្ទាល់។ លោកមានស្បថប្រើពាក្យនេះដែរទេ កាលពីម្សិលមិញ?

**លោក សាឡុត បាន៖**

បាទ ខ្ញុំបានស្បថ។ ប៉ុន្តែ ដូចបានជម្រាបជូនហើយ ខ្ញុំបានយល់សប្តិលោកតាមកប្រាប់ខ្ញុំយ៉ាងដូច្នេះ។

[០៩:១៦:៥៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវបញ្ហានេះយើងអត់ឲ្យអ្នកឯងនិយាយទៀតទេ។ បញ្ហាសំខាន់មិនយកសប្តិ យល់សប្តិហ្នឹង អបិយជំនឿហ្នឹងយកមកគ្របដណ្តប់នៅក្នុងដំណើរការនីតិវិធីរបស់តុលាការទេ។ យើងបានស្តាប់អ្នកឯងរួចហើយ អម្បាញ់មិញអ្នកឯងយកសប្តិ តម្កល់សប្តិដែលជាអបិយជំនឿហ្នឹងយកធ្វើជាធំមករារាំងកិច្ចដំណើរការរបស់តុលាការ។ ឥឡូវនេះបញ្ហាអ្នកឯង ជំហរអ្នកឯងគិតយ៉ាងម៉េចទៅឥឡូវនេះចំពោះបញ្ហាចំពោះមុខនាពេលនេះ ក្នុងការឆ្លើយតបទៅនឹងសំណួរ? ព្រោះអ្នកឯងផ្អែកលើពាក្យសម្បថគឺច្បាស់លាស់ណាស់លើពាក្យសម្បថដែលបានឲ្យធ្វើសម្បថ ព្រោះពាក្យសម្បថនេះមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ដែលពាក្យពេចន៍ទាំងអស់នេះដាច់ខាតត្រូវតែដកស្រង់យកទៅធ្វើសម្បថនៅចំពោះមុខកិច្ចដំណើរការរបស់តុលាការ ទាំងកម្ពុជា ទាំងនៅក្នុងក្របខ័ណ្ឌអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ពីព្រោះតុលាការនេះជាតុលាការដំណើរការតាមច្បាប់កម្ពុជា។

**លោក សាឡុត បាន៖**

បាទ ខ្ញុំសូមឯកភាពតាមលោកប្រធានតុលាការ។ ដូច្នេះ ខ្ញុំគ្រាន់តែសំណូមពរថា សូមតុលាការមានអឺខុសឆ្គង ក៏សូមថា កុំឲ្យខ្ញុំ ៗប្រើពាក្យថា “វ័ណ្ឌក”មកខ្ញុំផង។ បាទ សូមអរគុណបាទ។

[០៩:១៨:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានមានការប្រយ័ត្នប្រយែង ហើយដោយសារលោកមានសំណូមពរ សូមឲ្យមានមេធាវីប្រឹក្សាអមលោក ដើម្បីស្ដាប់ និងពិភាក្សានូវសំណួរឯណាដែលនាំឲ្យលទ្ធផលនៃចម្លើយតបរបស់លោក ឬក៏សេចក្ដីអះអាងរបស់លោកនុ៎ង វាអាចនាំឲ្យមានពិរុទ្ធភាព។ អ៊ីចឹងសំណួរនេះគឺ សូម្បីតែអង្គជំនុំជម្រះខ្លួនឯងក៏ប្រយ័ត្នប្រយែងស្ដាប់ ប្រសិនបើចូលដល់ស្ថានភាពនោះក៏អង្គជំនុំជម្រះនឹងមិនឲ្យលោកឆ្លើយដែរ។ លើកលែងតែអង្គជំនុំជម្រះស្ដាប់ទៅមិនទាន់ ឬក៏មិនយល់នូវខ្លឹមសារដោយសារការបកប្រែជាដើម អានោះគឺអាចមានបញ្ហា។ អ៊ីចឹងហើយបានជាយើងបានជម្រាបទៅដល់មេធាវីកាលពីម្សិលមិញរំឭកថា មេធាវី ឥឡូវនេះថ្ងៃនេះគឺបន្ថែមទៀត ដោយសារមានមេធាវីថ្មី គឺសូមឲ្យមេធាវីហ្នឹងជួយលោកនៅក្នុងការស្ដាប់នូវរាល់សំណួរដែលសួរដោយភាគី ឬក៏សួរដោយអង្គជំនុំជម្រះចំពោះលោក ដើម្បីវិភាគមើលថាតើសំណួរហ្នឹងនាំឲ្យលោកឆ្លើយហ្នឹង ថាលោកហ្នឹងជាអ្នកប្រព្រឹត្ត ឬក៏លោកហ្នឹងជាអ្នកចូលរួមក្នុងការប្រព្រឹត្តនៅក្នុងអំពើវិនាសកម្មផ្សេងៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[០៩:២០:១៤]

បើសិនបើសួរសំណួររបៀបនេះ លោកអាចពិភាក្សាជាមួយនឹង សុំពេលវេលាដូចម្សិលមិញ អ៊ីចឹងពិភាក្សាគ្នា ថាទៅថាគួរឆ្លើយ ឬក៏សុំមិនឆ្លើយ? បើសិនណាមិនឆ្លើយទេ អង្គជំនុំជម្រះអាចសម្រេចថាឲ្យលោកឆ្លើយ ឬក៏សម្រេចថា មិនចាំបាច់ឆ្លើយទេ។ ដូចអ្វីដែលយើងបានធ្វើពីម្សិលមិញ ច្រើនករណីហើយណើះ! កាលណាជំទាស់ទៅថាឲ្យលោកឆ្លើយ ឬក៏មិនឲ្យឆ្លើយទេ ថាឲ្យសួរផ្សេងទៀត សំណួរផ្សេងទៀត។

**លោក សាឡុត បាន៖**

*(និយាយមិនបើកមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

បាទ ៗ។ បាទ អង្គជំនុំជម្រះសង្ឃឹមថា លោកនឹងដំណើរការបានល្អ ហើយសហការបានល្អនៅក្នុងកិច្ចដំណើរការនេះក្នុងគោលបំណង ដើម្បីស្វែងរកការពិតទាំងអស់គ្នា។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:២១:០៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានខ្ញុំសូមអរគុណលោកប្រធាន។ បាទ ខ្ញុំឈប់និយាយអំពីប្រធានបទក-១ ខ្ញុំនឹងចោទសំណួរផ្សេងទៀតទៅសាក្សី។ ក៏ប៉ុន្តែខ្ញុំសូមជម្រាបជូនដល់អង្គជំនុំជម្រះថា បើសិនជាសាក្សីជំទាស់មិនឆ្លើយតបនឹងសំណួរ យើងនឹងធ្វើការ-- ធ្វើសវនាការជាអសាធារណៈដើម្បីនិយាយអំពីវិធី២៨។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ទាក់ទងនឹងអ្វីដែលបានលើកឡើងកាលពីម្សិលមិញ គឺថានៅពេលដែលអៀង សារី អវត្តមានដោយមានបេសកកម្មនៅបរទេស លោកបាននិយាយថា "ពុំមានការប្រជុំសំខាន់អ្វីទេនៅពេលនោះ ហើយក៏ពុំមានការសម្រេចធំដុំអ្វីដែលនៅពេលដែលគាត់អវត្តមាន ហើយក៏ពុំមានបញ្ហាអ្វីដែលត្រូវដោះស្រាយនោះដែរ។ ដូច្នេះក្រសួងមិនត្រូវទទួលជំនួយការពីគណៈមជ្ឈិមទេ"។ តើនេះពិតជាអ្វីដែលបានលោកបានលើកឡើងកាលពីម្សិលមិញដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ត្រឹមត្រូវ ប៉ុន្តែខ្ញុំមិនទទួលខុសត្រូវទេ ខុសត្រូវទេ។

[០៩:២២:៤២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមបង្ហាញឯកសារមួយដល់លោក ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់លោក ដែលខ្ញុំពុំទាន់បានបង្ហាញជូនសាក្សីទេលោកប្រធាន គឺជាឯកសារ E3/417 ហើយនិង D233/9។

សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញចម្លើយលេខ៧ របស់សាក្សីទៅដល់អ្នកស៊ើបអង្កេតនៃតុលាការយើងនេះ គឺនៅថ្ងៃទី២៧ តុលា ឆ្នាំ២០០៩។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីតុលាការដើម្បីបង្ហាញឯកសារនេះ និងផ្តល់ឯកសារចម្លងមួយទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ទៅជូនសាក្សីពិនិត្យ ហើយចង្អុលបង្ហាញផងចំណុចដែលត្រូវពិភាក្សាដេញដោលនាពេលនេះ។

[០៩:២៤:១៩]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** នេះគឺជាចម្លើយទី៧។ បាទ ខ្ញុំសូមអានចម្លើយនេះទាំងស្រុងតែម្តង ដើម្បីឱ្យយើងយល់

បរិបទ។ សំណួរគឺថា "តើនៅពេលដែលលោក អៀង សារី ទៅបំពេញបេសសកម្មនៅក្រៅប្រទេស តើលោកជាអ្នកដឹកនាំកិច្ចប្រជុំរបស់ក្រសួងបរទេសមែនទេ? ចុះពេលដែលលោក និងលោក អៀង សារី ទៅបរទេស តើមានអ្នកណាទទួលខុសត្រូវក្រសួងការបរទេស?"ចម្លើយ៖ បាទ ខ្ញុំដឹកនាំការប្រជុំការងាររបស់ក្រសួង ពេលដែលបង អៀង សារី ចេញទៅក្រៅប្រទេស ខ្ញុំដឹកនាំ គ្រប់គ្រងជំនួសគាត់ដោយមានការណែនាំអំពីមជ្ឈិមបក្ស។ ពេលខ្ញុំ និងបង អៀង សារី ទៅបរទេសមានសមមិត្ត ជាម ជួនកាលសមមិត្ត មី, សមមិត្ត ឌិក សុគន្ធ ជួនកាលសមមិត្ត ប៊ិច ប៊ុនណារ៉េត។ ចំពោះថ្នាក់ដឹកនាំខាងលើពុំមានមកជំនួសនៅក្រសួងការបរទេសទេ។ ប៉ុន្តែគ្រាន់តែមានការណែនាំអំពីថ្នាក់លើតាមទូរស័ព្ទ។ សរុបទៅពេលគាត់ចេញទៅក្រៅប្រទេស ក្រសួង-- ការងារក្រសួងធំៗរបស់ក្រសួងមិនសូវមានតែ ច្រើនតែមានការងារជីវភាពតែប៉ុណ្ណោះ"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

[០៩:២៦:១០]

អ្វីដែលលោកបានលើកឡើងកាលពីម្សិលមិញ គឺថាមានបញ្ជាក់នៅក្នុងចម្លើយនេះ។ ក៏ប៉ុន្តែមានចំណុចមួយចំនួនដែលខុសពីនេះ តើលោករក្សាចម្លើយរបស់លោកអម្បាញ់មិញនេះទេ ដែលលោកបានចុះហត្ថលេខាចំពោះមុខអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត?

**លោក សាឡុត បាន៖**

**ឆ៖** តាម បាទ សួរបាទ ខ្ញុំបាទ--

*(សាក្សីពិភាក្សាជាមួយមេធាវី)*

[០៩:២៧:៤២]

**ឆ៖** សំណួរនេះខ្ញុំយល់ស្របតាមចម្លើយដើម។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ខ្ញុំគ្មានភារកិច្ចអីទៅសម្រេចការងារនោះទេ។

**ស៖** បាទសូមអរគុណលោកសាក្សី។ នៅក្នុងចម្លើយរបស់លោក លោកបាននិយាយអំពីឋានានុក្រម ដែលផ្តល់អនុសាសន៍តាមរយៈទូរស័ព្ទ។ តើលោកនិយាយអំពីអ្នកណាដែលនៅពេលដែលលោកនិយាយអំពីឋានានុក្រមនោះ? តើសំដៅលើអ្នកណា? ថាតើអ្នកណាទាក់ទងទៅក្រសួងតាមរយៈទូរស័ព្ទនោះ?

**ឆ៖** ពេលនោះប្រហែលជាលោក ប៉ង់។ គឺលោក ប៉ង់ អត់ប្រហែលទេ គឺលោក ប៉ង់ តែម្តងបាទៗ ខ្ញុំចាំបាន។

**សៈ** តើ ប៉ង់ ធ្វើការណែនាំមកដល់លោករបៀបណា ឬក៏ទៅក្រសួង ហើយនៅពេលដែល លោក អៀង សារី អវត្តមាននោះ?

[០៩:២៩:៣២]

**ឆៈ** ការដែលណែនាំ មិនរៀបរាប់អស់ទេ ណែនាំសរុបមកមានពីរ ធ្វើម៉េចកុំឱ្យបែកបាក់គ្នាក្នុង កុំឱ្យមានទំនាស់ រក្សាសន្តិសុខឱ្យបាន តែប៉ុណ្ណឹង។

**សៈ** បាទ សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីទំនាក់ទំនងជាមួយលោក ប៉ង់ នៅពេលក្រោយ។ ម្សិលមិញនេះ ដើម្បីបំភ្លឺលើរចនាសម្ព័ន្ធនៃក្រសួងការបរទេស ខ្ញុំត្រូវចោទសំណួរលោកពីរបីសំណួរមុននិងពេលដែលខ្ញុំត្រឡប់មកនិយាយអំពីទំនាក់ទំនងជាមួយលោក ប៉ង់។ តើក្រសួងការបរទេសគឺថា មានការិយាល័យពិធីការដែរឬទេ?

**ឆៈ** នៅក្នុងក្រសួងមានការិយាល័យ-- ទេ ដូចជាមិនមានទេការិយាល័យពិធីការទេ។ តាមខ្ញុំពិនិត្យមើលចេះតែច្រឡំមាត់ថា ការិយាល័យ ប៉ុន្តែវាមិនទាន់រៀបរយជាការិយាល័យទេ។ គឺចាប់អ្នកនេះចាប់អ្នកនោះមក អ្នកណាចេះធ្វើអីល្អមៗទៅក៏ឱ្យទៅធ្វើទៅ ការរៀបចំប្រទេសពេលនុ៎ង វាមិនទាន់បានសាម-សែសិបឆ្នាំទេ វាបានតែមួយខែពីរខែ ដូច្នេះអារម្មណ៍នឹកឃើញទៅដល់៤០ឆ្នាំ វាខុស។ ដូច្នេះរៀបចំមួយអាទិត្យ ពីរអាទិត្យអត់មានការិយាល័យទេ គឺចាប់នេះចាប់នោះ ធ្វើម៉េចឱ្យតែបានដំណើរការទៅ។

[០៩:៣១:៥៧]

**សៈ** ពីរបីខែក្រោយមកនោះ ខ្ញុំគិតថាក្រសួងហ្នឹងត្រូវបានរៀបចំរចនាសម្ព័ន្ធ ហើយនៅពេលនុ៎ងនៅឆ្នាំ៧៦ ឆ្នាំ៧៧ ឆ្នាំ៧៨ តើមានការិយាល័យដែលទទួលបន្ទុកខាងពិធីការដែរឬទេ? ឬក៏គ្រាន់តែមានមនុស្សដែលគេ ដែលគេចាត់តាំងដើម្បីឱ្យបំពេញភារកិច្ចនុ៎ង តែប៉ុននុ៎ងទេ?

[០៩:៣២:២៧]

**ឆៈ** បាទ ត្រឹមត្រូវ។

**សៈ** តើអ្នកណាជាប្រធានការិយាល័យ ឬក៏ផ្នែកពិធីការនុ៎ង?

**ឆៈ** គឺៗមិនកំណត់ ពេលខ្លះហៅបង ជួន ប្រាសិទ្ធ ទៅ, ពេលខ្លះហៅបង គាត ឈន់ ទៅ, ពេលខ្លះហៅអ្នកនេះ ហៅអ្នកនោះទៅ ដែលជាបញ្ញាជន អត់មានកំណត់។

**សៈ** បាទ ទាក់ទងនឹងរចនាសម្ព័ន្ធដដែល តើក្រសួងមានការទំនួលខុសត្រូវជាក់លាក់ទាក់ទងទៅនឹងព្រលានយន្តហោះពោធិ៍ចិនតុងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** អ្នកណា អ្នកទទួលបន្ទុកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ? បរទេស ឬក៏គណៈប្រតិភូបរទេស ឬក៏បញ្ញាជន ដែលត្រឡប់មកពីបរទេស? តើជាក្រសួងរបស់លោក ឬក៏ជាក្រសួងមួយទៀតផ្សេងទៀត?

[០៩:៣៤:២១]

**ឆ៖** អត់យល់។ សូមបញ្ជាក់សំណួរម្តងទៀត ខ្ញុំអត់យល់។

**ស៖** ខ្ញុំចង់ដឹងថា ទាក់ទងទៅនឹងការទទួលគណៈប្រតិភូបរទេស ដែលមកទស្សនកិច្ចកម្ពុជាប្រជាធិបតេយ្យ និងការទទួលបញ្ញាជនកម្ពុជាដែលត្រឡប់មកប្រទេសកម្ពុជាវិញ។ តើក្រសួងរបស់លោកដែលជាអ្នកទទួលបន្ទុកគឺថា ក្រសួងរបស់លោកទៅព្រលានយន្តហោះដើម្បីទទួលពួកគាត់ទាំងអស់គ្នា ឬក៏ជាក្រសួងផ្សេងទៀត ដែលទទួលបន្ទុកខាងការទទួលនេះ?

**ឆ៖** ក្រសួងការបរទេសមិនទទួលបន្ទុកទេ គឺលោក ប៉ង់។

**ស៖** យើងនឹងត្រឡប់មកនិយាយអំពីចំណុចនេះនៅពេលក្រោយ។ តើស្ថានទូតនៃកម្ពុជាប្រជាធិបតេយ្យដែលប្រចាំនៅបរទេស ហើយនិងបុគ្គលិករបស់ស្ថានទូតនោះស្ថិតនៅក្រោមចំណុះរបស់ក្រសួងការបរទេសដែរឬទេ?

**ឆ៖** គឺស្ថិតនៅក្នុងក្រសួងការបរទេស។

[០៩:៣៦:៣១]

**ស៖** តើក្រសួងការបរទេសផ្តល់សេចក្តីណែនាំ ឬក៏ជូនព័ត៌មានទៅឲ្យឯកអគ្គរដ្ឋទូត ឬក៏បុគ្គលិករបស់ស្ថានទូតតាមរយៈមធ្យោបាយទំនាក់ទំនងអ្វីខ្លះ?

**ឆ៖** តាមទំនាក់ទំនងក្រសួងការបរទេស។ ហើយរឿងអីៗ ខ្ញុំអត់ដឹងទេ។

**ស៖** *(គ្មានការបកប្រែ)*

*(មានបញ្ហាបច្ចេកទេសសំឡេង)*

[០៩:៤០:១៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

*(គ្មានការបកប្រែ)*

[០៩:៤០:៣៥]

**អ្នកបកប្រែ៖**

លោកប្រធាន អម្បាញ់មិញនេះ អ្នកបកប្រែមិនអាចចុចមីក្រូបានទេ លោកប្រធាន។ តែទើបបានឥឡូវអាចចុចបានវិញហើយ សូមឲ្យសហព្រះរាជអាជ្ញាសួរឡើងវិញ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាសូមតាំងសំណួរសាជាថ្មី។ អម្បាញ់មិញមានបញ្ហាបច្ចេកទេសប្រព័ន្ធសំឡេងដដែល។ បាទ ឥឡូវទំនងជាលែងមានបញ្ហាអីហើយ លោកចាប់ផ្ដើមសាជាថ្មី។

អ្ហះ! បកបានទេ?

ម៉េចទៅអ្នកបកប្រែ អាចដំណើរការបានទេ?

**អ្នកបកប្រែ៖**

ជម្រាបប្រសាសន៍លោកប្រធាន ឥឡូវដំណើរការបានហើយ។

[០៩:៤២:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បន្តកិច្ចពិភាក្សាដេញដោល។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អម្បាញ់មិញនេះ ខ្ញុំមានសំណួរ តើមានទំនាក់ទំនងដោយផ្ទាល់រវាងក្រសួង និងស្ថានទូតទាំងអស់ ឬមួយក៏ត្រូវឆ្លងកាត់តាមរយៈស្ថានទូតជាក់លាក់ណាមួយ ដើម្បីទាក់ទងទៅកាន់ស្ថានទូតផ្សេងៗនោះ តាមរយៈខ្សែកាប ដែលលោកបានបញ្ជាក់អម្បាញ់មិញនេះ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែការងាររបស់ខ្ញុំ គឺខាងជីវភាព។

**ស៖** សូមអរគុណ។ តើស្ថាប័នណាដែលចំណុះឲ្យផ្សាររដ្ឋ? (ខ្ញុំសូមទោស) តើផ្សាររដ្ឋនៅកម្ពុជាប្រជាធិបតេយ្យហ្នឹង ស្ថិតនៅក្រោមស្ថាប័នណា?

**ឆ៖** ផ្សាររដ្ឋក្នុងស្ថាប័នក្រសួងការបរទេស។

[០៩:៤៣:៤៤]

**ស៖** តើផ្សាររដ្ឋហ្នឹងជាអ្វី? ជាកន្លែងធ្វើអីដែរ?

**ឆ៖** ផ្សាររដ្ឋ ជាកន្លែងប្រមូលផ្ដុំផល ដែលខាងក្រសួងការបរទេសដាំដុះដោយខ្លួនឯង បានបន្តិចបន្តួច និងទៅប្រមូលកន្លែងផ្សេងៗ ក្រសួងមន្ទីរផ្សេងៗ ដែលគេជួយដាំដុះដែរ ប្រមូលមកទុកមួយដុំ។ ហើយសាច់ជ្រូក សាច់គោអីហ្នឹង ទៅប្រមូលពីខាងក្រសួងអីផ្សេងៗមកទុកផ្ដុំ ដើម្បីចែកជូនដល់ភ្ញៀវបរទេស។ មិនមែនដូចផ្សារទំនើបយើងនេះទេ។

**ស៖** តើមានមនុស្សប្រហែលប៉ុន្មាននាក់ដែរ ដែលធ្វើការសម្រាប់ឲ្យក្រសួងការបរទេសនៅសម័យនោះ? គឺនិយាយចាប់ពីពេលដែលក្រសួងការបរទេសដំណើរការបានពេញលេញហើយ។ លោកអាចប្រហែលទេ អាចបង្ហាញពីចំនួនបុគ្គលដែលធ្វើការឲ្យក្រសួងនេះបានទេនៅសម័យនោះ?

**ឆ៖** សម័យនោះ បុគ្គលិកម៉ាល្មមធ្វើការងារបាន។ ប្រហែលជា១០០ ទៅ-- ១៥០ ទៅ ៣០០ បាទ។ អាហ្នឹងបុគ្គលិកដែលទាក់ទងនឹងផ្សារ។ រាប់តាំងពីអ្នកដាំដុះទៅ។ រាប់តាំងពីអ្នកដឹកជញ្ជូនអីទៅ។ មិនមែនផ្សារដោយឡែក ដោយផ្សារទេ កកើតជាផ្សារហ្នឹងមក គឺត្រូវតែប្រមូលផ្ដុំតាំងពីអ្នកដាំដុះ តាំងពីអ្នកដឹកជញ្ជូនទៅ ឧបត្ថម្ភផ្សារនុ៎ង។ កាលនុ៎ងគេមិនចាយលុយទេ។ ដូច្នេះផ្សារ កុំច្រឡំថាផ្សាររបៀបចាយលុយ។

[០៩:៤៦:៤៥]

**ស៖** សូមអរគុណ។ គឺលោកនិយាយថាប្រហែលជា១៥០ ទៅដល់៣០០នាក់ ដែលធ្វើការសម្រាប់ផ្សាររដ្ឋ។ ហើយអ្នកផ្សេងទៀត គឺធ្វើការនៅក្នុងមន្ទីរ ឬក៏អង្គភាពក្រោមចំណុះរបស់ក្រសួងការបរទេស។ ដូច្នេះលោកគិតថា តើប្រហែលប៉ុន្មានដែរ ទាំងអស់តែម្ដង ទាំងនៅប-១ ហើយនិងទាំងនៅក្រៅប-១ នោះ?

**ឆ៖** ខ្ញុំអត់មានស្ថិតិទេ។ អត់ដឹង។

**ស៖** ឥឡូវនេះខ្ញុំនិយាយអំពីទំនាក់ទំនងរវាងក្រសួងការបរទេស និងលោកប៉ង់។ ខ្ញុំព្យាយាមសង្ខេបអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញពាក់ព័ន្ធនឹង ប៉ង់ ហើយលោកឆ្លើយមកខ្ញុំថា តើត្រូវ ឬក៏ខ្ញុំច្រឡំ។ ខ្ញុំជឿថាលោកបានលើឡើងពីឈ្មោះ ប៉ង់ នេះជាច្រើនលើកច្រើនសា ហើយកាលពីម្សិលមិញនេះ។ លោកបាននិយាយថាគាត់ជាអ្នកដឹកនាំមួយរូបនៅមន្ទីរ៨៧០ ហើយគាត់ជាអ្នកចាត់តាំងលោកឲ្យទៅកាន់ក្រសួងការបរទេស។ ហើយបន្ទាប់មកទៀត លោកនិយាយថា គាត់ជាអ្នកជ្រើសរើសបុគ្គលិករបស់មន្ទីរប-១ ក្នុងចំណោមវណ្ណៈកសិករស្អាតស្អំ។ លោកបានបញ្ជាក់ថា នៅពេលដែល ប៉ង់

មកក្រសួងការបរទេស គាត់អាចធ្វើសេចក្ដីសម្រេចមួយចំនួនបាន ហើយជាពិសេសគាត់មកពេលដែល អៀង សារី អវត្តមាន។ លោកនិយាយថា បឹងត្របែក ស្ថិតនៅក្រោមឱវាទរបស់ ប៉ង់ មុនពេលដែលត្រូវបានផ្ទេរទៅឲ្យក្រសួងការបរទេសជាអ្នកគ្រប់គ្រង។ ហើយជាចុងក្រោយ នៅពេលបញ្ចប់សវនាការនោះ លោកបាននិយាយអំពីថា ប៉ង់ បានបញ្ជូនសមាជិកនៃគ្រួសារសាច់ថ្លៃរបស់លោកនោះទៅកាន់ក្រសួង។ ហើយបន្ទាប់មកគេចាប់ខ្លួន។

[០៩:៤៩:០៤]

តើអ្វីដែលខ្ញុំសង្ខេបនេះវាត្រឹមត្រូវតាមអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញពាក់ព័ន្ធនឹង ប៉ង់ ទេ ឬក៏លោកមានអីត្រូវបន្ថែម?

**ឆ៖** បាទត្រឹមត្រូវ។

**ស៖** ក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់ តើ ប៉ង់ រាយការណ៍ទៅអ្នកណា?

**ឆ៖** ខ្ញុំអត់ដឹងរាយការណ៍ទៅនរណាទេ។

**ស៖** បើតាមលោកដឹង តើ ប៉ង់ ជាសមាជិក ឬក៏ជាសមាជិកបម្រុងរបស់គណៈមជ្ឈិមដែរឬទេ?

**ឆ៖** អត់មានសេចក្ដីប្រកាស ខ្ញុំស្មាន ប្រហែលជាសមាជិកមជ្ឈិម។

**ស៖** បើតាមលោកដឹង តើ ប៉ង់ ជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងការសម្ងាត់របស់បក្សទេ។ ខ្ញុំអត់ដឹង។

**ស៖** កាលពីម្សិលមិញ ខ្ញុំបានអានចម្លើយរបស់លោក ហើយលោកបានបង្ហាញពីឈ្មោះមនុស្សមួយចំនួនដែលលោកជឿថាជាសមាជិកគណៈអចិន្ត្រៃយ៍ ប៉ុន្តែលោកមិនបានលើកអំពី ប៉ង់ ទេ។ ក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់ តើលោកដឹងទេថា ប៉ង់ ស្ថិតនៅក្រោមឱវាទរបស់គណៈអចិន្ត្រៃយ៍?

**ឆ៖** អត់បានប្រកាស ខ្ញុំស្មានថា ប្រហែល។

**ស៖** ឥឡូវនេះត្រឡប់មកនិយាយអំពីការងាររបស់ ប៉ង់ នៅក្រសួង។ ដូច្នេះ ខ្ញុំគិតថាលោកមានកាយស្រួលក្នុងការឆ្លើយ។ សំណួរសួរថា ហេតុអ្វីបានជា ប៉ង់ មកក្រសួងការបរទេស?

[០៩:៥១:៥៨]

**ឆ៖** បង់ មកក្រសួងការបរទេស មកម្ដងម្កាល ដូចជាត្រូវយកមនុស្សពីបរទេសម្នាក់ពីរនាក់អីទៅណាទៅណីអី ខ្ញុំមិនដឹងទេ។

**ស៖** តើគាត់មកញឹកញាប់ទេនៅក្រសួងការបរទេសហ្នឹង ដើម្បីនាំមនុស្សយកទៅហ្នឹង?

**ឆ៖** គាត់មកមិនញឹកញាប់ទេ។

**ស៖** តើលោកបានឃើញ ប៉ង់ ប៉ុន្មានដងនៅក្រសួងការបរទេស ដើម្បីមកយកមនុស្សចេញទៅនោះ? តើលោកអាចនឹកឃើញអំពីចំនួនដងដែលគាត់មកទេ?

**ឆ៖** ខ្ញុំនឹកឃើញដូចជាពីរដងទេ បាទ។

**ស៖** កាលពីម្សិលមិញលោកបាននិយាយថា ប៉ង់ អាចធ្វើសេចក្ដីសម្រេចបានដែរនៅក្រសួងការបរទេស។ តើវាជាប្រភេទនៃសេចក្ដីសម្រេចបែបណាដែរ? តើវាពាក់ព័ន្ធតែខាងផ្នែកសន្តិសុខ ឬក៏ពាក់ព័ន្ធនឹងផ្នែកអ្វីផ្សេងទៀត?

[០៩:៥៤:១៣]

**ឆ៖** ការងាររបស់ ប៉ង់ ខាងលើ ពិសេសបង អៀង សារី គ្រាន់តែប្រាប់ថា ប៉ង់ មករកអី ឲ្យមានសិទ្ធិបាន។ ឯផ្នែកដទៃទៀត ខ្ញុំអត់ដឹងទេ។ សិទ្ធិប៉ុនណាៗតទៀតទៅ-- តទៅ ខ្ញុំមិនដឹងទេ។

**ស៖** តើលោកអាចផ្ដល់ឈ្មោះមនុស្សដែលត្រូវបានគេ ប៉ង់ នាំចេញពីក្រសួងការបរទេសបានដែរឬទេ?

**ឆ៖** ជាច្រើននាក់ ដែល ប៉ង់ មិនមកផ្ទាល់សរសេរសំបុត្រមក ជូនកាលជួបខ្ញុំ ជួនកាលជួបលោក ជាម មកយកទៅ។ មនុស្សដែលខ្ញុំចាំ មានបងថ្លៃខ្ញុំមួយ ក្រៅពីនោះខ្ញុំភ្លេចឈ្មោះហើយ។

**ស៖** លោកបាននិយាយអំពីបងថ្លៃរបស់លោកកាលពីម្សិលមិញ ប៉ុន្តែខ្ញុំដូចជាមិនចាប់បានឈ្មោះទេ តើលោកអាចបញ្ជាក់អំពីឈ្មោះពេញរបស់បងថ្លៃរបស់លោកបានទេ តើគាត់មានឈ្មោះមួយ ឬក៏មានឈ្មោះច្រើន សូមលោកជួយបង្ហាញផង?

**ឆ៖** ខ្ញុំស្គាល់តែឈ្មោះមួយទេ គឺឈ្មោះ ហុង។

[០៩:៥៦:៣៧]

**ស៖** តើគាត់មានមុខងារអ្វីដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? តើគាត់ធ្វើការនៅក្រសួងការបរទេសតាំងពីដើមដំបូង ឬក៏គាត់ធ្វើការនៅកន្លែងណាផ្សេង?

**ឆ៖** ខ្ញុំដឹងប្រវត្តិគាត់ថា ជាគាត់អ្នកតស៊ូជើងចាស់មួយដែរ សម័យខ្ញុំ ក៏ប៉ុន្តែការតស៊ូនោះមិនដឹងនៅទីណាទេ ស្រាប់មកជួបគ្នាដែល ប៉ង់ យកមកផ្ញើនៅក្រសួងការបរទេសប្រហែលជាពីរបីថ្ងៃប៉ុណ្ណោះ។

**ស៖** តើគាត់ធ្វើការនៅស្រុក តំបន់ ឬក៏ភូមិភាគមុនពេលដែល ប៉ង់ ផ្ញើនៅក្រសួងការបរទេសនោះ។ បើសិនជាអ៊ីចឹងមែន តើលោកដឹងទេថាតើនៅស្រុក តំបន់ ឬក៏ភូមិភាគណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងស្រុកភូមិទេ ប៉ុន្តែខ្ញុំដឹងថាភូមិភាគ៣០៤។

[០៩:៥៨:២៩]

**ស៖** សូមអរគុណ។ តើបងថ្លៃរបស់លោក និងអ្នកផ្សេងទៀតដែលត្រូវបាននាំដោយ ប៉ង់ ឬក៏បុគ្គលិករបស់ប៉ង់ តើលោកបានឃើញពួកគេត្រឡប់មកវិញទេ បន្ទាប់មកនៅពេលក្រោយនោះ?

**ឆ៖** តែទៅពីក្រសួងការបរទេសហើយ គឺបាត់ហើយ។

**ស៖** ដូច្នេះមានន័យថា គេចាប់ខ្លួនពួកគាត់ ហើយបន្ទាប់មកសម្លាប់មែនទេ?

**ឆ៖** ខ្ញុំមិនដឹងទេ។

**ស៖** អម្បាញ់មិញនេះ លោកបានបញ្ជាក់ថា អៀង សារី បានផ្តល់សេចក្តីណែនាំថា ពេលដែល ប៉ង់ មកក្រសួងការបរទេសនោះត្រូវតែស្តាប់បង្គាប់ ប៉ង់។ តើមានន័យថា អៀង សារី បានដឹងថា ប៉ង់ មកនាំមនុស្ស តើអ៊ីចឹងមែនទេ?

[០៩:៥៩:៥៨]

**ឆ៖** ខ្ញុំអត់ដឹងទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

កាលពីម្សិលមិញខ្ញុំបានផ្តល់ឯកសារមួយជូនលោក គឺឯកសារលេខ D91/14។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានបញ្ចាំងឯកសារនេះនៅលើអេក្រង់ ហើយស្នើសុំឲ្យសាក្សីមើលនូវទំព័រជាភាសាខ្មែរ 00204097 ទៅដល់ 98, ជាភាសាបារាំង 00503936 រហូតដល់ទៅដល់ 37, ERN ជាភាសាអង់គ្លេស 00223593។

ដើម្បីឲ្យយើងទាំងអស់គ្នាបានដឹងច្បាស់នោះ គឺសំណួរចុងក្រោយដែលសួរដោយអ្នកស៊ើបអង្កេត នៅក្នុងកំណត់ហេតុនេះ គឺជាសំណួរមួយដែលមានចម្លើយយ៉ាងវែង។ ដូច្នេះខ្ញុំនឹងអានតែចម្លើយនេះមួយផ្នែកទេ ពីព្រោះថាមួយផ្នែកធំទៀតនោះមិនពាក់ព័ន្ធអ្វីទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយទំនងជាមន្ត្រីច្បាប់រកឯកសារអម្បាញ់មិញមិនឃើញទេ។ សូមតំណាងសហព្រះរាជអាជ្ញាអាចផ្តល់ឯកសារជាក្រដាស។ មានឃើញនូវ? អូខេៗ!

សម្រួលៗ ចង្អុលបង្ហាញចំណុចដែលព្រះរាជអាជ្ញាមានបំណងពិភាក្សាដេញដោលនាពេលនេះ ឲ្យគាត់បានឃើញភ្លាម។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេះ**

**ស៖** ខ្ញុំសូមសង្ខេបសំណួរ "សំណួរចង់ដឹងថា តើលោកមានបានកត់សម្គាល់ឃើញមានការបាត់ខ្លួនកម្មាភិបាល ឬក៏បុគ្គលិកក្នុងក្រសួងការបរទេសដែរឬទេ? ហើយតើអ្នកណាជាអ្នកចេញបញ្ជាឲ្យចាប់ខ្លួន? ហើយតើនៅពេលដែលគេចាប់ខ្លួននោះ អៀង សារី បានដឹងដែរឬទេ?" ហើយលោកក៏បានឆ្លើយដូចតទៅនេះ៖ ឃ្លាដំបូង "ខ្ញុំបានដឹងថា មានកម្មាភិបាល បុគ្គលិកបាត់ខ្លួនមែន ក៏ប៉ុន្តែខ្ញុំមិនដឹងថាគេយកទៅណាទេ ពីព្រោះបងប្អូនរបស់ខ្ញុំក៏បាត់ខ្លួនដែរ។ ខ្ញុំមានការព្រួយបារម្ភដែរ"។ បន្ទាប់មកទៀតនៅចុងបញ្ចប់លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ "ចំពោះអ្នកដែលគេមកយកមនុស្សនោះ គឺមានឈ្មោះ ប៉ង់។ ពេលដែលបាត់ខ្លួនកម្មាភិបាល បុគ្គលិករបស់ក្រសួង លោក អៀង សារី ក៏បានដឹងដែរ។ តែគាត់មិនបាននិយាយថា អ្វីទេ ខ្លួនគាត់ក៏ភ័យដែរ ហើយខ្ញុំក៏ភ័យដែរ"។

[១០:០៣:៥៤]

តើលោកនៅតែរក្សាចម្លើយនេះដដែលទេ? គឺមានន័យថា លោក អៀង សារី ក៏បានដឹងដែរ នៅពេលបុគ្គលិក ឬក៏កម្មាភិបាលរបស់ក្រសួងការបរទេសបាត់ខ្លួននោះ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំយល់ស្របតាមចម្លើយនេះ។ ប៉ុន្តែខ្ញុំសូមអត្ថាធិប្បាយបន្តិច។ ពាក្យថា "ដឹងដែរ" នេះគឺថា វាត្រូវតែដឹងហើយ ដល់តែបាត់ខ្លួនហើយបានដឹង។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះ តើលោកអាចបញ្ជាក់បានទេ? ថាតើចាប់ពីពេលណាដែល ប៉ង់ និងមនុស្សរបស់ ប៉ង់ មកក្រសួងការបរទេស ដើម្បីមកនាំកម្មាភិបាល ឬបុគ្គលិកក្រសួង ហើយរហូតដល់ពេលណា?

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការផ្តល់-- អស់ថ្មមើលទៅ!

អញ្ជើញតាំងសំណួរសាជាថ្មីម្តងទៀត ទំនងភ្លេច មិនចាំទេ ព្រោះមានបញ្ហាឧបករណ៍ស្តាប់សំឡេងរបស់មេធាវីប្រឹក្សាសាក្សី។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្តាឯល៖**

**ស៖** សូមអរគុណលោកប្រធាន ខ្ញុំសួរថា ចង់ដឹងថា តើចាប់ពីពេលណាដែល ប៉ង់ និងមនុស្សរបស់ ប៉ង់ បានមកក្រសួង ដើម្បីនាំមនុស្សចេញទៅ ឬក៏មកចាប់ខ្លួន? ហើយបន្តរហូតដល់ពេលណាដែរ? គឺមានន័យថាចាប់ពីខែណា ឆ្នាំណា? រហូតដល់ខែណា? ឆ្នាំណា ដែលបានមកហើយចាប់ខ្លួនយកទៅនោះ?

[១០:០៦:៣០]

**លោក សាឡុត បាន៖**

**ឆ៖** គឺនៅពេលដែល ប៉ង់ បាត់ខ្លួន នៅពេលដែលវៀតណាមចូលស្រុក។ តាមខ្ញុំដឹងប្រហែលជាវៀតណាមបុកមកដល់ក្រចេះ សម័យនុំងប្រហែលដល់ក្រចេះ ហើយនិងតាកែវ បាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេថាតើ ប៉ង់ មកនាំមនុស្សជាលើកដំបូងនៅពេលណា?

**ឆ៖** ប៉ង់ នាំមនុស្សមកលើកដំបូងប្រហែលជាមួយខែ ឬពីរខែមុនវៀតណាមចូលស្រុក។

**ស៖** អម្បាញ់មិញលោកបាននិយាយថា ប៉ង់ មកម្តងម្កាលនៅក្រសួងការបរទេស ហើយមាននាំមនុស្សជាច្រើនចេញទៅ ចួនកាលគាត់មកនាំដោយខ្លួនឯង ឬក៏មនុស្សរបស់ ប៉ង់។ តើលោកច្បាស់ទេអំពីអ្វីដែលលោកបាននិយាយអម្បាញ់មិញនេះថា ប៉ង់ ចាប់ផ្តើមមកៗក្រសួងនោះ គឺមុនពេលដែលវៀតណាម-- មួយខែពីរខែ ដែលមុនពេលវៀតណាមចូលមកទីក្រុងភ្នំពេញ? តើលោករក្សាចម្លើយនេះដដែល?

*(សាក្សីពិភាក្សាជាមួយមេធាវី)*

**ឆ៖** បាទ ខ្ញុំអត់ច្បាស់ទេ។

[១០:០៩:១០]

**ស៖** នៅពេលដែល ប៉ង់ មកក្រសួង តើគាត់តែងតែមានឡាន ហើយនិងមានមនុស្សរបស់គាត់សម្រាប់មកនាំអ្នកនៅក្រសួងចេញ ឬក៏គេប្រើឡានរបស់ក្រសួងផ្ទាល់តែម្តង ដើម្បីមកនាំមនុស្សដែលត្រូវចាប់ខ្លួននោះ?

**ឆ៖** គាត់ប្រើម៉ូតូ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីប្រឹក្សាសាក្សី សូមលោកអនុវត្តភារកិច្ចរបស់លោក ក្នុងកម្រិតមួយដែលនៅសំណួរ

ឯណា ដែលមានខ្លឹមសារ បំណងឲ្យសាក្សីឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ឬក៏ធ្វើអំណះអំណាងដាក់ពិរុទ្ធភាពលើខ្លួនប៉ុណ្ណោះ។ ចំណែកខ្លឹមសារដទៃទៀត ទុកឲ្យសាក្សីជាអ្នកសម្រេច។ ប្រសិនជាមិនច្បាស់ គាត់អាចប្រាប់មកយើង ដើម្បីយើងប្រាប់ទៅដល់អ្នកតាំងសំណួរឲ្យសួរសាជាថ្មី។ យើងបានអនុវត្តដូច្នេះ កន្លងមកហើយ។ ចៀសវាងមានការភ័ន្តច្រឡំ ពីព្រោះគាត់ចូលរួមនៅក្នុងកិច្ចដំណើរការនេះ មិនមែនក្នុងនាមគាត់ជាជនជាប់ចោទទេ គឺក្នុងនាមជាសាក្សី ហើយគាត់មានសិទ្ធិមិនឆ្លើយតបទៅសំណួរ ឬក៏ឲ្យគាត់ធ្វើអំណះអំណាង ឬអត្ថាធិប្បាយណាមួយដែលដាក់ពិរុទ្ធភាពលើខ្លួនឯង។ ដោយសារក្រែងបារម្ភលើខ្លឹមសារនៃទម្ងន់ សំណួរ ឬក៏អំណះអំណាងដែលសុំឲ្យគាត់ធ្វើហ្នឹង ក្រែងលោវាស៊ីជម្រៅ គាត់យល់មិនបាន ទើបចាត់តាំងមេធាវីប្រឹក្សា ដើម្បីឲ្យសម្របសម្រួលពិភាក្សាលើបញ្ហានេះ។ បញ្ចៀសនូវការរំលោភសិទ្ធិជនជាប់ចោទ-- អ៎ រំលោភសាក្សីមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងប៉ុណ្ណោះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តការសួរដេញដោល។

[១០:១១:២៤]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំមិនចង់ដឹងអំពីមធ្យោបាយធ្វើដំណើររបស់ ប៉ង់ ទេ។ ខ្ញុំចង់ដឹងថាតើគេប្រើមធ្យោបាយដឹកជញ្ជូនអ្វីសម្រាប់នាំអ្នកដែលចាប់ខ្លួននៅក្រសួងការបរទេសចេញទៅនោះ? តើជាយានជំនិះរបស់មន្ទីរ៨៧០ ឬក៏យានជំនិះរបស់ក្រសួងការបរទេស? ដូចដែលលោកបាននិយាយអម្បាញ់មិញនេះថា ត្រូវតែស្តាប់បង្គាប់ ប៉ង់ នៅពេលដែល ប៉ង់ មក។ តើមានប្រើក្រសួង-- ឡានរបស់ក្រសួងដើម្បីដឹកអ្នកដែលចាប់ខ្លួនហ្នឹងដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** អត់មានប្រើឡានក្រសួងទេ គឺគាត់មកម៉ូតូ ហើយក៏ឲ្យសំបុត្រទៅ ថាយកមនុស្សនេះមនុស្សនោះ ទៅ។ គេប្រើពាក្យថា “ទៅរៀនសូត្រ ទៅធ្វើការងារនៅការដ្ឋាននេះ ការដ្ឋាននោះ” ក៏ឲ្យជិះម៉ូតូទៅ ប៉ុនអ្នកតាមក្រោយទៅ ប៉ង់ ក៏យកទៅ។ ពាក្យថា “ច្រើនៗ” នេះ គឺម្តងមួយៗ អ៊ីចឹង ដោយម៉ូតូ មិនមានឡានទេ។

[១០:១៣:៣១]

**ស៖** អម្បាញ់មិញ លោកនិយាយអំពីលិខិតដែលបញ្ជាក់អំពីការនាំមនុស្សទៅអប់រំ។ តើលោកមានធ្លាប់ឃើញសំបុត្របែបហ្នឹងទេ? ហើយអ្នកណាជាអ្នកចុះហត្ថលេខាលើសំបុត្របែបនេះ?

**ឆ៖** ជួនកាល ប៉ង់ មក គឺអត់មានសំបុត្រទេ ប៉ង់ យកទៅ។ ពេលណា ប៉ង់ មិនមក មានកម្មាភិបាលក្រោមៗរបស់ ប៉ង់ សរសេរស៊ីញេ ប៉ង់ មក។

**ស៖** សូមអរគុណ។ ច្បាស់ហើយចំពោះពេលនេះ។ កាលពីម្សិលមិញ លោកបាននិយាយថា ប៉ង់ មកក្រសួងការបរទេស នៅពេល អៀង សារី អវត្តមាន។ តើប៉ង់ មានទំនាក់ទំនងដោយផ្ទាល់ជាមួយ អៀង សារី ដែរទេ-- ដែរឬទេ? ពួកគេអាចទាក់ទងគ្នាតាមមធ្យោបាយណាមួយ ឬក៏លោកធ្លាប់ឃើញពួកគេទាំងពីរនាក់នេះ ជួបប្រជុំគ្នា នៅក្រសួង? ឬក៏នៅមន្ទីរក-១? ឬក៏នៅមន្ទីរណាផ្សេងទៀត?

**ឆ៖** ប៉ង់ គ្មានការទាក់ទងជាផ្លូវការរបស់បក្សជាមួយ អៀង សារី ទេ។ ប៉ង់ ទាក់ទងតែការងារបច្ចេកទេស ដែលត្រូវទាក់ទងជាមួយបង អៀង សារី។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ D91/15។ ដែលបានប្រគល់ បង្ហាញជូនសាក្សីកាលពីព្រឹកមិញ។ ហើយសូមអនុញ្ញាតបង្ហាញឯកសារនេះ ថាលេខ ERN ជាភាសាខ្មែរ 00204100 ជាភាសាបារាំង 00524353 ទៅដល់ 54, ជាភាសាអង់គ្លេស 00223595 រហូតដល់ 96។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

ចាំ រង់ចាំមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលរកត្រង់ទំព័រដែលលោកមានបំណងដេញដោលសិន សូមចាប់ផ្តើមដេញដោលដល់សាក្សី។

[១០:១៧:៣៥]

ឯកសារនោះទំនងជាមិនមានទេ មានទេ? ឯកសារ D9115 ទំនងជាមិនទាន់មានទេ ព្រឹកមិញគឺ 9114 ទេ។ សូមឲ្យតំណាងសហព្រះរាជអាជ្ញាផ្តល់ឯកសារជាក្រដាសឲ្យដល់សាក្សីតាមរយៈមន្ត្រីរដ្ឋបាលតុលាការ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ ខ្ញុំច្រឡំ តាមពិតខ្ញុំមិនទាន់បានផ្តល់ឯកសារហ្នឹងទៅសាក្សីទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** នេះគឺជាសំណួរទីពីរនៃឯកសារហ្នឹង។ ជាកំណត់ហេតុចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៧។

សំណួរដែលសួរទៅលោកនោះគឺថា "សូមបញ្ជាក់បន្ថែមចំពោះមន្ត្រីទូតដែលហៅត្រឡប់មកវិញ ដូចជា ហួត សម្បត្តិ, មាឃ ទូច ហៅ កែម, តូច ខាំឌឿន និង អ៊ិន លន ហៅ ណាត ជាដើម។ អ្នកទាំងនេះក្រោយមកត្រូវបានចាប់ខ្លួន ហើយឃុំខ្លួននៅមន្ទីរស-២១ តើលោកអាចបញ្ជាក់បានឬទេ?" ហើយលោកបានឆ្លើយ "ឈ្មោះទាំងនេះ ខ្ញុំដឹង លើកលែងតែឈ្មោះ ហួត សម្បត្តិ ដែលខ្ញុំមិនដឹងទេ។ ហើយខ្ញុំមិនដឹងថាគេយកអ្នកទាំងនោះទៅកន្លែងណាទេ។ ការសម្រេចគឺគណៈអចិន្ត្រៃយ៍ គឺក្រុមលោក ប៉ង់ នៅមន្ទីរមជ្ឈិម៨៧០ គេជាអ្នកនាំយកទៅ គឺគាត់ទាក់ទងផ្ទាល់ជាមួយនឹងលោក អៀង សារី។ ចំណែកខ្ញុំមិនបានដឹងទេ"។

[១០:២០:០៤]

បាទ ខ្ញុំសូមសួរលោក ថាតើលោកបញ្ជាក់ថា ប៉ង់ មានទំនាក់ទំនងផ្ទាល់ជាមួយ អៀង សារី ដែរឬទេ ទាក់ទងទៅនឹងការមនុស្សដែល ប៉ង់ នាំទៅក្រសួងការបរទេស?

**ផ៖** ក្នុងខនេះ ខ្ញុំសូមបដិសេធពាក្យ "ការសម្រេចចិត្តគណៈអចិន្ត្រៃយ៍" លុបចោល បាទ។ ពីមុនមកអាចខ្ញុំភ័ន្តច្រឡំពាក្យពេចន៍អី ហើយខ្ញុំឈឺ ខ្ញុំមិនសូវបានមើលឲ្យត្រឹមត្រូវទេ។ ពេលនេះខ្ញុំសូមបដិសេធពាក្យហ្នឹង។ បញ្ហានេះមិនដឹងជាការសម្រេចរបស់ពីណាទេ។ ឃើញក្រុម ប៉ង់ មក, បង អៀង សារី គាត់មិនដឹងដែរ អត់ដឹងទេ។ បាទ មិនដឹងជាយ៉ាងណាទេបាទ។

**ស៖** លោកសាក្សីអម្បាញ់មិញនៅក្នុងឯកសារ D91/14 ដែលខ្ញុំបានអានជូនលោក លោកបានឆ្លើយថា លោករក្សាចម្លើយរបស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេតថា "នៅពេលដែលកម្ម-ភិបាលនៃក្រសួងបាត់នោះ លោក អៀង សារី ដឹង ហើយលោកក៏ដឹងដែរ" តើនេះមិនមែនជារឿងផ្ទុយគ្នានឹងអ្វីដែលលោកទើបតែនឹងលើកឡើងអម្បាញ់មិញនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតបទៅនឹងសំណួរ! ដោយមានការលើកឡើងជំទាស់-- អ៎! ងើបឡើងជំទាស់តវ៉ាពីមេធាវីការពារក្ដីលោក អៀង សារី។ សូមអញ្ជើញលោកមេធាវីការពារក្ដី លោកអៀង សារី!

[១០:២២:២៧]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្ដីលោកប្រធាន លោក លោកស្រីចៅក្រម។ សូមអធ្យាស្រ័យដែលខ្ញុំកាត់នៅត្រង់នេះ ក៏ប៉ុន្តែខ្ញុំជឿថា សហព្រះរាជអាជ្ញាកំពុងតែព្យាយាមធ្វើឲ្យសាក្សីយល់ច្រឡំ ឬក៏មិនយុត្តិធម៌ចំពោះ

សាក្សី។ សំណួរដែលសួរខាងដើមទៅដល់សាក្សីនោះ គឺថាអ្នកណាធ្វើសេចក្ដីសម្រេច? ដូច្នេះសំណួរនេះ គឺចង់សួរថា ហើយគឺចង់បញ្ជាក់ទៅលើគណៈអចិន្ត្រៃយ៍។ សាក្សីបានកែចម្លើយនោះរួចទៅហើយ។ នៅពេលនេះគឺសហព្រះរាជអាជ្ញាព្យាយាមតទល់ជាមួយនឹងសាក្សី ដើម្បីបញ្ជាក់ថា សាក្សីមិនប្រាប់ការពិតដោយផ្អែកទៅលើចម្លើយដែលគាត់ឆ្លើយមុនៗ។ សេចក្ដីប្រកាសមុនៗ គឺសាក្សីបាន-- តើបានដឹងដែរឬទេថាគេមាននាំបុគ្គលចេញទៅខាងក្រៅ? ហើយបន្ទាប់មក គឺនៅពេលនេះសហព្រះរាជអាជ្ញាសួរថា តើនរណាគេជាអ្នកសម្រេចទៅលើបញ្ហាហ្នឹង?

ហេតុដូច្នេះហើយ ខ្ញុំយល់ឃើញថា សំណួរដែលសួរដោយសហព្រះរាជអាជ្ញា គឺមិនមានភាពយុត្តិធម៌ និងធ្វើឲ្យសាក្សីយល់ច្រឡំ។ ប្រសិនបើគាត់នៅសួរដដែលដូច្នេះ ខ្ញុំនឹងជំទាស់ទៅលើការសួរសំណួរបែបនេះ។ សូមអរគុណ។

[១០:២៣:៣៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

បាទ ខ្ញុំយល់ការលើកឡើងរបស់មេធាវី កាណាវ៉ាស លោកប្រធាន។ ខ្ញុំគិតថាមានភាពស្រពេចស្រពិលនៅពេលដែលសាក្សីបានលើកឡើងថា អៀង សារី មិនដឹង ហើយគាត់មិនដឹងពីសេចក្ដីសម្រេចចិត្តលើការចាប់ខ្លួន។ បាទ ឥឡូវនេះ ខ្ញុំសូមបន្តទៅមុខទៀត ហើយខ្ញុំចោទសំណួរផ្សេងទៀត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

**ស៖** លោកសាក្សី លោកបានលុបឃ្លាមួយក្នុងចម្លើយរបស់លោក។ ក៏ប៉ុន្តែលោកពុំបានឆ្លើយទៅសំណួរដែលថា "តើ ប៉ង់ មានទំនាក់ទំនងជាមួយ អៀង សារី ដែរឬអត់នោះទេ?"។ លោករក្សាចម្លើយនេះ តែលោកបដិសេធទាក់ទងនឹងការសម្រេច-- សេចក្ដីសម្រេច។ តើ-- ឥឡូវខ្ញុំសួរម្ដងទៀត តើ ប៉ង់ មានទំនាក់ទំនងផ្ទាល់ជាមួយលោក អៀង សារី ទាក់ទងទៅនឹងការចាប់ខ្លួន ឬក៏ការនាំយកបុគ្គលិកចេញពីក្រសួងការបរទេសដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតបនឹងសំណួរ!

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំស្នាក់ស្ទើរក្នុងការតាំង-- ជំទាស់ទៅនឹងការសួរសំណួរបែបនេះ ដោយសារដើម្បីខ្ញុំការពារ

ប្រយោជន៍របស់កូនក្តីរបស់ខ្ញុំ។ យើងដឹងហើយថា មានការជំទាស់ជាច្រើនកាលពីសប្តាហ៍មុនពីខាងសហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះបានតម្កល់ការជំទាស់ទាំងអស់នោះ។ នៅពេលនេះ សំណួរដែលបានសួរដោយសហព្រះរាជអាជ្ញា ខ្ញុំជឿថាសួរបីដងហើយ។ ដូច្នេះហើយ ខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការសម្រេចឲ្យមានភាពយុត្តិធម៌ សម្រាប់ទាំងភាគីសងខាង បើសិនមិនដូច្នេះទេ គឺវាមានភាពយុត្តិធម៌តែភាគីម្ខាង។ ដូច្នេះអ្វីដែលសហព្រះរាជអាជ្ញាសួរនោះ គឺវាហាក់ដូចជាមិនទំនងជាត្រឹមត្រូវ ហើយមានភាពយល់ច្រឡំ។ គួរតែសួរឲ្យច្បាស់លាស់ ហើយថាតើចំណុចណាដែលសហព្រះរាជអាជ្ញា គាត់មិនយល់ច្បាស់។ ដូច្នេះគាត់ត្រូវតែសួរចំណុចនោះឲ្យបានច្បាស់ បើសិនមិនដូច្នេះទេ សំណួរដែលគាត់សួរនោះគឺមិនច្បាស់លាស់នោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាមានអីតបវិញទេ!

[១០:២៦:២០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សំណួរខ្ញុំអម្បាញ់មិញនេះ ខ្ញុំសួរច្បាស់លាស់ហើយ ខ្ញុំសួរសំណួរមួយទាក់ទង ថាដែលចង់ដឹងថា តើ ប៉ង់ មានទំនាក់ទំនងផ្ទាល់ជាមួយ អៀង សារី ដែរឬអត់ទាក់ទងនឹងការចាប់ខ្លួន--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសួរថា តើលោកតបនឹងអ្វីដែលជំទាស់ដោយមេធាវីការពារក្តីនេះដែរឬទេ? លោកតបទេ?អំមិញលោកតាំងសំណួរ តំណាងសហព្រះរាជអាជ្ញាបានលើកសេចក្តីជំទាស់របស់ខ្លួន។ សំណួរសួរថា តើលោកមានតបទៅនឹងសេចក្តីជំទាស់របស់តំណាង-- របស់មេធាវីអន្តរជាតិការពារក្តី អៀង សារី ដែរឬទេ? ដើម្បីឲ្យអង្គជំនុំជម្រះនឹងសម្រេចអំពីបញ្ហានេះជាមុន មុននឹងផ្តល់ពេលវេលាទៅឲ្យសាក្សីឆ្លើយតប ឬក៏មិនឲ្យឆ្លើយតបទៅនឹងសំណួរ។ មិនមែនឲ្យលោកសួរឡើងវិញទេ។

[១០:២៧:២៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធានបាទ។ ខ្ញុំមិនព្យាយាមរៀបសំណួរនេះឡើងវិញទេ គ្រាន់តែចង់និយាយថា សំណួរដែលខ្ញុំបានចោទពីដើមនោះ មិនបានទទួល មិនមានការឆ្លើយច្បាស់លាស់នោះទេ គ្រាន់តែគាត់បានបញ្ជាក់អំពី រក្សាអំពីអ្វីដែលគាត់បានឆ្លើយពីមុន ដោយលុបឃ្លាមួយចោល ហើយខ្ញុំគ្រាន់តែ

ចង់សួរបញ្ជាក់ ចង់បានការបញ្ជាក់ពីគាត់តែប៉ុណ្ណោះអំមិញនោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២៨:៥៤]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក អៀង សារី គ្មានប្រសិទ្ធភាព។ សាក្សីអាចឆ្លើយ-- ត្រូវឆ្លើយនឹងសំណួរដែលសួរអម្បាញ់មិញដោយតំណាងសហព្រះរាជអាជ្ញា ប្រសិនបើលោកនូវចងចាំសំណួរ ប្រសិនបើជាលោកមិនចងចាំទេ សូមឱ្យតំណាងសហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរចុងក្រោយអម្បាញ់មិញនេះសាជាថ្មី។

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំនៅមានការចងចាំ។ សំណួរលើកមុន ខ្ញុំបានឆ្លើយប្រាប់ថាលោក អៀង សារី ដឹងដឹងនៅពេលដែល ប៉ង់ ចាប់ហើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីចាំស្តាប់សំណួរចុងក្រោយ ចុងក្រោយណ៎ះ ចុងក្រោយអម្បាញ់មិញបានសួរបញ្ជាក់ពីព្រោះវាមានបញ្ហាភាពមិនច្បាស់លាស់ ដើម្បីញែកឱ្យបានច្បាស់លាស់លើបញ្ហានេះ រួមទាំងដែលលោកឆ្លើយតបនេះ ហើយទំនងជាប្រៀបធៀបជាមួយនឹងសំណោរដែលមាននៅក្នុងឯកសារ D91/15 អម្បាញ់មិញនេះដែលវាមានបញ្ហា។ អ៊ីចឹងហើយបានជាសួរបញ្ជាក់ឱ្យបានច្បាស់ សូមលោកចាំស្តាប់សំណួរសាជាថ្មីម្តងទៀត ហើយឆ្លើយតបនឹងសំណួរ។ ហើយសូមសម្រួលអារម្មណ៍ឱ្យបាននឹងនរ ឱ្យបានស្ងប់ដើម្បីឆ្លើយតបនឹងសំណួរ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

[១០:៣០:៤៣]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សំណួរខ្ញុំ គឺចង់ដឹងថា តើលោករក្សាចម្លើយរបស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលថា ប៉ង់ មានទំនាក់ទំនងផ្ទាល់ជាមួយលោក អៀង សារី? ហើយទំនាក់ទំនងផ្ទាល់ជាមួយ

លោក អៀង សារី នេះគឺនិយាយអំពីអ្វី? ប្រធានបទអ្វីដែរ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំបានជម្រាបជូនរួចហើយ ប៉ង់ មកទាក់ទងនឹងលោក អៀង សារី គឺជាបញ្ហាអ្វីផ្សេងៗទេ តែជាការប្រជុំឲ្យទៅតាម ជាការប្រជុំក្នុងក្របខ័ណ្ឌនយោបាយអីធំៗ គឺអត់មានទេ។

[១០:៣១:៥៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសមល្មម សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសម្រាប់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅក្នុងអំឡុងពេលឈប់សម្រាកនៅបន្ទប់សម្រាប់សម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅពេលវេលាដែលបានកំណត់ គឺម៉ោងដប់មួយខ្វះដប់នាទី។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាពថ្ងៃនេះលោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ប៉ុន្តែសូមចូលរួមដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

[១០:៣២:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍ដោយមានមូលហេតុសុខភាពមិនអាចអង្គុយតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់បានយូរ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ លះបង់សិទ្ធិក្នុងការចូលកិច្ចដំណើរការសវនាការរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ច

ដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេល នេះទៅរហូតដល់ចប់សវនាការនេះ នៅសម្រាប់ថ្ងៃនេះ។

[១០:៣៣:៤៥]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី អៀង សារី ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដែលចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃដោយលោក អៀង សារី និងបង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ដែលរៀបចំទុកជាស្រេចឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៤ នាទី ដល់ម៉ោង ១០:៥៣នាទី)*

[១០:៥៣:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចនីតិវិធីសវនាការ និងសូមផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលជាបន្តចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

ម៉េចទៅមានបញ្ហាបកប្រែទៀតហើយ? ឮទេ? អ្នកបកប្រែស្តាប់បានទេ?

**អ្នកបកប្រែ៖**

ស្តាប់បានលោកប្រធាន។

[១០:៥៤:៣០]

*(មានបញ្ហាបច្ចេកទេសសំឡេង)*

[១១:០៣:១០]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដោយសារមានព័ត៌មានដែលផ្ដល់ឡើងដោយ--

**អ្នកបកប្រែ៖**

*(អ្នកបកប្រែធ្វើតេស្ដមីក្រូហ្វូន)*

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៤:៤៨]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដោយសារមានបញ្ហារអាក់រអួលបច្ចេកទេសប្រព័ន្ធសំឡេង ដែលមិនអាចដំណើរការបកប្រែភាសា ជាពិសេសគឺគ្មានការបកប្រែជាទៅជាភាសាអង់គ្លេស ហើយអ្នកបច្ចេកទេសបានប្រមើលមើលថា ការចំណាយពេលវេលាអាចសាមសិប ទៅសែសិបនាទីឯណោះ ទើបអាចរៀបចំឲ្យមកប្រក្រតីភាពឡើងវិញ។ ដោយសារពេលវេលាក៏សមល្មមនឹងសម្រាកអាហារថ្ងៃត្រង់ហើយដែរ ប្រសិនបើ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចប្រកាសសម្រាកសម្រាប់កិច្ចដំណើរការសវនាការព្រឹកនេះ ត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅរសៀល ចាប់ពីម៉ោងមួយសាមសិបនាទី។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកសមរម្យមកដល់សាក្សី ហើយនិងមេធាវីប្រឹក្សារបស់គាត់ផង នៅក្នុងអំឡុងពេលសម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។ ហើយអនុរក្ស--

ឥឡូវនេះ បាទ សូមអញ្ជើញលោកស្រីចៅក្រម!

[១១:០៦:១៣]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៌៖**

សូមអរគុណលោកប្រធាន។ យើងឃើញថាមានបញ្ហាបច្ចេកទេសខាងបកប្រែភាសាអង់គ្លេស ដូច្នេះ ដូចដែលលោកប្រធានបានជម្រាប យើងនឹងចំណាយពេលមួយចំនួន ដើម្បីជួសជុលទៅលើបច្ចេកទេសទាំងអស់នេះ។ ដូច្នេះហើយ យើងធ្វើការសម្រាកអាហារថ្ងៃត្រង់មុនបន្តិច ហើយយើងនឹងត្រឡប់មកវិញនៅម៉ោងមួយសាមសិបនាទី។ ហើយលោកប្រធានបង្គាប់ឲ្យមានការនាំជនជាប់ចោទ

រួមទាំងសាក្សីត្រឡប់មកវិញ ទៅតាមទម្លាប់ដែលយើងធ្លាប់ធ្វើ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមិនដឹងថា តើអ្វីដែលខ្ញុំនិយាយនេះ អាចបកប្រែបានដែរឬទេ នោះទេ? ក៏ប៉ុន្តែខ្ញុំសូមធ្វើសូមសំណើ សុំឲ្យកូនក្តីរបស់ខ្ញុំនេះ ទៅតាមដានសវនាការតាមបន្ទប់រង់ចាំខាងក្រោម សម្រាប់រយៈពេលថ្ងៃនេះដែលនៅសល់។ យើងខ្ញុំនឹងដាក់ជូនលិខិតបោះបង់សិទ្ធិនេះ ជូនអង្គជំនុំជម្រះតាមក្រោយ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលពេញមួយរសៀលនេះ។ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ច-- ផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយក្រុមមេធាវីការពារក្តីសន្យារថា នឹងប្រគល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេញមួយរសៀលនេះ។ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ។

[១១:០៨:៣១]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយចុះហត្ថលេខា ឬផ្តិតស្រាមមេដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការរសៀលនេះ។ ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួន

ខាងក្រោម ដោយរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីប្រព័ន្ធសោតទស្សន៍ និងដោយឡែកឲ្យនាំលោក ខៀវ សំផន មកកាន់បន្ទប់សវនាការវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:០៩ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនឹងប្រគល់វេទិកាទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយមុននឹងប្រគល់ និងដំណើរការ អង្គជំនុំជម្រះសូមឲ្យតំណាងសហព្រះរាជអាជ្ញា តើខាងក្រុមរបស់លោកហ្នឹងត្រូវការចំណាយពេលវេលាប៉ុន្មានទៀត ក្នុងការសួរដេញដោលសាក្សីរូបនេះ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្លាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់ អម្បាញ់មិញនេះខ្ញុំចង់ជម្រាបអង្គជំនុំជម្រះពីពេលវេលានេះឯង ពីព្រោះថាកាលពីព្រឹកមិញយើងមានការយឺតយ៉ាវ ដោយសារមានបញ្ហាបច្ចេកទេស។ ដូច្នេះ ខ្ញុំគិតថាយើងមិនអាចនិយាយអំពីចំណុចទាំងអស់ជាមួយនឹងសាក្សីនៅថ្ងៃនេះទៀតទេ។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះក្នុងការបន្តនៅថ្ងៃស្អែក វេលាព្រឹកស្អែក ហើយខ្ញុំព្យាយាមសង្ខេបៗ។ ក៏ប៉ុន្តែដោយសារយើងទៅមុខមិនបានលឿន ដូច្នេះអ្វីដែលយើងអាចនិយាយបាននៅពេលនេះ គឺថាយើងត្រូវការពេលព្រឹកស្អែកមួយព្រឹកទៀត ហើយគឺថាយ៉ាងយូរបំផុតគឺថា ដល់ម៉ោង១២ថ្ងៃត្រង់ ហើយយើងពីដើមមកជាមួយដើមបណ្តឹងរដ្ឋប្បវេណី គឺថាយើងគិតថាយើងត្រៀមពីរថ្ងៃ ដែលលើពីរថ្ងៃកន្លះហ្នឹង ហើយខាងភាគីដើមបណ្តឹងរដ្ឋប្បវេណីគាត់យកកន្លះថ្ងៃ គឺថាពេលព្រឹកថ្ងៃទីបី។

[១៣:៣២:៤៣]

បើសិនជាសំណើរបស់ខ្ញុំអនុញ្ញាតអំពីអង្គជំនុំជម្រះ គឺថាពេលវេលារបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនោះគឺថា ពេលវេលាមិនមានការអូសបន្លាយ ពន្យារទៀតទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតតាមសំណើសុំទេ។ តែអង្គជំនុំជម្រះនឹងសងវិញនូវពេលវេលាមួយម៉ោង ដែលមានការរអាក់រអួលដោយបញ្ហាបច្ចេកទេសប៉ុណ្ណោះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ខ្ញុំសូមបន្តចោទសំណួរទៅសាក្សី។

**ស៖** លោកសាក្សី កាលពីព្រឹកមិញលោកបាននិយាយអំពីការដែលថាលោកជា-- ដែលថាសមាជិកគ្រួសារថ្លៃរបស់លោក-- បងថ្លៃរបស់លោកនោះត្រូវបញ្ជូនទៅក្រសួងជាបណ្ដោះអាសន្ន ហើយក្រោយមកទៀតត្រូវបានចាប់ខ្លួនដោយ ប៉ង់។ ខ្ញុំសូមបំភ្លឺចំណុចនេះ។ ខ្ញុំសូមយោងទៅលើឯកសារD234/2 ដែលជាកំណត់ហេតុស្ដាប់ចម្លើយរបស់លោក ដែលលោកមានហើយ ហើយសូមអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញឯកសារនេះជូនទៅដល់សាក្សី គឺនៅសំណួរចុងក្រោយគេបំផុត។ ហើយសូមបញ្ចាំងនៅអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលបង្ហាញនូវចំណុចដែល--

**អ្នកបកប្រែ៖**

សូម អ្នកបកប្រែសូមកែប្រែលោកប្រធាន លេខឯកសារអម្បាញ់មិញនេះ គឺ D233/2 មិនមែន 234ទេ។

[១៣:៣៥:៥៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណ ខ្ញុំមិនអានវគ្គនេះទាំងស្រុងទេ គឺជាសំណួរទាក់ទងទៅនឹងការប្រជុំនៅក្រសួងការបរទេស ដែលលោកបានចូលរួមជាមួយលោក អៀង សារី។ ហើយដែលនិយាយអំពីការបោស

សម្អាតផ្ទៃក្នុង។ នេះជាសំណួរដែលគេបានចោទទៅលោក ហើយលោកបានឆ្លើយទៅនឹងសំណួរនេះ គឺថានៅចំកណ្តាលចម្លើយរបស់លោក "នៅក្នុងកិច្ចប្រជុំនេះ ខ្ញុំមិនដែលចោទប្រកាន់ទៅអ្នកទេ ហើយលោក អៀង សារី ក៏មិនដែលចោទប្រកាន់ទៅអ្នកណាដែរនៅក្រសួងការបរទេស។ មានតែអ្នកមកពីក្រៅទេ ដែលធ្លាប់ចោទប្រកាន់មកក្រសួងការបរទេសដូចជាគ្រូខ្ញុំពីដើមឈ្មោះ វ៉ាញ ហើយឈ្មោះដើម ជា ហួន ជាគណៈភូមិភាគពាយ័ព្យដែលបានផ្លាស់មកធ្វើការនៅក្រសួងការបរទេសក្រោយមកត្រូវគេចាប់ខ្លួនបាត់ ហើយមួយទៀតគឺឈ្មោះ ឃឹម ជាលេខាស្រុកនៅក្នុងតំបន់ក្រចេះត្រូវជាបងរបស់ប្រពន្ធខ្ញុំត្រូវមកធ្វើការនៅក្រសួងការបរទេស ហើយគាត់ក៏ត្រូវបានគេចាប់ខ្លួនដែរ។ ហើយករណីដូចគ្នាដែរ គឺលោក មាឃ ទូច ហៅ កែម នេះដែលបញ្ជូនវគ្គ ដូចជាលោក តូច ភឿន, តូច ខាំឌឿន, អ៊ិន សូកាន ជាដើម"។ ខ្ញុំសូមបញ្ចប់សម្រង់ត្រង់នេះ។

[១៣:៣៧:៣២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯលះ**

**ស៖** សំណួររបស់ខ្ញុំដំបូង គឺចង់ដឹងថាលោករក្សាចម្លើយនេះ នូវអ្វីដែលខ្ញុំអានអម្បាញ់មិញនេះ តើលោកពិតជាបាននិយាយយ៉ាងដូច្នេះមែនទេនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំរក្សាដើម ប៉ុន្តែខ្ញុំសូមយោបល់បន្តិច។ ពីដើមឡើយការសាកសួរ និងការសរសេរចេញជាឯកសារនេះ ខ្ញុំច្រើនប្រើពាក្យគ្រប់គ្រង ប៉ុន្តែខ្ញុំពិចារណាទៅពាក្យនេះ វាច្រើនតែប្រើគ្រប់ៗតែគ្នាឲ្យតែអ្នកណាឲ្យធ្វើអីតិចតួចអី គឺថាគ្រប់គ្រងៗហើយ។ ប៉ុន្តែបើនិយាយជានយោបាយក្នុងពេលនេះ ខ្ញុំគិតឃើញថា ខ្ញុំមិនជាអ្នកគ្រប់គ្រងទេ។ ខ្ញុំជាអ្នកជួយការងាររបស់អ្នកដឹកនាំតែប៉ុណ្ណោះ ខ្ញុំមិនបានគ្រប់គ្រងអីទេ ព្រោះខ្ញុំមិនបានសម្រេចអីដោយខ្លួនឯងទេ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ។

[១៣:៣៩:១៨]

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំមានសំណួរមួយ ព្រោះអម្បាញ់មិញនេះ ខ្ញុំបានលេចនិយាយអំពីលោក ហុង ដែលជាបងថ្លៃរបស់លោក ហើយលោកបាននិយាយអំពីលោក ឃឹម ផងដែរ។ ថាគាត់ជាអនុលេខា-- ជាលេខាស្រុកនៅតំបន់ក្រចេះ តើជាបុគ្គលដដែល ឬក៏បុគ្គលផ្សេងទៀត ពីបុគ្គលដែលលោកបាននិយាយអម្បាញ់មិញនេះ?

[១៣:៣៩:៥០]

**ឆ៖** ខ្ញុំទើបនឹងនឹកឃើញពេលនេះ។ ឈ្មោះ ហុង គឺឈ្មោះដើមរបស់គាត់។ ឈ្មោះក្នុងបដិវត្តន៍ ហៅថា យឹម។

**ស៖** បាទសូមអរគុណ។ តើលោកចាំពីមូលហេតុដែលគាត់ត្រូវបានគេនាំទៅក្រសួងការបរទេស ហើយក្រោយមកទៀតគេបានចាប់ខ្លួនគាត់?

**ឆ៖** បាទ ខ្ញុំមិនដឹងមូលហេតុ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមយោងទៅឯកសារ គឺថាកំណត់យកចម្លើយ គឺថាឯកសារ D600--369/36 នៅចម្លើយទី៥៦ ដែលសាក្សីបានឆ្លើយនៅចំពោះសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះ ហើយនិងបង្ហាញចម្លើយនេះទៅសាក្សី។

[១៣:៤១:២២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិយកទៅជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៣:៤២:៣២]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ សំណួរ៥៦ “តើលោកអាចបង្ហាញឈ្មោះអ្នកដែលគេយកមកធ្វើការនៅក្រសួងការបរទេសបានដែរឬទេ?” លោកបានឆ្លើយថា “បាទ ខ្ញុំបានប្រាប់ហើយ គឺបងថ្លៃរបស់ខ្ញុំ គេបានយកគាត់មកដើម្បីធ្វើការនៅក្រសួងការបរទេស ប៉ុន្តែស្រាប់តែបាត់ខ្លួន។ បងថ្លៃរបស់ខ្ញុំគឺជាប់ខ្សែខាង កុយធួន”។ សូមបញ្ចប់ការដកស្រង់។

តើលោកនឹកឃើញទេ? អំពីមូលហេតុដែលបងថ្លៃរបស់លោកត្រូវបានគេនាំខ្លួនទៅក្រសួងការបរទេស ហើយបន្ទាប់មកគាត់ត្រូវបានគេចាប់ខ្លួននោះ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំអត់ទាន់យល់ទេ សូមពិភាក្សាជាមួយ។

[១៣:៤៣:៤០]

*(សាក្សីពិភាក្សាជាមួយមេធាវី)*

[១៣:៤៤:២៨]

**ឆ៖** បាទ មូលហេតុនេះខ្ញុំអត់ដឹងទេ មិនដឹងជារឿងអីទេ។ ប៉ុន្តែខ្ញុំដឹងថា គាត់នេះនៅ-- បងថ្លៃខ្ញុំនេះគាត់នៅជាមួយ នៅភូមិភាគ៣០៤ ដែល ឃួន នេះទទួលខុសត្រូវ។

**ស៖** តើយើងត្រូវយល់យ៉ាងម៉េចដែរ ពាក្យថា "ជាប់ពាក់ព័ន្ធនឹងអ្នកណាម្នាក់" នេះ? តើលោកអាចពន្យល់ពាក្យហ្នឹងបានដែរឬទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ? ពាក្យថា "ជាប់ពាក់ព័ន្ធទៅនឹងលោក កុយ ធួន" នេះ? ជាប់ខ្សែខាង កុយ ធួន? ខ្ញុំមិនសួរថា បងថ្លៃរបស់លោកបានធ្វើអ្វីនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែចង់ដឹងអំពីខ្លឹមសារពាក្យថា "ជាប់ខ្សែខាង កុយ ធួន" នេះ តើមានន័យយ៉ាងម៉េច?

**ឆ៖** ពាក្យថា "ជាប់ខ្សែ" នេះ គឺខ្សែបដិវត្តន៍។ ពាក្យ "បដិវត្តន៍" នេះ មានពាក្យមួយគេថា "ខ្សែ"។ បើចូលខាង៣០៤ គេហៅថា "ខ្សែ៣០៤"។ ដូច្នេះគឺ លោកមិនស្គាល់ខ្សែទេ។ សូមជម្រាប។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីសំណួរពីមុននេះ ដែលលោកបានបញ្ជាក់រក្សារួចហើយ។ លោកបាននិយាយនៅក្នុងចម្លើយនេះ ស្រង់នៅក្នុងចម្លើយកាលអម្បាញ់មិញនេះ ថាអតីតគ្រូរបស់លោកឈ្មោះ វ៉ាន់ (ស៊ីក) ហើយឈ្មោះ-- ហៅ ជា ហ៊ុន (ស៊ីក) ដែលជាប្រធានតំបន់ពាយ័ព្យ ដែលពេលក្រោយមកត្រូវបានគេចាប់ខ្លួន។ តើបុគ្គលនេះ គឺជាអ្នកដែលធ្វើការពីដើមមកធ្វើនៅខាងក្រៅក្រសួង ហើយក្រោយមកបាននាំមកចូលធ្វើការនៅក្នុងក្រសួងជាបណ្ដោះអាសន្ន តើមែនដែរឬទេ?

[១៣:៤៦:៥៧]

**ឆ៖** បាទមែន។

**ស៖** តើជាទូទៅ តើលោកអាចសង្កេតឃើញថា ប៉ង់ ហ្នឹងតែងតែនាំយកកម្មាភិបាលដែលវាមានមុខងារផ្សេងទៀតមកពីខេត្ត ដើម្បីឱ្យមកធ្វើការជាបណ្ដោះអាសន្ននៅក្រសួងការបរទេស? តើអ៊ីចឹងមែនទេ?

**ឆ៖** បាទមែន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

កាលពីម្សិលមិញនៅចម្លើយទី២១ នៃឯកសារ D369/36 មានការលើកឡើងថា នៅមន្ទីរ ប-១ គេដាក់អ្នកដែលថា ប្រវត្តិរូបមិនច្បាស់នៅមួយឡែក។ ខ្ញុំមិនដឹងថា គួរតែបង្ហាញឯកសារនេះឡើងវិញ

ដែរឬក៏អត់ទេ ឬក៏គ្រាន់តែថាលើកយកតែឃ្លានេះមួយមកបង្ហាញ។ នេះអាស្រ័យលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។

[១៣:៤៨:២៦]

**ប្រធានអង្គជំនុំ៖**

គប្បីបង្ហាញនៅលើអេក្រង់កុំព្យូទ័រ ដើម្បីភាគីដទៃទៀតបានដឹងផង បានឃើញផង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** បាទ ខ្ញុំសូមអានអ្វីដែលសាក្សីបានទទួលស្គាល់ "នៅ ប-១ គេបានរក្សាមនុស្សដែលប្រវត្តិរូបមិនច្បាស់លាស់ ហើយបន្ទាប់ពីបានស៊ើបអង្កេតលើពួកគាត់នោះ គេបញ្ជូនពួកគាត់ចេញ ចេញទៅកន្លែងផ្សេង"។ ដូច្នេះ សំណួរខ្ញុំមានដូចតទៅនេះ៖ នៅពេលដែលពួកគាត់ទៅដល់ក្រសួងការបរទេស តើអ្នកណាជាអ្នកស៊ើបអង្កេត? តើជាការស៊ើបអង្កេតដែលធ្វើនៅក្នុងក្រសួងការបរទេស ឬក៏ធ្វើនៅក្រៅក្រសួងការបរទេស?

**លោក សាឡុត បាន៖**

**ឆ៖** ប៉ង់ យកមកធ្វើនៅក្រសួងការបរទេស។ ធ្វើ ពាក្យថា "បញ្ញើ"។ ឯការស៊ើបអង្កេត គឺខាងក្រៅ គឺខាង ប៉ង់។

**ស៖** បាទ សូមអរគុណ។ តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាគេបញ្ជូនគាត់ជាបណ្ដោះអាសន្នទៅក្រសួងការបរទេស? ហើយហេតុអីបានជាបុគ្គលទាំងអស់នេះមិនត្រូវបានចាប់ខ្លួនដោយផ្ទាល់តែម្ដង? ហើយនិងបញ្ជូនទៅមន្ទីរសន្តិសុខ? ហេតុអីក៏បញ្ជូនទៅក្រសួងការបរទេស? ហេតុអីក៏ត្រូវឆ្លងកាត់តាមក្រសួងបរទេសអ៊ីចឹង? តើលោកអាចពន្យល់បានទេអំពីបញ្ហានេះ?

**ឆ៖** ខ្ញុំឃើញថាក្រសួងការបរទេសគ្មានអាវុធទេ អត់មានអាវុធទុកទេ។

**ស៖** តើហេតុអីបាននេះជាការចាំបាច់នៅក្នុងការឲ្យបុគ្គលទាំងអស់នេះឆ្លងកាត់តាមក្រសួងការបរទេសជាបណ្ដោះអាសន្នសិននោះ គ្រាន់តែឈរលើមូលហេតុដែលថា នៅក្រសួងការបរទេសពុំមានអាវុធ ឬក៏យ៉ាងម៉េច?

[១៣:៥១:៣៧]

**ឆ៖** លោកសួរនេះគឺពិបាកឆ្លើយដែរ ប៉ុន្តែខ្ញុំប្រឹងឆ្លើយហើយនេះ។ ប្រហែលជាគេឃើញខ្ញុំកក់ក្ដៅមិនដឹង បានជាគេយកទុកនៅហ្នឹង។ ខ្ញុំទទួលខុសត្រូវហ្នឹង វាមានភាពកក់ក្ដៅមិនដឹង។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញនេះ នៅក្នុងសម្រង់នៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោក ចម្លើយឯកសារ 233/2 លោកបានលើកឡើងពីឈ្មោះ មាឃ ទូច ហៅ កែម ដែលថាគាត់ជាបញ្ញវន្ត។ តើលោកដឹងអំពីមុខងារជាក់លាក់របស់គាត់ទេ ថាមុនពេលមុខងាររបស់គាត់មុនពេលដែលគាត់ត្រូវបានចាប់ខ្លួនដោយ ប៉ង់ នោះ?

**ឆ៖** ខ្ញុំអត់បានដឹងមុខងារជាក់លាក់ទេ។

**ស៖** ចុះលោក តូច ខាំឌឿន វិញនោះយ៉ាងម៉េចដែរ តើលោកស្គាល់តួនាទីរបស់គាត់ទេ មុនពេលដែលគាត់ត្រូវបានគេចាប់ខ្លួននោះ?

**ឆ៖** ខ្ញុំអត់បានស្គាល់ទេ។

**ស៖** ហើយលោកៗ តូច ភឿន ហើយនិង អ៊ុន សូកាន នេះតើលោកស្គាល់មុខងាររបស់គាត់ទេថា នៅខាងក្រៅក្រសួងការបរទេស ហើយនិងមុខងារគាត់នៅក្នុងក្រសួងការបរទេស?

**ឆ៖** ខ្ញុំស្គាល់តែមុខមាត់ និងការងាររបស់គាត់។ ការងាររបស់គាត់ដែលគាត់ធ្វើ តែតួនាទីអត់មានប្រកាសថា ធ្វើអីៗទេ។

[១៣:៥៤:០១]

**ស៖** លោកទើបតែនិយាយថា លោកដឹងអំពីការងារដែលពួកគាត់បានបំពេញ។ ថាតើគាត់ជាអ្នកទទួលបន្ទុកក្នុងការបំពេញការងារនៅក្រសួងការបរទេស? ហើយខ្ញុំនិយាយអំពី មាឃ ទូច ហើយនិង តូច ភឿន និង តូច ខាំឌឿន ហើយនិង អ៊ុន សូកាន?

**ឆ៖** តើគាត់ចង់សួរថាម៉េច? សូមបញ្ជាក់ម្ដងទៀតបាទ។

**ស៖** លោកបាននិយាយថា លោកមិនបានស្គាល់ពីឋានៈ ហើយនិងមុខងាររបស់គាត់ពិតប្រាកដទេ ជាក់លាក់ទេ ក៏ប៉ុន្តែលោកដឹងពីការងារ ដែលគាត់ធ្វើនៅក្នុងក្រសួងការបរទេស។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើបុគ្គលទាំងអស់នេះបានបំពេញការងារអ្វីខ្លះ នៅក្នុងក្រសួងការបរទេសមុនពេលដែលពួកគាត់ទាំងអស់គ្នាហ្នឹងត្រូវបានចាប់ខ្លួន?

**ឆ៖** តាមខ្ញុំចាំ គាត់ដូចជាមកសម្រាក ហើយមានការងារអីត្រូវធ្វើបន្តិចបន្តួច គាត់ជួយ ដូចជាជួយសរសេរអីអ៊ីចឹងទៅ។ ហើយការងារអីមួយទៀតដែលត្រូវខ្វះគ្នា ក៏ទៅការងារមួយទៀតទៅ ពីព្រោះពេលនោះ ត្រូវតែជួយគ្នា អ្នកណាចេះអីជួយហ្នឹង ជួយបានតិចធ្វើតិច ជួយបានច្រើនធ្វើច្រើន គ្មានតួនាទីអីច្បាស់លាស់ទេ។

[១៣:៥៦:៣៥]

**ស៖** តើក្នុងចំណោមបុគ្គលទាំងអស់នោះ មុននឹងពេលដែលគាត់មកធ្វើការនៅមន្ទីរ ប-១ នោះ តើក្នុងចំណោមពួកគាត់នោះ មានអ្នកណាជាអតីតឯកអគ្គរាជទូតដែរឬទេ?

**ឆ៖** ខ្ញុំចាំអត់បានបាទ។

**ស៖** កាលពីព្រឹកមិញ បន្ថែមលើឈ្មោះដែលខ្ញុំបានរៀបរាប់ក្នុងសម្រង់នេះ ដែលលោកបានរក្សាបញ្ជាក់ហើយ មានសម្រង់មួយទៀតដែលយើងបានអាន នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺ D91/15។ ខ្ញុំសាកល្បងរកលេខ ERN ឥឡូវនេះតែម្តង ដែលលោកបានលើកឡើងអំពីឈ្មោះ អ៊ុន លន ហៅ ណាត តើលោកដឹងថា អ៊ុន លន ហៅ ណាត នេះជាអ្នកណាដែរឬទេ?

**ឆ៖** ជួយមើលខ្ញុំផង ឯណា អ៊ុន លន?

**ស៖** បាទ ដើម្បីបញ្ជាក់ឲ្យច្បាស់ គឺឯកសារ D91/15 និង E233/2 ERN ជាភាសាបារាំង មាន 00524353 ដល់ 54 ជាអង់គ្លេស 00361014 ជាភាសាខ្មែរ 00204100 គឺជាសំណួរទីពីរនៅទំព័រនេះ នៃឯកសារនេះ ដែលមានសំណួរសួរថា សាក្សីស្គាល់អ្នកការទូតមួយចំនួនដែរទេ? --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លឿនសាក្សីរកចំណុច ដែលលោកត្រូវសួរដេញដោលនោះមិនទាន់ឃើញទេ។

[១៣:៥៩:៣៨]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាងលេ៖**

**ស៖** នេះគ្រាន់តែជាសំណួរទាក់ទងទៅនឹងបុគ្គលនេះ ដែលមានឈ្មោះនៅក្នុងសំណួរហ្នឹង។ ហើយលោកបានឆ្លើយថា លោកស្គាល់ឈ្មោះបុគ្គលទាំងអស់នោះ ហើយរួមបញ្ចូលទាំងឈ្មោះ អ៊ុន លន ហៅ ណាត ផងដែរ។ តើលោកអានបញ្ជាក់ គ្រាន់តែបញ្ជាក់ថា មុខងារ ឬក៏សកម្មភាពរបស់ អ៊ុន លន ហៅ ណាត នេះមុនពេលដែលគាត់មកដល់មន្ទីរ ប-១ ឬក៏មុនពេលដែលគាត់ចូលមកក្រសួងការបរទេស?

**ឆ៖** បាទ សូមទោស គឺថា ឈ្មោះ អ៊ុន លន ហ្នឹងដូចខ្ញុំអត់ៗស្គាល់ អ៊ុន លន។ ប៉ុន្តែ ណាត ខ្ញុំស្គាល់ ប៉ុន្តែក្នុងឯកសារនេះដាក់ អ៊ុន លន បាទ។ ខ្ញុំអត់ស្គាល់ឈ្មោះ អ៊ុន លន ទេ។ ប្រហែលជាខ្ញុំមើលច្រឡំអីមិនដឹង ឬមួយអ្នកកំណត់ហេតុសរសេរទៅលើសលស់អីមិនដឹង ខ្ញុំសូមបញ្ជាក់ថា អ៊ុន លន ខ្ញុំអត់ស្គាល់ទេបាទ។ បើ ណាត ខ្ញុំស្គាល់។ បញ្ហា ណាត ខ្ញុំអត់ដឹងទេ អត់ដឹងរឿងអីទេបាទ។

**ស៖** ណាត១ ជាឈ្មោះបដិវត្តន៍របស់គាត់នៅសម័យនោះ។ ដូច្នេះ តើលោកអាចជម្រាបជូនបានអំពីមុខងាររបស់ ណាត មុនពេលដែលគាត់មកដល់មន្ទីរ ប-១ ហើយនិងអំពីសកម្មភាពដែលគាត់បំពេញនៅ ប-១ ពេលដែលគាត់មកដល់ ប-១ នេះ?

[១៤:០១:៤២]

**ឆ៖** ណាត តាមខ្ញុំដឹង គឺតួនាទីជាយោធា។

**ស៖** គាត់ជាយោធា ក៏ប៉ុន្តែតើគាត់បំពេញមុខងារអ្វីក្នុងឋានៈគាត់ជាយោធានោះ មុននឹងពេលដែលគាត់មកដល់មន្ទីរ ប-១ ក្រសួងការបរទេសហ្នឹង?

**ឆ៖** ខ្ញុំដឹងថា គាត់ជាយោធា ប៉ុន្តែមិនដឹងឋានៈគាត់ជាអ្វីទេ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងសម្រង់ដែលខ្ញុំបានបង្ហាញអម្បាញ់មិញនេះ លោកបានលើកឡើងបញ្ជាក់ថា ការចោទប្រកាន់ហ្នឹងមកពីខាងក្រៅទេ ហើយលោកបានជម្រាបជូនយើងកាលពីព្រឹកមិញថា ប៉ង់ ជាអ្នកមកចាប់មនុស្ស។ តើយើងអាចដឹងថា ការចោទប្រកាន់ប្រឆាំងនឹងសមាជិក នៅក្រសួងការបរទេសមកពីខាងក្រៅយ៉ាងម៉េច? ហើយវាមានន័យយ៉ាងម៉េចដែលពាក្យថា "ការចោទប្រកាន់មកពីខាងក្រៅ" នេះ?

**ឆ៖** ន័យនេះគឺ ប៉ង់ មានអំណាច ហើយយកមនុស្សពេលណាក៏បាន។

**ស៖** ប៉ុន្តែ ប៉ង់ ថាសម្រេចយកអ្នកនេះ អ្នកនោះ១ តើឈរលើមូលដ្ឋានអី? តើមានឯកសារណាដែលបញ្ជាក់ពីរឿងការមកយកមនុស្សដែរឬទេ?

[១៤:០៣:០០]

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** លោកសាក្សី ក្នុងឋានៈគាត់ជាសមាជិកគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម និងឧបនាយករដ្ឋមន្ត្រី ហើយរដ្ឋមន្ត្រីក្រសួងការបរទេស តើគាត់ទទួលព័ត៌មាន ឧទាហរណ៍ជាចម្លើយសារភាពរបស់អ្នកទោស ឬក៏កំណត់ហេតុលើចម្លើយសារភាពនេះទាំងអស់ដែរឬទេ? តើលោក អៀង សារី បានទទួលព័ត៌មានទាំងអស់នេះដែរឬទេ?

**ឆ៖** គេយកទៅបាត់ហើយបានលោកដឹង។

**ស៖** តើ អៀង សារី បានកោះប្រជុំដើម្បីនិយាយអំពីបញ្ហាចាប់ខ្លួនរបស់បុគ្គលិករបស់ក្រសួងការបរទេសដែរឬទេ?

**ឆ៖** គេយកទៅហើយ បាត់ហើយ អត់មានការកោះហៅប្រជុំទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានខ្ញុំចង់សូមអនុញ្ញាតពីតុលាការបង្ហាញឯកសារមួយ ចម្លើយរបស់សាក្សីនៅ ក្នុងកំណត់ហេតុស្តាប់ចម្លើយ D233/2 គឺជា លេខERN ជាភាសាខ្មែរ គឺថា 00357531 ជាភាសាបារាំង 00405457 នៅទំព័រទី៧ ហើយជាភាសាអង់គ្លេសទំព័រទី៧ដែរ ERN 00361014។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ សំណួរដែលបានចោទនោះមានដូចតទៅនេះ “គឺថាសាក្សីខ្លះបានលើកឡើងថាទាក់ទងទៅនឹងរបាយការណ៍លើការឆ្លើយដាក់ ដែលមាននៅក្នុងចម្លើយសារភាព ឌុច បានរាយការណ៍មកមន្ទីរ៨៧០ រួចមកមន្ទីរ៨៧០ បញ្ជូនមកលោក អៀង សារី។ តើលោកយល់យ៉ាងណាដែរចំពោះការអះអាងនេះ? តើលោកអៀង សារី គាត់ចាត់ការរឿងនេះយ៉ាងណាដែរ?” ហើយលោកបានឆ្លើយថា “បាទ ខ្ញុំដឹងដែរ។ លោកអៀង សារី បានប្រជុំថ្នាក់ដឹកនាំនៅក្រសួងឲ្យបានជ្រាប ប៉ុន្តែខ្ញុំអត់ដឹងអំពីការសម្រេចរបស់លោក អៀង សារី ទេ។ ពេលខ្លះគាត់ធ្វើមុខស្លូត។ បើតាមខ្ញុំដឹងឲ្យស៊ីជម្រៅទៀតនោះគឺមជ្ឈិមចាត់តាំង លោក សុន សេន ជាអ្នកទទួលខុសត្រូវខាងសន្តិសុខ”។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់។

[១៤:០៨:១៤]

តើលោកចាំថា លោកបាននិយាយយ៉ាងដូច្នេះទៅអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំបាននិយាយ គឺថាគេយកមក លោកដឹងហើយ។ គេឲ្យមកធ្វើ គឺលោកដឹង បើលោកមិននៅ ខ្ញុំក៏ជម្រាបលោកដែរ គេយកមនុស្សមកធ្វើហើយ អ្នកនេះ អ្នកនោះ។ ដូច្នេះលោកត្រូវតែដឹង។ ឯការយកមកធ្វើ លោកទទួលតែការយកទៅវិញ ទៅណាៗ នោះលោកអត់ដឹងទេ ខ្ញុំក៏អត់ដឹងដែរ។

**ស៖** តើលោកអាចជ្រាប ជម្រាបយើងបានទេ អំពីកិច្ចប្រជុំដែលកោះហៅដោយលោក អៀង សារី ពាក់ព័ន្ធទៅនឹងការឆ្លើយដាក់ដែលមាននៅក្នុងចម្លើយសារភាព?

**ឆ៖** ខ្ញុំអត់យល់។ អត់យល់សំណួរ។

[១៤:០៩:៤៥]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា តាំងសំណួរអម្បាញ់មិញនេះសាជាថ្មីម្តងទៀត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទក្នុងសម្រង់ដែលខ្ញុំបានអាននេះ ហើយដែលលោកបានរក្សាខ្លឹមសារ គឺថា លោកបាននិយាយថា "ខ្ញុំដឹង លោក អៀង សារី បានរៀបចំការប្រជុំនៅថ្នាក់ដឹកនាំនៅក្រសួង ដើម្បីនិយាយអំពីបញ្ហានុ៎ង"។

ខ្ញុំចង់ដឹងថា តើនៅពេលដែលមានការរៀបចំការប្រជុំហ្នឹងឡើង?

**លោក សាឡុត បាន៖**

**ឆ៖** បាត់មនុស្សដោយគេយកទៅមិនដឹង ទៅណាៗ។ ខ្ញុំ និងលោកត្រូវទទួលធ្វើការងារសតិអារម្មណ៍ កុំឲ្យបងប្អូនភ័យភិត។ នេះជាការមួយដែលកុំឲ្យបងប្អូនខូចអារម្មណ៍ មិនដឹងជាមានរឿងអីទេបានជាគេយកទៅនេះទៅនោះនោះ យើងខំតែប្រឹងធ្វើការទៅ។

[១៤:១១:១៤]

**ស៖** ចំពោះសម្រង់ដដែលនេះ ខ្ញុំចង់ត្រឡប់មកអ្វីដែលលោកបានឆ្លើយ។ ក្នុងសម្រង់ដែលខ្ញុំបានអាននេះ មានបញ្ជាក់ថា គណៈមជ្ឈិមបានចាត់តាំង សុន សេន ទទួលខុសត្រូវខាងបញ្ហាសន្តិសុខ។ តើគាត់ជាអ្នកទទួលខុសត្រូវបញ្ហាសន្តិសុខនេះក្នុងអំឡុងខែមេសា ៧៥ រហូតដល់ខែមករា ៧៩ ពេញតែម្តង ឬក៏មានពេលណាមួយនោះមានការកែប្រែអ្នកទទួលខុសត្រូវខាងផ្នែកសន្តិសុខនេះ?

**ឆ៖** រឿងនេះខ្ញុំអត់ដឹងទេ។

**ស៖** លោកបានបញ្ជាក់ថា លោក ហើយនិង អៀង សារី មិនដឹងទេ ថាតើ ប៉ង់ នាំអ្នកដែលចាប់ខ្លួននោះទៅណា? ឥឡូវនេះខ្ញុំសូមអាននូវសេចក្តីដកស្រង់មួយនៃឯកសារដដែលនេះ ដែលមានលេខ D233/2 នៅទំព័រជាភាសាខ្មែរ ERN 00357530 ជាភាសាបារាំង 00405456 ទំព័រទី៦ ហើយនិងទំព័រទី៧ ជាភាសាអង់គ្លេស ដែលមានលេខ ERN 00361014។

[១៤:១៣:៣១]

ខ្ញុំសូមចំណាយពេលពីរវិនាទីសិន កំពុងតែរកមើលកន្លែងដែលខ្ញុំចង់សួរនេះ។

ខ្ញុំដូចជាច្រឡំចំពោះឯកសារនេះហើយ។ ខ្ញុំនឹងត្រឡប់មកនិយាយពីឯកសារវិញនេះនៅពេល

ក្រោយ។ ឥឡូវនេះខ្ញុំចង់ត្រឡប់មកអ្វីដែលលោកនិយាយអំពី ប៉ង់ អម្បាញ់មិញនេះ។ ក្នុងដំណាក់កាលនេះ ជាច្រើនលើកច្រើនសា ខ្ញុំសង្កេតឃើញថា សាក្សីបានបញ្ជាក់ថា ប៉ង់ បានមកក្រសួងការបរទេសដើម្បីចាប់មនុស្ស នៅចុងឆ្នាំ៧៨ ជាពិសេសនៅក្នុងអំឡុងខែ-- ពីរខែចុងក្រោយនៃឆ្នាំ៧៨។ ក៏ប៉ុន្តែតាមចម្លើយសារភាពរបស់ ប៉ង់ នៅថ្ងៃ២៨ ឧសភា ឆ្នាំ៧៨ គឺឯកសារ IS5.14។ ខ្ញុំមិនស្នើសុំបង្ហាញឯកសារនេះ ឬក៏ផ្តល់ឯកសារនេះជូនសាក្សីទេ ប្រហែលជាគាត់មិនដែលឃើញទេ។ ប៉ុន្តែខ្ញុំគិតថាវាមានសារៈសំខាន់ក្នុងការសួរទៅកាន់សាក្សីរូបនេះ ដើម្បីចង់ដឹងថាតើក្នុងចន្លោះខែឧសភា ឆ្នាំ៧៨ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ប៉ង់ នេះ តើគាត់មានចងចាំទេ ឬក៏គាត់នៅរក្សាចម្លើយដដែល ដែលថាគាត់ឃើញ ប៉ង់ នៅក្រសួងការបរទេសនៅចុងឆ្នាំ១៩៧៨។

**ឆ៖** សូមពិនិត្យមើលឆ្នាំខែ សូមជួយ! សូមបញ្ជាក់សំណួរ និងឆ្នាំឲ្យច្បាស់។

[១៤:១៦:១៥]

**ស៖** ខ្ញុំនិយាយអំពីឆ្នាំ១៩៧៨។ ដូចដែលខ្ញុំបាននិយាយហើយ នៅរយៈកាល-- ការចាប់ខ្លួន ប៉ង់ នៅក្នុងសំណុំឯកសារនោះ គឺខែឧសភា ឆ្នាំ១៩៧៨ តើលោកមានចងចាំទេ អំពីពេលចាប់ខ្លួន ប៉ង់ នេះ? ពីព្រោះថាពីមុននេះលោកបាននិយាយថា បឹងត្របែកត្រូវបានផ្ទេរទៅឲ្យក្រសួងការបរទេសនៅចុងឆ្នាំ៧៨។ ហើយលោកបាននិយាយថា ប៉ង់ បានទៅក្រសួងការបរទេសប្រហែលជាពីរខែមុនពេលវៀតណាមចូលស្រុក ចូលទីក្រុង។ ដូច្នេះរយៈពេលពីពេលចាប់ខ្លួន ប៉ង់ រហូតដល់ពេលវៀតណាមចូលទីក្រុងភ្នំពេញមិនវែងដូចអ្វីដែលលោកគិតនោះទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** សូមទោស បញ្ហានេះខ្ញុំអាចវាក់វ័ណ្ឌនឹងរឿងឆ្នាំខែ ប៉ុន្តែខ្ញុំសូមជម្រាបដូចតទៅនូវការចងចាំរបស់ខ្ញុំពេលនេះ។ ប៉ង់ បាត់ខ្លួនទៅមិនដឹងមូលហេតុអីទេ។ ពេល ប៉ង់ បាត់ខ្លួនទៅ ខ្ញុំនិងបង អៀង សារី ទៅជួយរៀបចំនៅបឹងត្របែក។ បាទ សូមទោស បឹងត្របែក។ ឯហេតុការណ៍អី ប៉ង់ បាត់ខ្លួន និងអីៗទៀត សភាពការណ៍ មូលហេតុអី របស់ ប៉ង់ ខ្ញុំអត់បានដឹងទេ។

**ស៖** សូមអរគុណ។ យើងនឹងនិយាយអំពីបឹងត្របែកនៅពេលក្រោយទៀត។

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្សាងលេះ**

ឥឡូវនេះខ្ញុំបានរកឃើញសម្រង់ដែលខ្ញុំចង់អានជូនសាក្សីហើយ ដើម្បីជាការចងចាំគឺជាឯកសារលេខ D233/2 នៅទំព័រ៦ ជាភាសាបារាំងនៅពាក់កណ្តាលទំព័រ ហើយទំព័រ៧ ជាភាសាអង់គ្លេស ហើយជាភាសាខ្មែរ 00357530។ លោកប្រធាន សូមអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើអេក្រង់

ហើយសូមផ្តល់ឯកសារក្រដាសជូនទៅសាក្សីផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេះ៖**

**ស៖** សំណួរដែលបានសួរលោកនោះគឺថា "មានសាក្សីឆ្លើយថា ក្រសួងការបរទេសធ្លាប់ទទួលបានចម្លើយសារភាព ដែលបានផ្ញើពីមន្ទីរសន្តិសុខស-២១ តើលោកបានដឹងរឿងនេះដែរឬទេ? លោកបានឆ្លើយថា ខ្ញុំបានដឹងដែរ មានគេផ្ញើមកក្រសួងការបរទេស។ ឯកសារខ្លះមានលោក សួង ស៊ីគឿន គាត់ទុក តែពេលរត់ចេញបានបាត់ខ្ចាត់ខ្ចាយអស់ហើយ។ ឯកសារនេះមានការប្រឌិតច្រើន បើតាមខ្ញុំដឹងនោះ"។ ដូច្នេះ សំណួររបស់ខ្ញុំគឺចង់ដឹងថា ចម្លើយសារភាពដែលលោកបាននិយាយនោះ ថាពិតជាត្រូវបានផ្ញើដោយមន្ទីរស-២១ ទៅក្រសួងការបរទេសដែរឬទេ? តើលោកនៅតែរក្សាចម្លើយនេះដដែលឬ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំរក្សាដដែល។

[១៤:២១:៥៩]

**ស៖** តើលោកដឹងទេថា ប៉ង់ ជាអ្នកផ្ញើចម្លើយសារភាពនេះ ឬក៏អ្នកណាផ្សេងទៀត?

**ឆ៖** ខ្ញុំមិនដឹងនរណាផ្ញើទេ ប៉ុន្តែខ្ញុំបានឃើញនៅក្រសួង។

**ស៖** តើលោកអាចជម្រាបយើងបានទេថា តើចម្លើយសារភាពណាឲ្យប្រាកដនោះ ដែលលោកបានឃើញនៅក្រសួងនោះ? ហើយតើចម្លើយសារភាពរបស់អ្នកណា?

**ឆ៖** តាមខ្ញុំចាំចម្លើយសារភាពដូចជារបស់លោក កុយ ធួន។

**ស៖** តើអ្នកណាជាអ្នកបង្ហាញឲ្យលោកឃើញពីចម្លើយសារភាពរបស់ កុយ ធួន នេះ?

**ឆ៖** ពេលនោះ ខ្ញុំឃើញបង អៀង សារី គាត់យកមកអានឲ្យស្តាប់។

**ស៖** តើគាត់អាននៅពេលប្រជុំនៅក្នុងក្រសួងការបរទេស ឬក៏មិនមែនទេ?

**ឆ៖** គាត់អាននៅក្នុងក្រសួងការបរទេស។

[១៤:២៤:៣០]

**ស៖** ខ្ញុំយល់ចម្លើយរបស់លោកមិនច្បាស់ទេ។ តើគាត់អានទៅឲ្យបុគ្គលិកក្រសួងទាំងអស់ស្តាប់តែម្តង ឬក៏ក្នុងក្របខ័ណ្ឌបិទជិត គ្រាន់តែក្នុងកិច្ចប្រជុំ ដែលមានសមាជិក ឬក៏មានកម្មាភិបាលតែពីរបី

នាក់ទេ?

**ឆ៖** គឺអានក្នុងការប្រជុំកម្មាភិបាលថ្នាក់កណ្ដាល។ ពីថ្នាក់លើរហូតដល់ថ្នាក់--

**ស៖** ក្រៅពីអានចម្លើយសារភាពរបស់ កុយ ធួន តើ អៀង សារី គាត់មានបានគិតពិចារណាទៅលើចម្លើយសារភាព ហើយគាត់មានបានអង្កេតអីទេទៅលើហ្នឹង?

**ឆ៖** ពេលអានហើយ ទាំងខ្ញុំទាំងលោក អៀង សារី ទាំងអ្នកទាំងអស់គ្នាមានសេចក្ដីភិតភ័យដូចគ្នា។

**ស៖** ហេតុអីបានជាលោកភ័យ? តើ អៀង សារី ខ្លួនលោកផ្ទាល់ ហើយនិងអ្នកផ្សេងទៀតមានជាប់ខ្សែជាមួយ កុយ ធួន ឬមួយយ៉ាងណា បានជាភ័យនុ៎ង?

[១៤:២៦:៣៦]

**ឆ៖** បានជាភិតភ័យ ខ្ញុំគិតថាប្រហែលថ្ងៃណាមួយដល់អញទៀតហើយ។

**ស៖** បន្ទាប់ពីការចាប់ខ្លួន កុយ ធួន តើលោកអាចបញ្ជាក់បានទេថា នៅក្នុងក្រសួងការបរទេសចំពោះអ្នកដែលបានធ្វើការជាមួយ កុយ ធួន ដែលមកពីភូមិឧត្តរតើមានទទួលផលប៉ះពាល់អីទេ?

**ឆ៖** មិនមែនតែភូមិភាគឧត្តរទេ វៀតណាមវ៉ៃបុកខ្លាំង ដូច្នេះសភាពការណ៍ច្របូកច្របល់។ ការភិតភ័យ និងការដែលវៀតណាមចូលវារីតតែភ័យទាំងអស់គ្នាបន្តបន្ទាប់មក។

**ស៖** សូមអរគុណ។ លោកនិយាយអំពីពេលណាឲ្យប្រាកដនៅពេលដែលលោកនិយាយដល់ការអានចម្លើយសារភាពរបស់ កុយ ធួន ហើយនិងការវាយប្រហាររបស់វៀតណាមនោះ។ តើប្រហែលជានៅក្នុងឆ្នាំណា? លោកនិយាយអំពីឆ្នាំណាដែរ?

**ឆ៖** ខ្ញុំមិនបានកំណត់ហេតុឆ្នាំច្បាស់លាស់ទេ ព្រោះខ្ញុំជាអ្នកភ្លេចច្រើន។ ខ្ញុំកត់ត្រាដែរ ក្នុងសៀវភៅតូចរបស់ខ្ញុំ ប៉ុន្តែរត់ទៅវាចោលអស់ហើយ។ ប៉ុន្តែវៀតណាមឈ្លានពានកម្ពុជា តាំងពីណាពីណីមក។ ប៉ុន្តែពេលនោះ សភាពការណ៍វាកាន់តែជិតហើយ វាកាន់តែឃើញថា គ្រោះអាសន្ន។ វៀតណាមចូលហើយ ដូច្នេះការភ័យដូចខ្ញុំជម្រាបអំមិញអ៊ីចឹង។

[១៤:២៩:២២]

**ស៖** ដើម្បីបំភ្លឺឲ្យច្បាស់ គឺថាមានការវាយប្រហារពីខាងវៀតណាម។ តើលោកនិយាយអំពីការវាយប្រហារផ្ដាច់ព្រ័ត្រចុងក្រោយនៅចុងខែធ្នូ ឆ្នាំ៧៨ ឬក៏ការវាយបករបស់វៀតណាម ព្រោះថាវៀតណាមមានការវាយប្រហារច្រើនដងណាស់នៅខ្មែរយើងនេះ។ អ៊ីចឹងឆ្នាំ៧៨ ក៏មានដែរ តើលោក

សំដៅលើមួយណា? សូមទោស ៧៧។

**ឆ៖** ឲ្យខ្ញុំសំដៅយ៉ាងដូច្នេះមិនបានទេ។ ខ្ញុំសំដៅបានជារួមៗ អារម្មណ៍ខ្ញុំគិតបែកច្រើនពេកអត់បានទេ គឺបានដឹងជារួមៗអ៊ីចឹងជូនលោក។

**ស៖** ពាក់ព័ន្ធទៅនឹងរឿង កុយ ធួន នេះដដែល តើខ្លួនលោកផ្ទាល់បន្ទាប់ពី អៀង សារី បានអានចម្លើយសារភាពឲ្យស្ដាប់ជាមួយនឹងកម្មាភិបាលជាន់ខ្ពស់ និងថ្នាក់កណ្ដាលនៅក្រសួង តើលោកមានបានធ្វើជាប្រធានអង្គប្រជុំនៅច្រាំងចំរេះ ពាក់ព័ន្ធទៅនឹងសកម្មភាពក្បត់ ឬក៏ការចាប់ខ្លួន កុយ ធួន ដែរឬទេ?

**ឆ៖** ក្នុងឋានៈខ្ញុំជាជំនួយការរបស់បង អៀង សារី ខ្ញុំត្រូវតែទៅធ្វើការងារសតិអារម្មណ៍កុំឲ្យបងប្អូនភ័យព្រួយ។

**ស៖** នៅច្រាំងចំរេះតើមានអ្នកដែលមកពីខាងភូមិភាគ ដែល កុយ ធួន បានធ្វើការដែរឬទេ? ហើយតើអ្នកទាំងនុ៎ងគេអាចត្រូវបានគេសង្ស័យថាមានជាប់ខ្សែ កុយ ធួន ដែរឬទេ?

**ឆ៖** នៅច្រាំងចំរេះ ភាគច្រើនគឺនៅខាងភូមិភាគ៣០៤ គឺខាងបង កុយ ធួន។

[១៤:៣២:០៤]

**ស៖** តើមានការស៊ើបអង្កេតដើម្បីដឹងថាតើអ្នកទាំងនោះជាប់ខ្សែ កុយ ធួន យ៉ាងម៉េចខ្លះនោះមានការស៊ើបអង្កេតដែរឬទេ?

**ឆ៖** អត់ឮ អត់ឮបក។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំនឹងសួរសំណួរនេះឡើងវិញ។ ប្រហែលជាសំណួរចុងក្រោយរបស់ខ្ញុំហើយ មុននឹងពេលឈប់សម្រាកនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកបាននិយាយថា នៅច្រាំងចំរេះមានមនុស្សជាច្រើនដែលមកភូមិភាគ៣០៤ គឺភូមិភាគឧត្ដរ។ តើនៅពេលនោះពួកគេត្រូវបានសង្ស័យថាជាប់ខ្សែ កុយ ធួន ដែរឬទេ? ហើយមានការបើកការស៊ើបអង្កេត ដើម្បីដឹងថាតើអ្នកទាំងអស់នោះជាប់ខ្សែ កុយ ធួន យ៉ាងម៉េចខ្លះ? ហើយពួកនោះដឹងអំពីសកម្មភាព កុយ ធួន អីដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** អ្នកនៅច្រាំងចំរេះមកពីខាងបង កុយ ធួន គឺជាកូនកសិករ សុទ្ធតែកសិករ មិនមានឥទ្ធិពល

អីខាងកាន់អាវុធ កាន់អីជាយោធាទេ។ ដូច្នេះ គឺមិនមានខ្សែអីដែលត្រូវទៅស៊ើបអង្កេតទេ។

[១៤:៣៤:២០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណ។ លោកប្រធាន តើខ្ញុំត្រូវបន្តទៀតរហូតដល់ម៉ោងពីរសែសិបប្រាំ ឬក៏យើងឈប់សម្រាកសិន?

**ប្រធានអង្គជំនុំ៖**

បន្តទៀត រហូតដល់ម៉ោងពីរសែសិបនាទី!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី អម្បាញ់មិញនេះ លោកបាននិយាយអំពីចម្លើយសារភាពនៅមន្ទីរស-២១ ដែលត្រូវបានបញ្ជូនមកក្រសួងការបរទេស។ បើតាមលោកដឹងនោះ តើមានការបញ្ជូនចម្លើយសារភាពពីមន្ទីរ ស-២១ ដែលបានឆ្លើយដាក់បុគ្គលិកក្រសួងការបរទេសដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ។

**ស៖** តើលោកមានបានទទួលព័ត៌មានថា បុគ្គលិកមួយចំនួនរបស់ក្រសួងការបរទេសត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពដែរឬទេ? ទោះបីជាចម្លើយសារភាពទាំងអស់នេះមិនត្រូវបានបញ្ជូនមកឲ្យក្រសួងក៏ដោយ?

**ឆ៖** ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺខ្ញុំក៏ព្រួយដែរ មើលទៅគេ ក៏គេទាំងអស់គ្នាបែបព្រួយដូចខ្ញុំដែរហើយមើលទៅ។

[១៤:៣៦:១១]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំចង់យោងទៅលើឯកសារ D233/2 ជាថ្មីម្តងទៀត គឺជាឯកសារដដែលទេ ហើយលេខទំព័រជាភាសាខ្មែរ 00357530។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត សូមអញ្ជើញ! ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលរកទំព័រដែលត្រូវ និងចំណុចដែលត្រូវពិភាក្សាដេញដោលនេះ ដើម្បីជូនសាក្សីពិនិត្យដើម្បីមានលទ្ធភាពក្នុងការអាចដេញដោលបាន។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ជាភាសាបារាំង គឺទំព័រ៥ គឺដែលមានលេខ ERN 00405455 ភាសាអង់គ្លេស ទំព័រ៥-៦ គឺ00361012 ទៅដល់ 00361013។

[១៤:៣៧:៣៣]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួរដែលបានសួរលោកនោះ គឺថាខ្ញុំគិតថានៅទំព័រមុខទៀត ជាភាសាខ្មែរ គឺមានពាក់ព័ន្ធមនុស្សពីរនាក់ដែលមានឈ្មោះថា គាត ឈន់ និងជួន ប្រាសិទ្ធ។ សំណួរមានដូចតទៅនេះ “មានសាក្សីម្នាក់បាននិយាយថា លោក គាត ឈន់ និងលោក ជួន ប្រាសិទ្ធ មានឯកសាររាប់សិបដែលបានឆ្លើយដាក់រូបគាត់ទាំងពីរ។ ប៉ុន្តែលោក អៀង សារី បាននិយាយប្រាប់ ប៉ុល ពត បើចាប់លោក គាត ឈន់ និង ជួន ប្រាសិទ្ធ នោះត្រូវលុបក្រសួងការបរទេសចោលតែម្តង”។ តើលោកបានដឹងរឿងនេះដែរឬទេ? តើនេះជាមូលហេតុដែលលោក គាត ឈន់ និង ជួន ប្រាសិទ្ធ ត្រូវបានគេចាប់ខ្លួន តើមកពីលោក អៀង សារី មានឥទ្ធិពល ទើបអ្នកទាំងពីរនេះមិនត្រូវបានចាប់ខ្លួន មែនឬទេ?

មានការច្របូកច្របល់គ្នាក្នុងការបកប្រែចំពោះឯកសារនេះជាភាសាបារាំង។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ លោកបានឆ្លើយថា “បាទ ខ្ញុំបានដឹងបញ្ហានេះដែរ ហើយខ្ញុំក៏មានការព្រួយបារម្ភចំពោះខ្លួនខ្ញុំដែរ។ ប៉ុន្តែរឿងហ្នឹង ខ្ញុំមិនដឹងថាអ្នកណាប្រឌិតចោទប្រកាន់ទេ។ អ្នកទាំងពីរត្រូវបានលោក អៀង សារី ការពារអ៊ីចឹងមែន។ តាមខ្ញុំដឹងមិនមែនលោក អៀង សារី ទេ សូម្បីតែពូ ប៉ុល ពត ក៏គាត់ឯកភាពដែរ”។

តើលោកនៅតែរក្សាចម្លើយនេះដដែល ដែលលោកឆ្លើយថា គាត ឈន់ និង ជួន ប្រាសិទ្ធ ត្រូវបានគេឆ្លើយដាក់នៅក្នុងឯកសារចម្លើយសារភាពជាច្រើន?

[១៤:៣៩:៣៣]

**លោក សាឡុត បាន៖**

**ឆ៖** បាទ រក្សាដដែល។

**ស៖** តើមានន័យថាម៉េចដែលថា ត្រូវបានគេឆ្លើយដាក់នៅក្នុងឯកសាររាប់សិបនេះ?

**ប្រធានអង្គជំនុំ៖**

បុគ្គលិកជំនួយការ ហើយបើឯកសារវិលរហូតអ៊ីចឹង ទៅមើលឯណាឥឡូវហ្នឹង។ ហើយយ៉ាង

ម៉េចទៅ? លោកអាចទាក់ទងជាមួយនឹងតំណាងសហព្រះរាជអាជ្ញា ដើម្បីកំណត់ឲ្យបានច្បាស់លាស់ទេ ចំណុចណាមួយដែលត្រូវលើកយកមកពិភាក្សាដេញដោល។ បើបង្វិលរហូតអ៊ីចឹងទៅ ហើយអ្នកតាមដានឯកសារនៅក្នុងប្រព័ន្ធកុំព្យូទ័រហ្នឹងមើលម៉េចទៅ?

**លោក វាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសំដៅទៅដល់សំណួរដែលបានសួរនៅក្នុងឯកសារលេខ D233/2 ហើយនៅសំណួរនោះ គឺមានសាក្សីបាននិយាយថា គាត ឈន់ និង ជួន ប្រាសិទ្ធ នោះគឺមានឯកសាររាប់សិបដែលឆ្លើយដាក់។

[១៤:០០:៥៦]

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** ដូច្នេះ ខ្ញុំចង់ដឹងថា ការឆ្លើយដាក់នៅក្នុងឯកសាររបស់សិបនៅសម័យកម្ពុជាប្រជាធិប-តេយ្យហ្នឹងមានន័យថាម៉េច? ប្រហែលជាខ្ញុំអាចរៀបសំណួរនេះឡើងវិញ ថាតើការឆ្លើយដាក់នៅក្នុងឯកសាររាប់សិប មានន័យថា ត្រូវបានគេចោទប្រកាន់ដោយអ្នកណាម្នាក់នៅក្រោមរបបនេះ តើអ៊ីចឹងមែនទេលោកសាក្សី?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក អៀង សារី ប៉ុន្តែអង្គជំនុំជម្រះសូមជម្រាប និងរំឭកលោកថា លោកមានសិទ្ធិក្នុងការធ្វើការជំទាស់ទៅនឹងការតាំងសំណួរ ដោយបញ្ជាក់ពីមូលហេតុនៃការជំទាស់លោកខ្លីបានហើយ។ អង្គជំនុំជម្រះមិនបណ្ដែតបណ្ដោយឲ្យលោកធ្វើអត្ថាធិប្បាយយ៉ាងវែង ដូចអ្វីដែលលោកធ្លាប់ធ្វើពី--ដូចជាព្រឹកមិញនោះទេ។

[១៤:៤២:០២]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា នេះគឺជាសំណួរនាំមុខហើយ តាមដែលមេធាវីការពារក្ដីស្ដាប់ឮ។ ហើយខ្ញុំមិនៗជំទាស់ទេ តែបើសិនណាជាអនុញ្ញាតឲ្យភាគីម្ខាងសួរសំណួរនាំមុខនោះ ក៏ត្រូវតែអនុញ្ញាតឲ្យភាគីដទៃទៀតសួរសំណួរនាំមុខដែរ ពីព្រោះជាសំណួរដែលកំពុងតែនាំតម្រុយឈានទៅយកចម្លើយហើយ។

សូមអរគុណលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤២:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា! សំណួរចុងក្រោយ ហើយមុននឹងសម្រាក។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ តាមពិតនោះខ្ញុំនិយាយអំពីចម្លើយមួយផ្នែក ដែលបញ្ជាក់ថាមានការឆ្លើយដាក់នៅក្នុងឯកសាររាប់សិប។ ប្រសិនបើយើងមើលឯក-- សំណួរនេះបន្តទៀតនោះ ខ្ញុំគិតថាសំណួរដែលខ្ញុំសួរនោះមិនមែនថា ជាសំណួរនាំមុខហួសហេតុអីទេ។ ពីព្រោះថា អៀង សារី បានប្រាប់ប៉ុល ពត ថាបើសិនជាគេចាប់ខ្លួនបុគ្គលទាំងពីរនាក់ គេត្រូវបិទក្រសួងចោល។ ដូច្នេះនេះគឺជាការឆ្លើយដាក់នៅក្នុងឯកសារជាច្រើន ហើយច្បាស់ណាស់ គឺយើងនិយាយអំពីការចាប់ខ្លួន។ ដូច្នេះហើយខ្ញុំចង់សួរបញ្ជាក់ឲ្យច្បាស់ ថាតើនៅទីនេះ គឺជាឯកសារដែលបានចោទប្រកាន់ចំពោះបុគ្គលទាំងពីរនាក់នេះដែរឬទេ?

[១៤:៤៤:១១]

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំយល់ថា ឯកសារនេះ គឺជាឯកសារដែល-- ទេដូចខ្ញុំមិនទាន់យល់ទេ ខ្ញុំសូមពិគ្រោះន័--

*(សាក្សីពិភាក្សាជាមួយមេធាវី)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អន្តរជាតិការពារក្តីលោក នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលសាក្សីកំពុងតែពិគ្រោះយោបល់ជាមួយមេធាវីរបស់គាត់។ ខ្ញុំគ្រាន់តែដើម្បីប្រតិចារឹកគឺថា ហាក់បីដូចជាមានការបាត់បង់ពាក្យពេចន៍ខ្លះរវាងភាសាអង់គ្លេស និងភាសាខ្មែរ។ ប្រហែលជាតំណាងសហព្រះរាជអាជ្ញាអាចបង្ហាញនូវឯកសារ ដែលបានសួរនោះ ពីព្រោះសាក្សីបានឆ្លើយថា គាត់អត់បានដឹង។ ប្រហែលជាតំណាងសហព្រះរាជអាជ្ញាអាចជួយបញ្ជាក់

អំពីការបាត់បង់ ឬក៏ចន្លោះប្រហោងពាក្យពេចន៍រវាងភាសាទាំងពីរនេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

លោកប្រធាន ខ្ញុំគិតថាខ្ញុំមិនអាចឆ្លើយតបភ្លាមៗទៅកាន់មេធាវីទេ យើងត្រូវយោងទៅលើឯកសារច្បាប់ដើម ជាភាសាខ្មែរ ពីព្រោះថាប្រហែលជាមានបញ្ហាខាងបកប្រែជាភាសាអង់គ្លេស និងបារាំង ហើយខ្ញុំមិនអាចអានភាសាខ្មែរបានទេ។ ដូច្នេះខ្ញុំគិតថា ខ្ញុំអាចពិនិត្យមើលពេលឈប់សម្រាកហើយពេលចូលមកវិញ ខ្ញុំអាចផ្តល់ការពន្យល់បាន។ លោកប្រធានសូមអរគុណ។

[១៤:៤៦:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។

បាទ ឥឡូវដល់ពេលសមល្មមនឹងសម្រាកដែរហើយ ៗមុននឹងសម្រាកហ្នឹងអង្គជំនុំជម្រះសូមសួរទៅភាគីដទៃទៀតដែលមិនទាន់បានដំណើរការ តាំងសំណួរដល់សាក្សីរូបនេះ ក្រោយពីបានសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញាមកដល់ពេលនេះ សំណួរសួរថាតើក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវការចំណាយពេលវេលាប៉ុន្មានដែរ នៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ?

[១៤:៤៧:០៦]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវការរយៈពេលបីម៉ោងដូចដែលបានស្នើសុំពីមុន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគួរគិតឡើងវិញ ការប្រើប្រាស់ ស្នើសុំបីម៉ោងហើយនិងពេលវេលាមួយព្រឹក ហើយនិងមួយរសៀលនេះក៏ខុសគ្នាដែរ។ ពេលវេលាមួយព្រឹកមិនបានបីម៉ោងទេ ការដេញដោល ហើយរសៀលក៏ដូចគ្នា បានតែពីរម៉ោងដប់នាទីទេ។ អ៊ីចឹងគប្បីប្រើប្រាស់នូវពេលវេលាហ្នឹង ហើយនិងការស្នើសុំឲ្យបានត្រឹមត្រូវផងដែរ ដើម្បីចៀសវាងមានបញ្ហាមិនច្បាស់លាស់

នៅក្នុងការសម្រេចលើសំណើសុំ ហើយនិងស្ថានភាពជាក់ស្តែងដែលត្រូវអនុវត្តនៅទីនេះ។

ហើយចុះខាងមេធាវីការពារក្តីលោក នួន ជា តើត្រូវការពេលវេលាយ៉ាងម៉េចដែរ? ទំនងជាពេលវេលាប៉ុន្មានទៅ?

[១៤:៤៨:១៣]

**លោក ម៉ៃខល ផេសមិនៈ**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាមិនត្រូវការពេលលើសពីកន្លះថ្ងៃទេ មិនដឹងថាតើអនុញ្ញាតឱ្យខ្ញុំពេលព្រឹក ឬក៏រសៀលនោះទេ។ បាទ ខ្ញុំក៏ត្រូវពិភាក្សាជាមួយនឹងក្រុមមេធាវីការពារក្តីរបស់លោក អៀង សារី ជាមុនសិន ដោយសារគាត់ត្រូវចេញដំណើរមុន។ ខ្ញុំមិនជំទាស់ បើសិនណាជាអង្គជំនុំជម្រះសាលាដំបូងគិតថា ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ចាប់ផ្តើមមុន ហើយយើងខ្ញុំអាចនឹងត្រូវការពេលវេលាតិចជាងក្រុមគាត់ ឬក៏យ៉ាងណានោះ។

**ប្រធានអង្គជំនុំៈ**

បាទ អរគុណច្រើន។ ហើយចុះក្រុមមេធាវីការពារក្តីលោក អៀង សារី? យ៉ាងម៉េចដែរ ត្រូវការពេលវេលាប្រហែលជា-- ទំនងប្រហែលប៉ុន្មានទៅ?

**លោក ម៉ៃខល កាណាវាសៈ**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំស្មានថា ខ្ញុំត្រូវការពេលវេលាមួយថ្ងៃកន្លះ ប៉ុន្តែវាអាស្រ័យអ្វីដែលវានឹងកើតមានឡើងនៅថ្ងៃនេះ ឬក៏ថ្ងៃស្អែក។ ប្រហែលជាអាចនឹងតិចជាងរយៈពេលមួយថ្ងៃកន្លះនេះ។ ប៉ុន្តែសម្រាប់ពេលនេះ ខ្ញុំគិតថា ខ្ញុំត្រូវការលើសពីមួយថ្ងៃ ដោយសារថា បើសិនណាឱ្យមេធាវីការពារក្តីសរុបទាំងអស់ពីរថ្ងៃកន្លះ ពេលនោះយើងអាចនឹងចាត់ចែង។ កាលណាខ្ញុំនិយាយមួយថ្ងៃ គឺវាអាចតិចជាង។

[១៤:៤៩:៤៤]

ឧទាហរណ៍ បើនៅពេលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវការពេលវេលាស្អែកពេញមួយថ្ងៃតែម្តងនោះ។ ដូច្នេះយើងខ្ញុំអាចនឹងចំណាយពេលវេលានៅក្នុងពេលយប់នេះ ដើម្បីពិនិត្យមើលថា តើត្រូវការពេលវេលាប៉ុន្មាននោះ? ខ្ញុំគិតថា ការជូនព័ត៌មានទាំងនេះដល់ជំនុំជម្រះ អាចជាការជួយកំណត់ពេលវេលាបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ប៉ុន្តែក្រុមមេធាវីការពារក្តី-- នាំមុខដើមបណ្តឹងរដ្ឋប្បវេណី ទំនងជាមិនអនុញ្ញាតឲ្យលើសពីមួយពេលទេ មួយពេលនៃដំណើរការព្រឹក ឬក៏ពេលល្ងាច។ ហើយស្អែកទំនងជាយើងអនុញ្ញាតឲ្យតែមួយម៉ោងប៉ុណ្ណោះចំពោះការបាត់បង់ពេលវេលា ចំពោះក្រុមតំណាងសហព្រះរាជអាជ្ញា។ អ៊ីចឹងពេលវេលាស្អែកនេះ គឺអាចទំនងនៅសល់ចាប់ពីពេលសម្រាកនៅពេលរសៀល គឺនឹងទៅដល់វេនកិច្ចដំណើរដេញដោលដោយមេធាវីការពារក្តីហើយ។ យើងនឹងប្រឹងប្រែងគ្រប់គ្រងពេលវេលានេះឲ្យបានត្រឹមត្រូវ ហើយនិងជាអតិប្បបរមា លើកលែងតែមានហេតុការណ៍ផ្សេងៗដែលកើតឡើងដូចយើងបានជួបប្រទះកន្លងមក ជាពិសេសដូចព្រឹកនេះដែលយើងមិនអាចចៀសវាងបាន។ នោះយើងនឹងដោះស្រាយដោយវិធី នៃការបំពេញបន្ថែមក្នុងករណីដែលចាំបាច់ប៉ុណ្ណោះ។

ហើយចុះក្រុមមេធាវីការពារក្តីលោក ខៀវ សំផន?

[១៤:៥១:១៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្រុមមេធាវីការពារលោក ខៀវ សំផន យើងត្រូវការពេលប្រហែលជាមួយម៉ោង ទៅមួយម៉ោងកន្លះយ៉ាងច្រើនបំផុត។ ដូច្នេះ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើននូវការផ្តល់ព័ត៌មាន អំពីពេលវេលាប៉ាន់ស្មាននេះ ហើយយើងនឹងប្រឹងប្រែងធ្វើតទៅទៀត ហើយដើម្បីអង្គជំនុំជម្រះហ្នឹង បានតែបានព័ត៌មាននេះដើម្បីគ្រោងនូវការរៀបចំនូវការបរិច្ឆេទក្នុងកិច្ចដំណើរការសវនាការចំពោះសាក្សីរូបនេះ ឲ្យមានប្រសិទ្ធភាព ហើយការប្រើប្រាស់ពេលវេលាទៀតសោតហ្នឹង ឲ្យខ្ចីសមល្មម ដែលនឹងអាចបញ្ចប់នូវកិច្ចដំណើរការសម្រាប់គាត់បាន ពីព្រោះប្រសិនបើវែងពេកនោះ វាអាចឆ្លងដល់សប្តាហ៍ក្រោយនោះ ក៏ជាការលំបាកមួយចំពោះកិច្ចដំណើរការសម្រាប់រូបគាត់ ដែលត្រូវនៅទីក្រុងភ្នំពេញនៅក្នុងថ្ងៃឈប់សម្រាកថ្ងៃសៅរ៍អាទិត្យ។

នេះលទ្ធភាពនេះ អង្គជំនុំជម្រះប្រឹងប្រែងពិចារណា ហើយនិងរកដំណោះស្រាយណាល្អបំផុតដែលអាចទៅរួច។ ប្រសិនបើទៅមិនរួចទេ អាហ្នឹងយើងចាំបាច់ យើងនឹងបន្តទៅពេលសប្តាហ៍ក្រោយ។ អានេះជារឿងចាំបាច់នៃការងារ ដែលយើងអាចខានមិនបាន។

សូមអញ្ជើញលោកមេធាវី!

[១៤:៥២:៣០]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន សូមធ្វើការបញ្ជាក់សាជាថ្មី រយៈពេលដែលត្រូវការនោះគឺ ខាងមេធាវីនាំមុខបានស្នើសុំរយៈពេលបីម៉ោងមែន ក៏ប៉ុន្តែយើងខ្ញុំបានមានការភ័ន្តច្រឡំបន្តិចអម្បាញ់មិញ គឺរយៈពេលនេះគឺ ឯកភាពដូចដែលអ្វីដែលលោក-- អនុស្សរណៈរបស់អង្គជំនុំជម្រះគឺរយៈពេលមួយព្រឹក។ អ៊ីចឹងរយៈពេលប្រហែលជាពីរម៉ោងដប់ប្រាំនាទី ទៅពីរម៉ោងកន្លះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សីដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ផង ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបីដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៤ នាទី ដល់ម៉ោង ១៥:១០ នាទី)*

[១៥:១០:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីការសវនាការ។

បាទ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ថ្ងៃនេះអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់តំណាងសហព្រះរាជអាជ្ញាបានជ្រាបថា អង្គជំនុំជម្រះបានពិនិត្យពិចារណាលើសារៈសំខាន់នៃការពិភាក្សាដេញដោលចំពោះសាក្សីរូបនេះ ដើម្បីជាប្រយោជន៍ ក្នុងការស្វែងរកការពិតនោះ គឺអង្គជំនុំជម្រះបានសម្រេចឯកភាពលើមតិភាគច្រើនថា ផ្តល់ជូនតំណាងសហព្រះរាជអាជ្ញាមានឱកាសមួយព្រឹកថ្ងៃស្អែកទៀត ក្នុងការតាំងសំណួរដេញដោលសាក្សី

រូបនេះ។ ហើយចំណែកឯក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាពេញមួយរសៀលថ្ងៃស្អែក។ ហើយចំពោះស្ថានភាពនៃការផ្តល់ពេលវេលាជាក់ស្តែងដល់ក្រុមមេធាវីការពារក្តីនោះ គឺអង្គជំនុំជម្រះនឹងពិចារណានៅ-- នឹងជូនដំណឹងដល់ក្រុមមេធាវីការពារក្តីនៅរសៀលថ្ងៃស្អែកតាមស្ថានភាពជាក់ស្តែង នៅពេលដែលយើងដំណើរការសវនាការនៅថ្ងៃស្អែកទៀតនោះ។

[១៥:១២:៤៤]

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោល។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯលះ**

សូមអរគុណលោកប្រធាន។ មុនពេលសម្រាក មានចោទសំណួរមួយលើកឡើងដោយភាគីការពារក្តីរបស់ក្រុម នួន ជា ពាក់ព័ន្ធនឹងភាពខុសគ្នានៃការបកប្រែសំណៅបារាំង ហើយនិងអង់គ្លេសនៅចម្លើយរបស់សាក្សីនៅក្នុង D ឯកសារ 233/2 យើងបានផ្ទៀងផ្ទាត់ឃើញថា តាមពិតសំណៅខ្មែរហាក់ដូចជាស៊ីគ្នានឹងសំណៅជាភាសាបារាំង ក៏ប៉ុន្តែមិនស៊ីគ្នាជាមួយសំណៅជាភាសាអង់គ្លេស។ ក្នុងសំណៅជាភាសាអង់គ្លេស គឺថាគាត់មិនដឹង ហើយក្នុងសំណៅជាភាសាបារាំង ហើយនិងខ្មែរ គឺថាគាត់ៗ "ដឹង"។

[១៥:១៣:៤៤]

ខ្ញុំចង់បញ្ជាក់ថា នៅក្នុងសំណួរទេ ដែលថាអាចមានការលំបាកក្នុងការយល់ ពីព្រោះថាសំណួរនេះ សួរថា "តើនេះឬជាមូលហេតុនៃការចាប់ខ្លួនរបស់លោក គាត ឈន់ ហើយនិង ជួន ប្រាសិទ្ធ ហើយគាត់ទាំងពីររូបនេះមិនត្រូវបានចាប់ខ្លួនទេ"។ ហើយឃ្លាបន្ទាប់មកទៀតនោះ អាចឲ្យយើងយល់បានគឺថា ដោយសារតែលោក អៀង សារី ជាមនុស្សមានឥទ្ធិពល ដោយសារហេតុនេះហើយបានជាបុគ្គលទាំងពីររូបនេះមិនត្រូវបានគេចាប់ខ្លួន។ ហើយខ្ញុំមិនដឹងថា អ្វីដែលខ្ញុំបានលើកឡើងនេះ ឆ្លើយតបទៅនឹងសំណួររបស់ខាងក្រុមមេធាវីលោក នួន ជា ដែរ ឬក៏អត់នោះទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! សូមលោកបន្តការតាំងសំណួរដេញដោល។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯលះ**

បើសិនជាខ្ញុំមិនច្រឡំទេ គឺថាមុនពេលសម្រាកសាក្សីមិនបានឆ្លើយទៅសំណួរថា តើពាក្យថា

ឆ្លើយដាក់ នៅក្នុងឯកសារចម្លើយសារភាពនោះ គឺមានន័យយ៉ាងម៉េចនោះទេ។ ហើយអង្គជំនុំជម្រះក៏មិនបានធ្វើសេចក្តីសម្រេចលើបញ្ហានេះដែរ។ ខ្ញុំចង់ដឹងថា តើពាក្យថាឆ្លើយដាក់ដោយអ្នកណាម្នាក់នេះមានន័យយ៉ាងម៉េច? គឺអ៊ីចឹង ខ្ញុំចង់សួរទៅលោកប្រធាន ថាតើខ្ញុំអាចសួរសំណួរនេះ បានដែរឬទេ? ព្រោះអម្បាញ់មិញមានការជំទាស់ពីលោកមេធាវី កាណាវាស។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកតាំងសំណួរដេញដោល!

**សួរដោយលោក វ៉ាំងសង់ វ៉ាយស៍ ដេស្នាឯល៖**

**ស៖** លោកសាក្សីតើពាក្យថា មានការឆ្លើយដាក់នៅក្នុងចម្លើយសារភាពរាប់សិបនេះ ដែលថាឆ្លើយដាក់ដោយអ្នកផ្សេង? តើពាក្យនេះ មានន័យថាយ៉ាងម៉េចលោកសាក្សី?

**លោក សាឡុត បាន៖**

**ឆ៖** ពាក្យនេះ មានន័យថាឮ ចេះតែឮៗទៅ ឮថា មានគេឆ្លើយដាក់ៗៗ អ៊ីចឹងទៅ ហ្នឹង។ ប៉ុន្តែមិនដឹងប្រភពណាដែលឆ្លើយ។

**ស៖** នៅក្រសួងការបរទេស នៅពេលដែលមានអ្នកដែលគេឆ្លើយដាក់ ឧទាហរណ៍ គាត ឈន់ ហើយនិង ជួន ប្រាសិទ្ធ។ តើផលវិបាកនៃការឆ្លើយដាក់នេះ វាយ៉ាងម៉េចដែរ?

[១៥:១៧:២២]

**ឆ៖** ដូចខ្ញុំបានជម្រាបអ៊ីចឹង ទាំងគាត់ ទាំងខ្ញុំ ទាំងអី វាព្រួយបារម្ភ។

**ស៖** ហើយទាក់ទងទៅនឹងបុគ្គលដែលគេបានឆ្លើយដាក់នេះ តើបុគ្គលទាំងអស់នេះ ត្រូវផ្តល់ព័ត៌មាន ឬក៏ត្រូវបង្ហាញពីមូលហេតុទាក់ទងទៅនឹងការឆ្លើយដាក់ទៅលើខ្លួនដែរឬទេ?

**ឆ៖** មិនមានអ្វីជាការតបតទេ គឺធ្វើការជាធម្មតា នៅស្ងៀម។

**ស៖** តើបុគ្គលទាំងអស់នេះ ត្រូវតាក់តែងឯកសារទាក់ទងទៅនឹងការឆ្លើយដាក់លើខ្លួនដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ រឿងនេះ។

**ស៖** មុននឹងចូលទៅប្រធានបទមួយទៀត ខ្ញុំចង់ត្រឡប់មកជាថ្មីម្តងទៀត ជាលើកចុងក្រោយទៅលើរឿងរបស់លោក កុយ ធួន ដែលលោកបានរៀបរាប់ប្រាប់យើង។ ហើយនិងលើផលវិបាកនៅច្រាំងចំរេះ លោកបាននិយាយថា ពុំមានការចាំបាច់ក្នុងការស៊ើបអង្កេតអីទេ ព្រោះថាអ្នកនៅទីនោះសុទ្ធតែកសិករ ហើយគាត់មិនមែនជាអ្នកជាប់ខ្សែ កុយ ធួន ទេ។

[១៥:១៩:២៧]

ខ្ញុំសូមអានចម្លើយដែលលោកបានឆ្លើយទៅមុខ ចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺថានៅក្នុងឯកសារ D369/36 ហើយមានចម្លើយចំនួនបី ដែលយើងចាប់អារម្មណ៍ គឺចម្លើយ១០៧, ១០៨ ហើយនិង១១០។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការរៀបចំជួយចង្អុលបង្ហាញឯកសារដល់សាក្សី។

[១៥:២១:០៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ សូមអរគុណ។ សំណួរ១០៧ "តើលោកធ្លាប់ចូលរួមប្រជុំនៅ ប-១ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកដែលនៅក្រៅ មកលើអ្នកដែលនៅច្រាំងចំរេះ ដែលជា គេចោទថាខ្មាំងដែរឬទេ? ចម្លើយ៖ ខ្ញុំធ្លាប់ចូលរួមប្រជុំនៅ ប-១ ហើយខ្ញុំធ្លាប់បានហៅអ្នកនៅច្រាំងចំរេះមកប្រជុំ"។

សំណួរ១០៨ "សូមរៀបរាប់ករណីជាក់ស្តែងណាមួយ បើមាន? ចម្លើយ១០៨៖ ឧទាហរណ៍ដូចជារឿង កុយ ធួន ត្រូវបានគេចោទប្រកាន់។ ដូច្នេះ គេត្រូវនាំអ្នកដែលនៅក្រុម កុយ ធួន យកមកនាំសួរក្រែងលោ កុយ ធួន មានឲ្យធ្វើរឿងអ្វីខ្លះ ឬក៏ដឹងរឿង កុយ ធួន ធ្វើអ្វីខ្លះ"។

ហើយនៅបញ្ចប់ គឺសំណួរ១១០៖ "តើនៅពេលប្រជុំមើលឯកសារ-- ឯកសារចោទប្រកាន់មានលោក អៀង សារី ចូលរួមដែរឬទេ? ចម្លើយ៖ មិនមានទេ។ គាត់មិនបានចូលរួមទេ គឺខ្ញុំជាអ្នករាយការណ៍ជូនគាត់។ ខ្ញុំបានរាយការណ៍ថា ពួកអ្នកទាំងនេះមិនដឹងទេ គេធ្វើតាមតែអ្នកដឹកនាំ"។

បាទ ឥឡូវនេះខ្ញុំចង់ដឹងថា តើលោករក្សាចម្លើយរបស់លោកដែរឬទេ? ពីព្រោះថាអម្បាញ់មិញលោកហាក់ដូចជានិយាយថា ពុំមានការស៊ើបអង្កេត។ ក៏ប៉ុន្តែនៅក្នុងចម្លើយដែលថាលោកបានផ្តល់ពីមុនមកនោះ វាច្បាស់ណាស់ដែលថា ត្រូវតែកោះហៅកូនចៅរបស់ កុយ ធួន។ បាទ សូមលោកឆ្លើយតបនឹងសំណួរនេះ។

**លោក សាឡុត បាន៖**

**ឆ៖** បាទ សូមឆ្លើយនឹងសំណួរ ជារបៀបរបប គឺពាក្យថា "ប្រជុំ" មិនមែនជាការស៊ើបទេ។

មិនមែនជាការស៊ើបអង្កេតទេ។ ពាក្យថា "ប្រជុំ" នេះ គឺមានឯកសាររៀនសូត្រ។ រៀនសូត្រហើយឲ្យជំនាន់នុំង គេនិយាយតែមិត្តយើង សូមមិត្តយើងពាក់ព័ន្ធមើល៍ តើមិត្តយើងមានអីពាក់ព័ន្ធទេ កុំឲ្យមិត្តយើងព្រួយបារម្ភ មានអីនិយាយទៅ និយាយទៅ យើងកសាងខ្លួនទៅ ឲ្យស្មោះត្រង់ បើមិនមានអីទេ យើងធ្វើការទៅ តាមធម្មតាទៅ។ នេះមិនមានន័យថា "ស៊ើបអង្កេត"ទេ គឺការរៀនសូត្រពាក់ព័ន្ធ កសាងខ្លួន។

[១៥:២៤:៣៣]

**ស៖** បាទ សូមអរគុណ។ លោកបាននិយាយអំពីការសិក្សាឯកសារ។ តើនៅក្នុងវគ្គសិក្សាឯកសារនៅច្រាំងចំរេះនេះ លោកបានឲ្យសិក្សាឯកសារអ្វីខ្លះ?

**ឆ៖** ឯកសារមានច្រើន។ ប៉ុន្តែឯកសារដែលខ្ញុំសរុបមកហ្នឹង ដូចខ្ញុំបាននិយាយជាហូរហែមកគឺសីលធម៌ ១២ប្រការ។ ទីមួយ ស្នេហាជាតិមោះមុត អាហ្នឹងខ្ញុំចាំច្បាស់ណាស់។ ប៉ុន្តែខងទៃទៀត ម្ទេសមួយផ្លែ មិនត្រូវប៉ះប្រជាជនទេ។

**ស៖** ក៏ប៉ុន្តែលោកបានលើកឡើងដែរថា លោកបានរាយការណ៍ទៅ អៀង សារី ប្រាប់ថា មនុស្សទាំងអស់នេះមិនដឹងអ្វីទេ ហើយសំណួរដែលសួរទៅពួកគាត់នេះ ថាតើគាត់ដឹងអ្វីខ្លះអំពីសកម្មភាព កុយ ធួន ហើយនិងការចាប់ខ្លួនរបស់គាត់? ហើយនិងពីការចោទប្រកាន់ទៅលោក កុយ ធួន នោះ?

**ឆ៖** ខ្ញុំអត់យល់។ ខ្ញុំអត់យល់សំណួរទេបាទ។

[១៥:២៦:២០]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តាំងសំណួរអម្បាញ់មិញសាជាថ្មីម្តងទៀត ព្រោះសាក្សីមិនយល់សំណួរដែលលោកសួរទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកបាននិយាយអំពីការសិក្សាលើសីលធម៌១២ប្រការ ហើយនៅចម្លើយរបស់លោកនេះ លោកបានថា លោករាយការណ៍ទៅ អៀង សារី ហើយលោកបានប្រាប់គាត់ថា បុគ្គលទាំងអស់នោះដែលនៅច្រាំងចំរេះនោះ មិនដឹងអីទេ ហើយពួកគាត់នោះគ្រាន់តែអនុវត្តបញ្ជារបស់ថ្នាក់ដឹកនាំទេ។ តើឈរលើហេតុផល នៅពេលដែលលោករាយការណ៍ថា បុគ្គលទាំងអស់នោះមិនដឹងអ្វីទាំងអស់នុំង តើលោកមិនបានសួរទៅគាត់ថា បុគ្គលទាំងអស់នោះ ថាតើខ្លួនដឹងអំពី-- មានទំនាក់ទំនងអ្វីមួយ? ណាមួយ

ជាមួយ កុយ ធួន ទេឬ?

[១៥:២៧:២៣]

**លោក សាឡុត បាន៖**

**ឆ៖** វិធីរៀនសូត្រ ខ្ញុំបាននិយាយហើយ គឺឲ្យម្នាក់ៗពាក់ព័ន្ធខ្លួនឯង កសាងខ្លួនឯង តើខ្លួនឯងមានអីពាក់ព័ន្ធទៅបង កុយ ធួន ទេ។ បង កុយ ធួន មានប្រើប្រាស់ជាឧបករណ៍សម្រាប់អីៗឲ្យខូចខាតដល់អង្គភាពទេ។ គេពាក់ព័ន្ធទៅសមូហភាពជួយទៅ ឃើញថាអ្នកទាំងអស់នោះវាត្រឹមត្រូវ ខ្ញុំរាយការណ៍បងអៀង សារី ថាមនុស្សនោះត្រឹមត្រូវ។ នេះជាវិធី។

**ស៖** តើៗគេហៅកិច្ចប្រជុំទាំងអស់នោះ គេហៅថា កិច្ចប្រជុំជីវទស្សន៍ ដែរឬទេ?

**ឆ៖** កិច្ចប្រជុំវាមានច្រើន ឧទាហរណ៍អំមិញនេះ ខ្ញុំទៅប្រជុំនោះ គឺប្រជុំដើម្បីសម្របសម្រួលដើម្បីកុំឲ្យបងប្អូនភិតភ័យ អំពីរឿងការចាប់មេគេទៅ។ យើងអាចហៅថា "ធ្វើជីវទស្សនៈបដិវត្តន៍" ក៏បានដែរ ប៉ុន្តែជីវទស្សនៈបដិវត្តន៍នេះវាជ្រៅ។ ប្រជុំដូចខ្ញុំថាអំមិញហ្នឹង គឺជាប្រជុំស្រាលទេ គឺគ្រាន់តែទៅលួង-- អំគ្រាន់តែទៅធ្វើការងារសតិអារម្មណ៍ កុំឲ្យបងប្អូនភិតភ័យតែប៉ុណ្ណោះ។

**ស៖** ឥឡូវនេះ ខ្ញុំសូមមកនិយាយអំពីកិច្ចប្រជុំមួយដែលនិយាយអំពីបញ្ហាសន្តិសុខ ឬក៏បញ្ហាសត្រូវផ្ទៃក្នុង។ យើងបាននិយាយអំពីបញ្ហានេះកាលពីម្សិលមិញហើយ។ នៅពេលដែលមានកិច្ចប្រជុំទាក់ទងទៅនឹងកិច្ចការផ្ទៃក្នុង ហើយនិងសន្តិសុខនៃក្រសួងការបរទេស តើមានកំណត់កិច្ចប្រជុំដែលត្រូវបានធ្វើឡើងដែរឬទេ?

[១៥:៣០:០៨]

**ឆ៖** ផ្នែកខាងខ្ញុំមិនមានកំណត់ហេតុអីទេ ត្រឹមត្រូវទេ ពីព្រោះមិនសូវអ្នកណាចេះសរសេរ។

**ស៖** ចុះខាងផ្នែកផ្សេងទៀតនៃក្រសួង ដែលលោកបាននិយាយថា អៀង សារី ជាប្រធានកិច្ចប្រជុំនោះ តើមានធ្វើជាកំណត់ហេតុជាលាយលក្ខណ៍អក្សរទេ?

**ឆ៖** ខ្ញុំនិយាយខាងផ្នែកខាងបញ្ញាជនៗ គឺផ្នែកខាងបរទេស ផ្នែកខាងបច្ចេកទេស ផ្នែកខាងក្រសួងការបរទេសដែលទាក់ទងនឹងបរទេស នោះមានកំណត់ហេតុ ហើយខ្ញុំអត់មានចូលទៅប្រជុំក្នុងផ្នែកនោះទេ។

**ស៖** នៅពេលដែលប្រជុំដែលមានប្រមូលផ្តុំបញ្ញាជន និងវណ្ណៈកសិករ ដែលដឹកនាំដោយលោកអៀង សារី តើមានកំណត់ហេតុដែរឬទេ?

[១៥:៣១:៤៩]

**ឆ៖** មិនមានច្របូកច្របល់កសិករជាមួយនឹងបញ្ញាជនទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ឥឡូវនេះខ្ញុំចង់បង្ហាញឯកសារមួយទៀត។ គឺជាឯកសារសម័យនោះ គឺឯកសារលេខ E3/857 ដែលមានលេខ IS18.49។ នេះជារបាយការណ៍ដែលមានចំណងជើងជាភាសាអង់គ្លេស ដែលមានន័យថា ធ្វើការជាមួយគណៈកម្មាធិការគ្រប់អង្គភាពទាំងអស់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧ គឺនៅភាសាខ្មែរលេខ ERN 0086707 រហូតទៅដល់ 0086713 ហើយជាភាសាអង់គ្លេស 00355487 រហូតទៅដល់ 94 ឯកសារនេះមិនទាន់បានបកប្រែ ជាភាសាបារាំងនៅឡើយទេ។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បញ្ចាំងឯកសារនេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៥:៣៥:១៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំទុកពេលមួយចំនួនឲ្យសាក្សី ដើម្បីឲ្យគាត់ពិនិត្យមើលឯកសារនេះ។

**ស៖** ខ្ញុំចង់សួរសំណួរទីមួយទៅកាន់សាក្សី។ តើលោកធ្លាប់ឃើញរបាយការណ៍ ឬក៏កំណត់ហេតុនេះទេ? លោកធ្លាប់ស្គាល់ឯកសារនេះទេ?

**ឆ៖** បាទ ឯកសារផ្ទាល់ខ្លួនខ្ញុំ ខ្លួនខ្ញុំអត់ចាំផង។ ទម្រាំឯកសារគេផ្សេងទៀត ខ្ញុំមិនចាំទេ។ សែសិប ជិតសែសិបឆ្នាំហើយ បាទ សូមទោស។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ដើម្បីជួយឲ្យលោកបានចងចាំ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបញ្ចាក់អំពីការចង្អុលបង្ហាញមួយចំនួននៅក្នុងឯកសារនេះ ដើម្បីឲ្យគាត់ដឹងថា ឯកសារនេះចេញមកពីមន្ទីរប-១។ ដូច្នេះ ប្រសិនបើអង្គជំនុំអនុញ្ញាត ខ្ញុំនឹងអានឃ្លាមួយចំនួន ដែលនិយាយអំពីប-១ នៅក្នុងឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវាស!

[១៥:៣៦:៣៨]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ កាលពីមុនគឺនីតិវិធីក្នុងការបង្ហាញឯកសារជូនសាក្សី គឺយើងសួរសាក្សីថាធ្លាប់ឃើញឯកសារនេះពីមុនដែរឬក៏អត់? ហើយបន្ទាប់មកយើង-- ចំពោះសំណួរដែលបានរៀបចំដោយសហព្រះរាជអាជ្ញា ខ្ញុំមិនជំទាស់ទេ ប៉ុន្តែយើងត្រូវសួរទៅគាត់ថា ធ្លាប់បានឃើញឯកសារនេះពីមុន ឬក៏អត់? បើគាត់ធ្លាប់បានឃើញ សម្រាប់ខ្ញុំ ចំពោះបញ្ហានេះយើងនឹងបន្តការតាំងសំណួរទៅលើសាក្សីជាបន្តទៅទៀត ហើយអាចនឹងយកខ្លឹមសារនៃឯកសារនេះ យកមកតាំងសំណួរសួរ។ នេះតាមជា តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ក្នុងការអនុញ្ញាតឲ្យធ្វើបែបនេះ បើតាមខ្ញុំយល់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ សូមលោកតំណាងសហព្រះរាជអាជ្ញា អនុវត្តឲ្យបានត្រឹមត្រូវទៅតាមអ្វីដែលយើងបានអនុវត្តរួចមកហើយ តាំងពីដើមទីនៃការពិភាក្សាដេញដោលសំណុំរឿងក្តីនេះ។ ហើយចំពោះសាក្សីនានានៅចំពោះមុខអង្គជំនុំជម្រះ ចំពោះឯកសារដែលមានបំណងដាក់ចំពោះមុខអង្គជំនុំជម្រះ។ ហើយត្រូវសួរដល់សាក្សីអំពីការដែលខ្លួនធ្លាប់បានឃើញ បានជួប និងបានស្គាល់ ឬបានស្គាល់នូវឯកសារ ដែលខ្លួនប៉ុនប៉ងដាក់ដេញដោលដែរឬទេ? បើអត់ទេ គឺអង្គជំនុំជម្រះនឹងបង្គាប់ឲ្យដកឯកសារនោះចេញ ហើយដេញដោលនូវលក្ខណៈទូទៅនៃបញ្ហានានាដែលខ្លួនយល់ឃើញថា មានប្រយោជន៍នៅក្នុងការដេញដោលកិច្ចដំណើរការពិភាក្សាក្នុងសវនាការ។

[១៥:៣៨:៣០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំសួរសំណួរតែមួយចំនួនទេ ជាលក្ខណៈទូទៅ ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃឯកសារនេះ។ ប៉ុន្តែមិនសំដៅទៅលើទំព័រជាក់លាក់នៃឯកសារនេះទេ។ អ៊ីចឹងសូមអាចឯកសារនេះអាចដកចេញពីសាក្សីបាន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកឯកសារចេញពីសាក្សី ហើយបុគ្គលិកជំនួយការដកឯកសារនេះចេញពីអេក្រង់កុំព្យូទ័រ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំចង់សួរសាក្សីអំពីសេចក្តីបញ្ជាក់ទៅលើកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួង។ កាលពីម្សិលមិញ

យើងបាននិយាយថា ក្នុងកិច្ចប្រជុំគេនិយាយអំពីខ្មាំង ហើយនិងការការពារ និងការកសាងជាតិ។ តើកិច្ចប្រជុំមួយចំនួនដែលលោកបានចូលរួមនោះ មាននិយាយអំពីការជ្រៀតចូល ឬក៏ការបង្កប់ខ្លួនរបស់ខ្មាំងនៅក្រសួងការបរទេសដែរឬទេ?

[១៥:៤០:០១]

**ឆ៖** សូមអរគុណ។ ការប្រជុំ ខ្ញុំមានទស្សនៈផ្ទាល់ខ្លួនខ្ញុំ ស្នេហាជាតិ ស្នេហាប្រជាជនពិតប្រាកដ។ ឯកសារមាន ខ្ញុំឃើញថា ឯកសារទាំងអស់ជាឯកសារត្រឹមត្រូវដែលខ្ញុំចូលចិត្ត។ ទីពីរ ផ្ទាល់ខ្លួនខ្ញុំ ក៏ច្នៃប្រឌិតខ្លួនឯង ដើម្បីឲ្យបងប្អូន ពិសេសបងប្អូនជាកសិករនេះយល់នូវខ្លឹមសារអ្វីជាស្នេហាជាតិ អ្វីដែលជាមិនស្នេហាជាតិ។ ដូច្នេះ ឧទាហរណ៍ ខ្ញុំត្រូវរករឿងរ៉ាវអីផ្សេងៗឲ្យបងប្អូនយល់អំពីអារម្មណ៍ហ្នឹង ឲ្យសប្បាយផង ឲ្យយល់ផង ដើម្បីឲ្យគេជ្រួតជ្រាប។ ឧទាហរណ៍ ក្នុងសភាពការណ៍ឥឡូវនេះ ខ្ញុំយកសភាពការណ៍ឥឡូវនេះ ខ្ញុំមិនចង់ឲ្យមានរឿងក្របីឃ្មៀច និងក្របីខ្មៅ ត្រូវទន្សាយចាក់ចុចអុជអាលឲ្យឈ្លោះគ្នាទេ។ សូមជ្រាប។

**ស៖** ខ្ញុំបានឮចម្លើយរបស់លោកអម្បាញ់មិញនេះ ក៏ប៉ុន្តែ តើលោកអាចត្រឡប់មកឆ្លើយនឹងសំណួរដំបូងដែលខ្ញុំចង់ដឹងថា តើកិច្ចប្រជុំនោះមានបាននិយាយអំពីការជ្រៀតចូល ឬក៏ការបង្កប់ខ្លួនរបស់ខ្មាំងនៅក្នុងក្រសួងការបរទេសទេ? ហើយយើងត្រូវតែមានការប្រុងប្រយ័ត្នចំពោះការជ្រៀតចូលនេះ។

**ឆ៖** នេះបញ្ហាហ្នឹង គឺត្រូវតែមាន មិនតែត្រឹមចូលក្រសួងការបរទេសទេ គឺចូលក្នុងជាតិទាំងមូល។ ហើយខ្ញុំគិតថា មិនចូលក្នុងជាតិទាំងមូលទៀត ខ្ញុំគិតថាវាខូចបរិស្ថានទាំងមូលទៀតណោះ។ ខ្លាំងៗបន្តិចបាទ។

**ស៖** តើអ្នកណាជាខ្មាំងទាំងអស់ហ្នឹង? អ្នកខ្មាំងណាដែលថាព្យាយាមចូលទៅក្នុងជួរបក្សនោះនៅថ្នាក់ជាតិ ហើយនិងនៅថ្នាក់ក្រសួងការបរទេស? តើជាខ្មាំងប្រភេទណា?

[១៥:៤៣:០៦]

**ឆ៖** បើលោកសួរដូច្នេះ ខ្ញុំពិបាកពន្យល់ណាស់ ប៉ុន្តែខ្ញុំអាចសរុបជូនលោកបាន។ ខ្មាំងដែលធំបំផុត គឺខ្មាំងបំផ្លាញពិភពលោក ខ្មាំងដែលបំផ្លាញពិភពលោក គឺខ្មាំងដែលបំផ្លាញបរិស្ថាន ទឹក ដី ខ្យល់ ភ្លើង។ សូមលោកជ្រាប។ ព្រឹកមិញ ខ្ញុំបានជម្រាបហើយ ភ្លេចឲ្យស្ទូន្យ យើងទាំងអស់គ្នាភ្លេចឲ្យស្ទូន្យ។ បានត្រឹមតែ ០១ បានត្រឹមតែ ០០២ តែប៉ុណ្ណោះ។ សូមអភ័យទោស សូមជ្រាប។

**ប្រធានអង្គជំនុំ៖**

សាក្សីសូមរៀបចំនូវអារម្មណ៍ឲ្យបានល្អ ឲ្យបាននឹងឡើងវិញ ដើម្បីផ្តល់អារម្មណ៍ដើម្បីឆ្លើយតបទៅនឹងសំណួរដែលសួរ ហើយព្យាយាមដើម្បីស្តាប់សំណួរឲ្យបាន ហើយឆ្លើយឲ្យចំនឹងសំណួរដែលសួរ នេះជាការល្អសម្រាប់បំពេញភារកិច្ចក្នុងនាមជាសាក្សី ហើយគោលដៅគឺអាចបានឆាប់ចប់។ ដើម្បីបានវិលត្រឡប់ទៅលំនៅដ្ឋានប្រកបមុខរបរចិញ្ចឹមជីវិតវិញណ៎!

[១៥:៤៤:៣៧]

**ស៖** ខ្ញុំមិនសូវយល់អំពីអ្វីដែលលោកនិយាយអម្បាញ់មិញនេះ ដែលមានន័យថា អ្នកដែលចង់បំផ្លាញពិភពលោក បំផ្លាញបរិស្ថាន។ តើលោកអាចបញ្ជាក់ឲ្យច្បាស់ជាងហ្នឹងបានទេ? ថាតើអ្នកណាដែលជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងនោះ? ហើយតើគេអាចស្វែងរកខ្មាំងនោះដោយរបៀបណា?

**ឆ៖** អំពីរឿងបំផ្លាញពិភពលោក ខ្ញុំមិនអាចពន្យល់នៅទីនេះបានទេ។ បើខ្ញុំពន្យល់ទីនេះបានទាល់តែមួយខែ។ ឯរឿងតាមដានខ្មាំងនោះ ខ្ញុំមិនមែនជាអ្នកបច្ចេកទេសតាមដានខ្មាំងទេ។ ខ្ញុំបាននិយាយសាចុះសាឡើងហើយ ខ្ញុំធ្វើអារម្មណ៍ខ្លួនឯង ឲ្យខ្លួនឯងហ្នឹង វាស្អាតដោយខ្លួនឯងជាមុន បានមើលខ្មាំងពីក្រោមកឃើញ។ ឯការចាប់ចងអីៗនេះ ខ្ញុំមិនមានទេ។ ខ្ញុំអត់មានតួនាទីទេ។ ជាគិញជាចារកម្មអី អត់ទេ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញារៀបចំនូវសំណួរឲ្យបានខ្លី ឲ្យបានងាយយល់ ហើយបើអាចបញ្ជាក់បាននូវកាលបរិច្ឆេទនៃគោលបំណងនៃការសួរ អំពីការដែលប្រើពាក្យថា "ខ្មាំងស៊ីរូងផ្ទៃក្នុង" ហ្នឹង ផ្អែកមើលមូលដ្ឋានឯកសារអ្វី ឬក៏កាលៈទេសៈណាដែលកើតឡើងនឹងពាក្យនេះ ហើយថាតើសាក្សីហ្នឹងគាត់បានដឹង ធ្លាប់បានឮពាក្យនេះ ដែរឬទេ? នៅក្នុងអំឡុងពេលដែលគាត់រស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។

[១៥:៤៧:០១]

អង្គជំនុំជម្រះបានជម្រាប រំឭកភាគីរួចហើយ កាលពីអំឡុងពេលសប្តាហ៍មុន គប្បីខិតខំធ្វើយ៉ាងណា ក្នុងការរៀបចំការតាំងសំណួរឲ្យកាន់តែខ្លី ហើយសាមញ្ញ ងាយយល់ ដើម្បីឲ្យគោលដៅនៃការសួរហ្នឹង គាត់មានលទ្ធភាពស្តាប់យល់នូវសំណួរដែលសួរ ហើយគាត់បានឆ្លើយតបនឹងសំណួរនោះ បានគ្រប់សព្វទាំងអស់។ នេះជាប្រយោជន៍ដើម្បីស្វែងរកការពិត។ វាមិនសំខាន់នឹងការសួរស៊ីជម្រៅរហូតដល់

សាក្សីមិនយល់ ហើយឆ្លើយក៏មិនអាចតបបាន ដោយសារកម្រិតនៃការតាំងសំណួរវាជ្រៅពេក មិនអាចឆ្លើយតបបាននោះ វាអត់មានប្រយោជន៍អីដែលនាំឲ្យមានពន្លឺ មានព័ត៌មានដើម្បីវិភាគពិចារណាសម្រេចលើបញ្ហាទាំងអស់នោះបានឡើយ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី ខ្ញុំនិយាយសំដៅទៅដល់រយៈពេលដែលលោកមានវត្តមាននៅក្រសួងការបរទេស ហើយក្នុងអំឡុងពេលនោះ គឺមានកិច្ចប្រជុំមួយចំនួនដែលមានគោលដៅស្វែងរកខ្មាំងស៊ីរូងផ្ទៃក្នុង ហើយដែលលោកនិយាយថា មានខ្មាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រសួង។ លោកអាចនិយាយបានទេ នៅពេលដែលមាន-- តើនៅពេលដែលមានភាពសុទ្ធនោះ គឺថាមានសត្រូវពីខាងក្រៅ។ ខ្ញុំមិនដឹងថាតើជាសត្រូវប្រភេទណាទេ?

[១៥:៤៨:៤១]

នៅពេលដែលយើងនិយាយអំពីខ្មាំងបង្កប់ ឬខ្មាំងស៊ីរូងផ្ទៃក្នុងនោះ តើជាគិញ ឬក៏អ្នកណា?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំមិនអាចនិយាយបានទេ។ ដូចខ្ញុំបានជម្រាបអំមិញហើយ ខ្ញុំមិនអាចនិយាយបានទេ។

**ស៖** ខ្ញុំទទួលបានការបកប្រែ ថាខ្ញុំមិនអាចឆ្លើយទៅនឹងសំណួរនេះទេ។ ខ្ញុំចង់ដឹងថាតើលោកមិនចេះឆ្លើយ ឬក៏ថាលោកមិនចង់ឆ្លើយទៅនឹងសំណួរនេះ? ព្រោះថាការបកប្រែជាភាសាបារាំង ដូចជាមិនសូវច្បាស់។

**ឆ៖** ពីព្រោះ ខ្ញុំមិនមែនជាអ្នកបច្ចេកទេសខាងស៊ើបការណ៍រកខ្មាំងទេ។ ខ្ញុំជាអ្នកធ្វើការងារសតិអារម្មណ៍ឲ្យបងប្អូន ឲ្យឃើញខ្មាំងតែប៉ុណ្ណោះ។

[១៥:៥០:០៥]

**ស៖** លោកសាក្សី តើលោកធ្លាប់មានចូលរួមនៅក្នុងកិច្ចប្រជុំដែលមានការពិភាក្សាគ្នាអំពីចំណុចដែលចង់ដឹងថា តើមានកម្មាភិបាល ឬក៏យុទ្ធជនប៉ុន្មាននាក់នៅក្នុងក្រសួងការបរទេសដែលមានភាពស្អាតស្អំ មានជាសមាសភាពល្អ? ហើយមានភាគរយប៉ុន្មានដែលថាមិនស្អាតស្អំ មិនល្អ ហើយដែលត្រូវបានគេសង្ស័យនោះ? តើលោកមានធ្លាប់ចូលរួមនៅក្នុងកិច្ចប្រជុំបែបនេះដែរឬទេ?

**ឆ៖** អត់មានទេ។

[១៥:៥០:៥៨]

**ស៖** នៅពេលដែលលោកនិយាយថា មានខ្មាំងបង្កប់ ឬខ្មាំងស៊ីរូងផ្ទៃក្នុង តើមានការពិភាក្សានៅក្នុងកិច្ចប្រជុំពាក់ព័ន្ធទៅនឹងការបង្កប់ខ្លួនរបស់ពួក សេ.អ៊ី.អា, កា.ហ្សេ.បេ ឬក៏ភ្នាក់ងារយួនដែរឬទេ?

**ឆ៖** រូបភាពទាំងអស់នេះ ខ្ញុំមិនសូវយល់ទេ ខ្ញុំឮតែគេថាដែរ។ មិនដឹងជា កា.ហ្សេ.បេ អី, សេ.អ៊ី.អា អីក៏មិនដឹងដែរ ខ្ញុំមិនសូវយល់ទេ។ ខ្ញុំយល់ថា ធ្វើការងារឲ្យល្អ បើថាធ្វើការងារភារកិច្ចខ្លួនឯងមិនល្អ គឺត្រូវតែកសាងខ្លួនតែប៉ុណ្ណោះ។

**ស៖** បើតាមលោកដឹង តើការប្រុងប្រយ័ត្នបដិវត្តន៍នេះ មានន័យថាម៉េច ពាក្យថា "ប្រុងប្រយ័ត្នបដិវត្តន៍" នេះនៅសម័យនុ៎ង?

**ឆ៖** ពាក្យថា "ប្រុងប្រយ័ត្នបដិវត្តន៍" ហ្នឹង ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺប្រុងកុំឲ្យគេជិះក្បាល ហើយត្រូវ--កុំឲ្យគេជិះក្បាល ហើយត្រូវមានមេត្តា កុំទៅជិះក្បាលគេ។

[១៥:៥៣:១៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំមានឯកសារធំមួយដែលត្រូវដាក់ជូនសាក្សី។ ខ្ញុំមិនដឹងថា តើវាជាពេលសមស្របដែរឬទេ ដែលត្រូវបង្ហាញឯកសារនេះជូនសាក្សី ប្រសិនបើលោកប្រធានអនុញ្ញាតនោះ ខ្ញុំអាចស្នើសុំការពន្យល់មួយចំនួនពីសាក្សី ពីព្រោះថា នៅក្នុងភាសាអង់គ្លេស បារាំង និងខ្មែរនោះ វាមានភាពខុសគ្នា មិនសូវស៊ីសង្វាក់គ្នា។ ដូច្នេះ ខ្ញុំត្រូវការពេលវេលាប្រាំនាទី ដើម្បីពន្យល់ថា តើគួរតែប្រើឯកសារមួយណាត្រឹមត្រូវនោះ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

នេះ គឺជាឯកសារដែលមានលេខ E3/522 ដែលមានលេខមួយផ្សេងទៀត គឺ E3/926។ ហើយនិងមានលេខមួយទៀត គឺលេខ D267/5/1.1.25។ ឯកសារលេខ D267/5/1.1.25 នេះគឺជាឯកសារដើមជាភាសាខ្មែរ។ ដូច្នេះ គឺមានទំព័រពេញលេញគ្រប់ក្នុងឯកសារនេះ ហើយមានបកប្រែជា

ភាសាអង់គ្លេស ក៏មានពេញលេញដែរ។ ក៏ប៉ុន្តែនៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងឯកសារជាភាសាបារាំងវិញ ឯកសារលេខ E3/925 នោះក៏មានលេខ IS14.1 ដែរ។ ដូច្នេះក្នុងនេះ គឺមានឯកសារជាភាសាខ្មែរ គឺឯកសារខ្មែរនេះ គឺដូចគ្នាទៅនឹងឯកសារដែលខ្ញុំបានលើកឡើងអម្បាញ់មិញដែរ។ ហើយមាន-- ឯកសារនេះត្រូវបានបកប្រែជាភាសាអង់គ្លេស ប៉ុន្តែមានបញ្ហាជាមួយនឹងឯកសារ IS14.1 ពីព្រោះថា មានទំព័រច្របូកច្របល់គ្នាមួយចំនួន មានទំព័រខ្លះជាន់គ្នា ហើយមានបាត់ទំព័រមួយចំនួន។ ដូច្នេះចាប់ពីផ្តោតទៅលើការបកប្រែជាភាសាបារាំងនេះគឺធ្វើចេញពីឯកសារដែលបាត់នេះ។ ហេតុនេះហើយបានជាខ្ញុំចង់បញ្ជាក់ជូនអង្គជំនុំជម្រះថា ឯកសារជាភាសាបារាំងនោះមិនត្រូវបានបកប្រែពេញលេញអំពីឯកសារជាភាសាខ្មែរទេ។ ដូច្នេះខ្ញុំព្យាយាមយោងទៅលើឯកសារជាភាសាអង់គ្លេសវិញ ព្រោះអង់គ្លេសវាពេញលេញជាង។

[១៥:៥៦:៣០]

ដូច្នេះ ខ្ញុំចង់បង្ហាញឯកសារលេខ D267/5/1.1.25 ជូនសាក្សី ហើយសូមអនុញ្ញាតបង្ហាញឯកសារនេះ ដែលជាឯកសារធំណាស់ ដែលមានរហូតទៅដល់ប្រហែលជា ២០០ទំព័រជាងឯណោះ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ចាត់ការលោកតំណាង-- អ៊ំ លោកមន្ត្រីរដ្ឋបាលតុលាការ!

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវ៉ាស!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមស្នើថា គួរតែអនុវត្តនីតិវិធីបង្ហាញឯកសារចំពោះឯកសារមួយនេះដូចគ្នាទៅនឹងការបង្ហាញចំពោះឯកសារមុនៗ។ ទីមួយសួរទៅសាក្សី ថាតើគាត់ធ្លាប់បានឃើញឯកសារនេះពីមុនមកទេ? បើសាក្សីឆ្លើយថា មិនដែលឃើញទេ មិនចាំបាច់បង្ហាញនូវលេខទំព័រ ឬក៏លេខអ្វីមួយនោះទេ។ ខ្ញុំគិតថា នីតិវិធីគួរតែប្រើប្រាស់ចំពោះឯកសារនេះដដែល។

[១៥:៥៧:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

មុននឹងប្រគល់ឯកសារនេះជូនទៅសាក្សី យើងអាចសួរសាក្សីអំពីកំណត់ហេតុ ឬក៏កូនសៀវភៅ

ដែលគាត់អាចរក្សាទុក។ ពីព្រោះថា វាជាការសំខាន់ដែលត្រូវចោទសួរសំណួរនេះទៅកាន់សាក្សីសិន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណណាស់លោកចៅក្រម។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អម្បាញ់មិញលោកនិយាយអំពីកំណត់ហេតុ ដែលលោកបានសរសេរនៅក្នុងកូនសៀវភៅមួយ។ តើលោកបានដឹងអំពីទ្រង់ទ្រាយនៃកូនសៀវភៅកំណត់ហេតុនេះទេ? ដែលថាតើមានអី មានរូបស្អីខ្លះនៅទំព័រទីមួយនៃសៀវភៅនេះ?

[១៥:៥៨:៤១]

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំអត់យល់ទេសំណួរនេះ ងងឹតឈឹងហើយនេះ។

**ស៖** កាលពីអម្បាញ់មិញនេះ លោកបាននិយាយថា លោកបានកត់ត្រាធ្វើជាកំណត់ហេតុ គឺដោយតែលោកបាននិយាយអំពីគិញអម្បាញ់មិញនេះ គឺថាមានជាសៀវភៅកំណត់ហេតុមួយ ដែលលោកសរសេរនៅសម័យកម្ពុជាប្រជាធិបតេយ្យ ហើយលោកបានបាត់កូនសៀវភៅនេះ។ ដូច្នេះ ខ្ញុំចង់ថាតើសៀវភៅនេះមានទ្រង់ទ្រាយរូបរាងយ៉ាងម៉េចដែរ? តើមានអក្សរ ឬក៏មានរូបអីនៅលើទំព័រទីមួយដែរឬទេ? ហើយសៀវភៅហ្នឹងដូចទៅហ្នឹងអីដែរ ចំពោះសៀវភៅខាងក្នុងនោះ?

**ឆ៖** កំណត់ហេតុ យើងនិយាយថា សៀវភៅហ្នឹងវា ខ្ញុំនិយាយមុនហ្នឹងវាជ្រុលមាត់ក៏មិនដឹងទេ កំណត់ហេតុហ្នឹងវាក្រដាស យើងមួយសន្លឹក ពីរសន្លឹកកត់អ៊ីចឹង ជំនាន់នោះនោះ។ មានសៀវភៅអីឲ្យត្រឹមត្រូវដូចឥឡូវទេ។ ប៉ុន្តែ ខ្ញុំឃើញរូបភាពអំមិញហ្នឹងចេញអីរាជសីអី មកខ្ញុំដូចជាឆ្ងល់ដែរ សៀវភៅមិនទេ អត់ទេបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សោកស្តាយណាស់លោកប្រធាន ទំព័រទីមួយនេះគឺបានបង្ហាញទៅហើយ មុនពេលដែលខ្ញុំសួរសំណួរនោះ។ ប៉ុន្តែសៀវភៅរបស់សាក្សីនោះ គឺដូចទៅនឹងអ្វីដែលយើងបានពិពណ៌នា នៃឯកសារនេះដែលនឹងបង្ហាញជូននេះ។ ឥឡូវនេះ តើខ្ញុំមានសិទ្ធិដើម្បីបង្ហាញឯកសារនេះជូនទៅសាក្សី ដើម្បីសួរថាគាត់ធ្លាប់ឃើញឯកសារនេះដែរឬទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ ពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិជូនទៅសាក្សីពិនិត្យឯកសារជាមុនសិន។

សូមអញ្ជើញតំណាង-- មេធាវីជាតិការពារក្តីលោក ខៀវ សំផន!

[១៦:០១:៣៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមធ្វើការកត់សម្គាល់ថា ដោយសារឯកសារនេះវាមានទំហំធំ ហើយអ៊ីចឹងការពិនិត្យរបស់សាក្សី គឺមិនដឹងថាពិនិត្យយ៉ាងម៉េចទេ។ បើសិនជាគាត់ត្រូវអានអត្ថបទនេះ វាត្រូវចំណាយពេលច្រើន។ អ៊ីចឹងសូមសហព្រះរាជអាជ្ញាមេត្តាណែនាំទៅសាក្សី ថាតើឲ្យគាត់ពិនិត្យទៅលើអ្វី? ទៅទម្រង់ ទៅលើគម្របខាងក្រៅ ឬមួយទៅលើខ្លឹមសារ ដែលជាប់ពាក់ព័ន្ធនៅក្នុងសៀវភៅនៃឯកសារនេះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ដើម្បីឲ្យបានជ្រះស្រឡះបញ្ហានេះ សូមលោកតំណាងសហព្រះរាជអាជ្ញាអញ្ជើញធ្វើការកត់សម្គាល់ទៅលើបញ្ហាមួយចំនួន ដើម្បីរំឭកការចងចាំដល់សាក្សីរូបនេះ។ ហើយមុននឹងសួរគាត់ថា គាត់ធ្លាប់ឃើញឯកសារនេះពីមុនមកដែរឬទេ។

[១៦:០២:៣៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្អាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្អាឯល៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ឃើញឯកសារនេះពីមុនមកទេ? ខ្ញុំដឹងថាមិនមានពេលគ្រប់គ្រាន់ក្នុងការអាននៅពេលនេះទេ ប៉ុន្តែសូមឲ្យលោកគ្រាន់តែបើកមើលឯកសារនេះឲ្យលឿនបន្តិចទៅ។

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំគ្រាន់តែមើលឃើញក្បាលឯកសារនេះ ឃើញថា ខ្ញុំ មិនៗដឹង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្អាឯល៖**

លោកប្រធាន។ ខ្ញុំសូមឲ្យសាក្សីអាន គឺថាមិនចាំបាច់អានចំណងជើងខាងលើទេ ព្រោះវាអត់

ពាក់ព័ន្ធនឹងខ្លឹមសារទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំចង់សួរសាក្សីថា តើសាក្សីធ្លាប់ត្រូវបានអ្នកស៊ើបអង្កេត នៃសហចៅក្រមស៊ើបអង្កេត ធ្លាប់បានបង្ហាញគាត់ទេ នៅក្នុងអំឡុងពេលកិច្ចស៊ើបសួរនោះ?

**លោក សាឡូត បាន៖**

**ឆ៖** អត់មានបានទេ អត់មានបានឃើញឯកសារនេះទាំងអស់ អត់។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមយោងទៅលើកំណត់ហេតុស្តាប់ចម្លើយមួយចំនួន ដែលមានការសួរសំណួរទៅកាន់សាក្សីរូបនេះ គឺឧទាហរណ៍ឯកសារ-- ខ្ញុំយោងទៅលើឯកសារនេះតែម្តងគឺលេខ-- ពាក់ព័ន្ធទៅនឹង D267/5/1.1.25 គឺមានឯកសារលេខ D369/36 នៅក្នុងចម្លើយសំណួរ៥២, ៧១ និង៦៧។ ហើយនៅក្នុងកំណត់ហេតុមួយទៀត ដែលមានលេខ D233/9 នៅក្នុងសំណួរ១, ២, ៣ គឺបានសួរអំពីឯកសារនេះដែរ ប៉ុន្តែដោយស្មោះត្រង់សហចៅក្រមស៊ើបអង្កេត មិនបានបង្ហាញពីលេខយោងឲ្យបានច្បាស់ទេ។ ដូច្នេះនៅក្នុងឯកសារលេខ D369/36 បានបញ្ជាក់ថា ឯកសារកំណត់ហេតុកូនសៀវភៅនេះត្រូវបានបង្ហាញដើម្បីសួរសំណួរទៅកាន់សាក្សី។ ដូច្នេះ ខ្ញុំចង់សួរសំណួរដដែល ថាតើគាត់មានធ្លាប់ឃើញសៀវភៅហ្នឹងទេ កាលពីមុនមកនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហ-- អ៎ លោកមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអាចនឹងចង្អុលបង្ហាញថា នៅពេលយើងបង្ហាញ-- នៅពេលដែលសហចៅក្រមស៊ើបអង្កេតបង្ហាញឯកសារ សាក្សីបានបញ្ជាក់ហើយថា គាត់អត់បានឃើញឯកសារនេះទេ មិនធ្លាប់បានឃើញទេ ហើយមិនដឹងថាអ្នកណាសរសេរនៅលើសៀវភៅនេះផងដែរ។ ដូច្នេះ ខ្ញុំយល់ឃើញថា ត្រូវតែសួរឲ្យបានច្បាស់លាស់ថា តើគាត់ពិតប្រាកដជាស្គាល់ឯកសារនេះទេ? ធ្លាប់បានប្រើទេ? ដូច្នេះ ខ្ញុំយល់ឃើញថា ត្រូវតែយកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដើម្បីមកអនុវត្តក្នុងការសួរឯកសារនេះ ពីព្រោះសាក្សីបានបញ្ជាក់ហើយថា គាត់មិនដែលឃើញឯកសារនេះ ហើយក៏មិនដឹងថាអក្សរដៃនេះអ្នកណាជាអ្នកសរសេរនោះផងដែរ បើសហព្រះរាជអាជ្ញាបានបង្ហាញថា សហចៅក្រម

សើុបអង្កេតធ្លាប់បានបង្ហាញក៏ដោយ។

[១៦:០៦:៥៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ប៉ុន្តែស្ថានភាពនេះទំនងជាអាចខុសពីអ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ ពីព្រោះបញ្ហាឯកសារនេះត្រូវបានអ្នកសើុបអង្កេត-- សហចៅក្រមសើុបអង្កេត បានយោងទៅដល់ក្នុងការសួរដេញដោល ដែលបានធ្វើរួចហើយនៅក្នុងដំណាក់កាលសើុបអង្កេតនោះ។ ដោយឡែកឯកសារផ្សេងទៀត ដែលយើងបានធ្វើកន្លងមកនោះគឺ មិនមានស្ថានភាពធ្វើដូច្នេះទេ។ អ៊ីចឹងហើយបានយើងចង់ធ្វើបញ្ហានេះឲ្យបានជាក់ច្បាស់ថា តើគាត់ពិតជាបានធ្លាប់បានឃើញដែរឬទេ? បើតាមការអះអាងនិងការចង្អុលបង្ហាញរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ យ៉ាងហោចក៏ទំនងជាគាត់ត្រូវបានអ្នកសើុបអង្កេត បានចង្អុលបង្ហាញឯកសាររួចហើយ នៅក្នុងអំឡុងពេលសើុបអង្កេត ដែលយោងទៅឯកសារ D369/36។ អ៊ីចឹងហើយបានអង្គជំនុំជម្រះចង់ដឹងអំពីបញ្ហានេះ ថាតើហេតុការណ៍វាមានមែនឬអត់? បើមានមែន កើតឡើងមានមែននោះ គឺជាការភ័ន្តច្រឡំរបស់សាក្សីប៉ុណ្ណោះ ដែលគាត់មិនបាន មិនមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យឯកសារនេះ ឲ្យបានយូរទើបគាត់ភ្លេច។ ការភ្លេចនេះ វាខុសពីការដែលគាត់មិនបានឃើញសោះ ហើយគ្មានហេតុផល ឬក៏ព្រឹត្តិការណ៍មួយដែលបង្ហាញបញ្ជាក់ថាគាត់ពិតជាធ្លាប់បានឃើញពីមុនមកទេ។

អ៊ីចឹងស្ថានភាពនេះ ខុសពីស្ថានភាពដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញា ធ្វើការចង្អុលបង្ហាញនូវឯកសារដែលពាក់ព័ន្ធនឹងដំណើរការនៃការធ្លាប់បានចង្អុលបង្ហាញឯកសារនេះដល់សាក្សី នៅក្នុងអំឡុងពេលដំណើរការសើុបសួរ។

[១៦:០៨:៥០]

**លោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា យើងហួសម៉ោងបួនជាងហើយ ហើយខ្ញុំមានសំណួរជាច្រើនសួរពាក់ព័ន្ធទៅនឹងកូនសៀវភៅនេះ។ ដូច្នេះ ខ្ញុំសូមស្នើផ្អាកសវនាការត្រឹមនេះសិន ឬមួយក៏ខ្ញុំត្រូវចាប់ផ្តើមសួរសំណួរពាក់ព័ន្ធទៅនឹងខ្លឹមសារនៃឯកសារនេះលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះឲ្យលោកសួរពាក់ព័ន្ធទៅនឹងការស្គាល់នៃឯកសារនេះ។ ថាតើធ្លាប់បានឃើញដែរ

អត់ដែលលោកបានចង្អុលបង្ហាញទៅដល់ឯកសារ D369/36 ដែលមានការ សំណួរដោយសហចៅក្រមស៊ើបអង្កេតចង្អុលបង្ហាញថា សាក្សីហ្នឹងពិតជាត្រូវបានសហចៅក្រមស៊ើបអង្កេតបានបង្ហាញនូវឯកសារ D267/5/1.1.25 រួចហើយ ដែលលោកអះអាងអំមិញប៉ុន្មានចំណុចនោះ ដើម្បីឲ្យពន្លឿននៃកិច្ចពិភាក្សានេះ។ ថ្ងៃស្អែក គឺយើងនឹងប្រគល់វេទិកាជូនលោក ដើម្បីលោកសួរដេញដោលអំពីខ្លឹមសារទូទៅនៃឯកសារនេះតែម្តង។

[១៦:១០:០០]

**សួរដោយលោក វាំងសង់ វ៉ាយន៍ ដេស្សាងលេះ**

**ស៖** លោកសាក្សី តើលោកអាចបញ្ជាក់បានទេថា ទំព័រមួយចំនួននៃឯកសារនេះត្រូវបានបង្ហាញជូនដោយអ្នកស៊ើបអង្កេត ដើម្បីពួកគាត់ទទួលបាននូវយោបល់របស់លោកពាក់ព័ន្ធទៅនឹងខ្លឹមសារនៃឯកសារនេះ កាលពីនៅក្នុងអំឡុងពេលកិច្ចស៊ើបសួរនោះ?

**លោក សាឡុត បាន៖**

**ឆ៖** បាទឯកសារនេះ ខ្ញុំមិនដឹងទេ។ ប៉ុន្តែ ខ្ញុំមិនបានមើលអីច្បាស់លាស់ទេ ប៉ុន្តែខ្លឹមសារខ្លះខ្ញុំមិនបានមើលឲ្យច្បាស់។ ដូច្នេះ ខ្ញុំកំណត់ថា ឯកសារនេះខ្ញុំមិនដែលបានឃើញ ខ្លឹមសារខ្ញុំមិនបានមើលហ្មត់ចត់ ដូច្នេះខ្ញុំមិនទទួលទេបាទ។ សូមៗ បើសិជាខ្ញុំមើលទៅឃើញថា អូ៎! ខ្លឹមសារនេះប្រហែលជាដូចសម័យមុន សម័យប្រជុំអីវាមាននិយាយអ៊ីចឹងខ្លះ ខ្ញុំក៏មិនដឹងជាអ្នកណាសរសេរកំណត់ហេតុដែរ។ ប៉ុន្តែ ឯកសារនេះសរុបទៅមិនមែនជាឯកសាររបស់ខ្ញុំទេ។

[១៦:១២:០៤]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដោះស្រាយបញ្ហានេះដូច្នេះ ដើម្បីឲ្យច្បាស់លាស់ពីព្រោះនៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងទៅលើឯកសារ D369/36 ដែលលោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដោយមានកំណត់ត្រាថាបានថា បង្ហាញ-- គេបានបង្ហាញឯកសារនេះ គឺឯកសារដែលនៅនឹងមុខលោកនេះ គឺ D267/5/1.1.25 នៅចំពោះលោក ហើយគេដាក់សួរដេញដោលរួចហើយ។ គ្រាន់តែមិនសួររួមទៅទេ ប៉ុន្តែគេដកនូវទំព័រមួយចំនួននៃឯកសារនោះ យកមក ដោយឯកសារនោះ វាមានស្ថានភាពជាការបោះពុម្ពមែន ប៉ុន្តែវាមានកំណត់ត្រា កំណត់ត្រាខ្លីៗនៅលើទំព័រនៃឯកសារនោះ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះ-- អ៎! ខាងសហព្រះរាជអាជ្ញាគេលើកៗចំណុចនេះ

ឡើងដើម្បីយកមកដេញដោលលោក គេផ្អែកលើឯកសារទាំងនេះ ដោយយោងទៅកំណត់ហេតុដែលលោកបានឆ្លើយនៅចំពោះអ្នកស៊ើបអង្កេត។

[១៦:១៣:១៥]

ឥឡូវនេះដើម្បីឲ្យបានជាក់ច្បាស់នោះ គឺអង្គជំនុំជម្រះទុកពេលវេលាសម្រាប់លោកពិនិត្យឯកសារនេះ នៅថ្ងៃស្អែកអាចចំណាយពេលវេលាមួយចំនួនមុនពេលដំណើរការសវនាការ ដើម្បីលោកពិនិត្យរួចហើយ សូមចាប់ផ្តើមពិភាក្សាគ្នាសាជាថ្មីម្តងទៀត ដើម្បីឲ្យលោករំឭកនូវការចងចាំ ជាពិសេសនៅពេលដែលលោកឆ្លើយចំពោះមុខអ្នកស៊ើបអង្កេតកន្លងមកនោះតើវាមានបញ្ហាដូច្នេះដែរឬទេ។ វាមានបញ្ហាលើកឯកសាររបៀបនេះមកបង្ហាញលោកដែរឬទេ? ពីព្រោះនៅក្នុងសំណួរនេះ គេមានសួរពាក់ព័ន្ធទៅនឹងឯកសារនេះ បានន័យថា នៅក្នុងកំណត់ត្រាក្រសួងការបរទេស ឯកសារ D267/5.1.1.25 លេខ ERN 00427826 បាននិយាយថា អ៊ីៗអ៊ីចឹងខ្លឹមសារនេះ ហើយលោកបានឆ្លើយថា "បាទ មានការចាត់តាំងដូច្នេះមែន"។ ខ្ញុំលើកឡើងខ្លីទេ គ្រាន់តែមានបញ្ហាវែងទៀត ដោយគេសួរផ្អែកលើឯកសារហ្នឹង ប៉ុន្តែដោយសារវាឯកសារធំ អ៊ីចឹងគឺអង្គជំនុំជម្រះនឹងទុកពេលវេលាសម្រាប់លោកពិនិត្យបញ្ហានេះ។ អ៊ីចឹងស្អែកហ្នឹងគឺ លោកសូមអញ្ជើញមកមុនម៉ោង ហើយនឹងអាចឲ្យមន្ត្រីរដ្ឋបាលតុលាការផ្តល់ឯកសារនេះ។ លោកនឹងមានពេលវេលាពិនិត្យវាមួយគ្រួសទៅដើម្បីដល់ពេលយើងចូលមកវាអាចបន្តនូវកិច្ចពិភាក្សាហ្នឹងបានទៅតែម្តង។ អាចធ្វើអ៊ីចឹងបានទេ?

[១៦:១៤:៥០]

បាទ អរគុណច្រើន ដោយសារពេលវេលាសមល្មមសម្រាកហើយ លើស១៥នាទីហើយ។ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកបន្តទៅធ្វើនៅថ្ងៃស្អែក ហើយអង្គជំនុំជម្រះដោយសារភាពចាំបាច់នៃសួរដេញដោលចំពោះសាក្សី លោក សាឡុតបាន គឺនៅតែដំណើរការទៀត។ ដូច្នេះ អង្គជំនុំជម្រះអញ្ជើញលោកមកចូលរួមផ្តល់សក្ខីកម្ម នៅបន្តនៅថ្ងៃស្អែកទៀត ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ប៉ុន្តែដោយសារតែបញ្ហា គប្បីចំណាយពេលវេលាអានអក្សរនេះ គឺលោកអាចមកមុនម៉ោងបន្តិចទៅ ដើម្បីចំណាយពេលវេលាខ្លះ សម្រាប់ពិនិត្យបញ្ហានេះ។ ហើយដូចគ្នា មេធាវីប្រឹក្សាសាក្សី សូមអញ្ជើញលោកមកអមក្នុងការផ្តល់សក្ខីកម្មរបស់សាក្សីនេះនៅក្នុងអំឡុងពេលនៃការសួរដេញដោលគាត់តាំងពីនេះ រហូតដល់ចប់។

ហើយសុំមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលនូវការអានឯកសារ ហើយនិងអញ្ជើញគាត់មក

ផ្តល់-- មកកាន់កន្លែងផ្តល់សក្ខីកម្មនេះនៅព្រឹកថ្ងៃស្អែក ត្រឹមម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៦នាទី)*